សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា

IPAC

Intellectual Property Association of Cambodia

# ក្រមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹង ពាណិជ្ជសញ្ញា

ចងក្រងនៅខែសីហា ឆ្នាំ២០២១

# មាតិកា

1. ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៣
2. អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦
3. ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១១
4. ប្រកាសស្តីពី ភ្នាក់ងារតំណាងស្របច្បាប់នៃម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១
5. ប្រកាសស្តីពី ការបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មាធិការប្រឡងសម្រាប់រៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២
6. ប្រកាសរួមស្តីពី ការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងការប្រកាសរួមលេខ ៩៨៥ សហវ ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០១៤
7. សេចក្តីជូនដំណឹងស្តីពី ការកត់ត្រាទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ២០១៥
8. សារាចរណែនាំស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឆ្នាំ២០១៥
9. ប្រកាសស្តីពី នីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ព័ន្ធម៉ាកផ្តាច់មុខ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦
10. ប្រកាសស្តីពី នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញាតកម្ម ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦
11. ប្រកាសស្តីពី នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦
12. ប្រកាសស្តីពី នីតិវិធីសម្រាប់កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦
13. ប្រកាសស្តីពីនីតិវិធីនៃការដាក់ស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧
14. ប្រកាសស្តីពីនីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករដ្ឋមន្ត្រីពាណិជ្ជកម្ម ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

# ១. ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការ ប្រកួតប្រជែងមិនស្មោះត្រង់

# ព្រះរាជក្រម

នស/រកម/០២០២/០០៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ម៉ាក ពាណិជ្ជនាម និងអំពើ
# នៃការប្រកួតប្រជែងមិនស្មោះត្រង់

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារម៉ាក ពាណិជ្ជនាមដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជានិងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម ។

**មាត្រា ២.-**

**ក-ម៉ាក** គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់សំរាប់សេវាហៅថា សេវាសញ្ញា ។

**ខ-ម៉ាកសមូហភាព** គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសំគាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសំគាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី ។

**គ-ពាណិជ្ជនាម** គឺជាឈ្មោះ ឬសញ្ញាសំគាល់ ឬជាឈ្មោះនិងសញ្ញាសំគាល់សំរាប់បញ្ជាក់និងសំគាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ ។

**មាត្រា ៣.-**

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៤.-**

ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ :

ក- ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត ។

ខ- ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីល-ធម៌ ឬប្រពៃណីល្អរបស់ជាតិ ។

គ- ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភាន់ច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ ។

ឃ- ម៉ាកដែលដូចគ្នានិង/ ឬត្រាប់តាម ឬមានចំណុចណាមួយដូចសញ្ញាជាតិ ទង់ជាតិនិងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋនោះ ឬអង្គការនោះ ។

ង- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះសំរាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហ-គ្រាសមួយទៀត ។

ច- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នាដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី ។

ឆ- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេងដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុននៅឯបរទេស ចំពោះទំនិញឬសេវាដូចគ្នា ឬទំនិញឬសេវាដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

# ជំពូកទី ២

## ការចុះបញ្ជីនិងសិទ្ធិដែលកើតឡើងពីការចុះបញ្ជីម៉ាក

មាត្រា ៥.-

បែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ។

ពាក្យស្នើសុំត្រូវភ្ជាប់ :

-គំរូម៉ាក

-បញ្ជីទំនិញឬសេវាដែលត្រូវចុះបញ្ជី ដោយរាយលំអិតតាមក្រុមមុខទំនិញទៅតាមចំណាត់ថ្នាក់អន្តរជាតិ ដូចមានក្នុងឧបសម្ព័ន្ធ ។

ខ- ការសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាកនិងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងពាណិជ្ជកម្ម ។

មាត្រា ៦.-

សិទ្ធិអាទិភាពក្នុងការចុះបញ្ជីម៉ាក ត្រូវបានផ្តល់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :

ក- អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាពនៃការចុះបញ្ជី ដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមាន តាមរយៈការស្នើសុំចុះបញ្ជីនៅប្រទេសណាមួយដែលជាសមាជិកនៃអនុសញ្ញាក្រុងប៉ារីស ។

ខ- តម្លៃនៃប្រកាសស្តីពីអាទិភាពខាងលើ ត្រូវតែស្របទៅតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

មាត្រា ៧.-

អ្នកស្នើសុំចុះបញ្ជីអាចដកពាក្យស្នើសុំរបស់ខ្លួននៅពេលណាក៏បាន ។

មាត្រា ៨.-

ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវ :

ក- ពិនិត្យមើលពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌនៃមាត្រា ៥ និងបទបញ្ញាដែលជាប់ទាក់ទង ។

ខ- ពិនិត្យនិងកំណត់ថាម៉ាកនោះគឺជាម៉ាកស្របតាមល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងមាត្រា ២ ចំណុច ក និងមិនអាចចុះបញ្ជីបានតាមមាត្រា ៤ ដោយលើកលែងតែចំណុច ឆ នៃមាត្រា៤ នេះចេញ ។

មាត្រា ៩.-

អាទិភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានកំណត់ដូចតទៅ :

ក- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូចឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំតាមពេលវេលាខុសគ្នា មន្ត្រីកាន់កាប់បញ្ជីអាចបដិសេធការចុះបញ្ជីម៉ាកណាមួយនៃម៉ាកទាំងនោះរហូតដល់ពេលដែលសិទ្ធិនៃអ្នកស្នើសុំទាំងនោះត្រូវបានកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ឬត្រូវបានដោះស្រាយដោយការព្រមព្រៀងគ្នា និងមានការយល់ព្រមពីមន្ត្រីកាន់កាប់បញ្ជី ។

ខ- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំក្នុងពេលជាមួយគ្នា ក្រោយពីការពិគ្រោះឯកភាពគ្នាទៅវិញទៅមកក្នុងចំណោមអ្នកស្នើសុំទាំងអស់ មានអ្នកស្នើសុំតែម្នាក់គត់ដែលអាចទទួលបាននូវការចុះបញ្ជីម៉ាក ។

មាត្រា ១០.-

សិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីរកឃើញថាល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ បានត្រូវបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក ចេញវិញ្ញាបនប័ត្រនៃការចុះបញ្ជីជូនអ្នកស្នើសុំនិងចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

ខ- ពាក្យស្នើសុំចុះបញ្ជីដែលមិនបានសមស្របតាមមាត្រា ៨ អ្នកស្នើសុំចុះបញ្ជី អាចកែតម្រូវក្នុងរយៈពេល ៤៥ (សែសិបប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំពីអ្នកសុំចុះបញ្ជីតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ ។

គ- ក្នុងរង្វង់ ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការហើយ ជនណាដែលមានការពាក់ព័ន្ធ អាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួនចំពោះការចុះបញ្ជីម៉ាក តាមបែបបទដែលបានកំណត់ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមល័ក្ខខ័ណ្ឌណាមួយនៃមាត្រា ២ ចំណុច ក មាត្រា ៤ និងមាត្រា ៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ ។

ឃ- មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់នូវសេចក្ដីជូនដំណឹងនោះមួយច្បាប់ទៅអ្នកសុំចុះបញ្ជីតាមពេលវេលានិងបែបបទដែលបានកំណត់ ។ បន្ទាប់មកអ្នកស្នើសុំចុះបញ្ជីត្រូវបញ្ជូនទៅមន្ត្រីកាន់កាប់បញ្ជីនូវចម្លើយបញ្ជាក់អំពីមូលដ្ឋានបង្អែកទាំងឡាយសម្រាប់ការចុះបញ្ជីរបស់ខ្លួន ។ ប្រសិនបើមិនបានឆ្លើយតបទេ ម្ចាស់ម៉ាកនោះត្រូវចាត់ទុកថាបានបោះបង់ចោលការចុះបញ្ជីរបស់ខ្លួន ។

ង- ប្រសិនបើអ្នកសុំចុះបញ្ជីធ្វើពាក្យជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្ដល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្ដឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង ឬភាគីទាំងសងខាងមានបំណងចង់ឱ្យមានសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្ដាប់ភាគីទាំងសងខាងនិងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវ

សម្រេចថាម៉ាកដែលបានចុះបញ្ជីនេះត្រូវរក្សាទុក ឬបដិសេធ ។

មាត្រា ១១.-

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវាដែលបានចុះបញ្ជីរួច ហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រម ពីម្ចាស់ដើមជាមុនសិន ។

ខ- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែល នឹងម៉ាក ដែលខ្លួនបានចុះបញ្ជីរួចហើយនិងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយនោះ ហើយដែលអាចបណ្តាលឱ្យមានការភាន់ច្រឡំជាសាធារណៈ ។

គ- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាកនឹងមិនរាប់បញ្ចូល នូវការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបាន ចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

មាត្រា ១២.-

សុពលភាពក្នុងការចុះបញ្ជីម៉ាកនិងការចុះបញ្ជីសាជាថ្មីត្រូវបានកំណត់តាម លក្ខខ័ណ្ឌដូចខាងក្រោម :

ក- ម៉ាកដែលបានចុះបញ្ជីហើយ មានសុពលភាព ១០(ដប់) ឆ្នាំចាប់ពី កាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ។

ខ- តាមការស្នើសុំ ការចុះបញ្ជីម៉ាកមួយ អាចធ្វើឡើងសាជាថ្មីសំរាប់ រយៈពេល ១០ (ដប់)ឆ្នាំ ម្តងជាបន្តបន្ទាប់ក្នុងលក្ខខ័ណ្ឌដែលម្ចាស់ដើមបង់អាករចុះបញ្ជី ជាថ្មីតាមការកំណត់ ។

គ- ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយ មុនពេលដែលច្បាប់នេះចូលជាធរមាន អ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដែលចង់បានការការពារ ដោយផ្អែកតាមចំណាត់ថ្នាក់អន្តរជាតិ ។

ឃ- ការអនុគ្រោះចំពោះការយឺតយ៉ាវក្នុងការចុះបញ្ជីសាជាថ្មីត្រូវបានអនុញ្ញាតត្រឹមតែរយៈពេល ៦ (ប្រាំមួយ) ខែ ។

## ជំពូកទី ៣

## មោឃភាពនិងការលុបម៉ាកចេញពីបញ្ជី

**មាត្រា ១៣.-**

មោឃភាពនិងអានុភាពនៃមោឃភាពត្រូវបានកំណត់ដូចខាងក្រោម :

ក- ជនណាដែលមានការពាក់ព័ន្ធ អាចស្នើសុំមកក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវទុកការចុះបញ្ជីជាមោឃៈ ប្រសិនបើជនដែលស្នើសុំឱ្យមានមោឃភាពនោះ បង្ហាញថាមានល័ក្ខខ័ណ្ឌណាមួយនៃមាត្រា ២ ចំណុច ក និងមាត្រា ៤ មិនត្រូវបានបំពេញ ។

គ- មោឃភាពនៃការចុះបញ្ជីម៉ាកត្រូវមានអានុភាពចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ហើយត្រូវបានកត់ត្រានិងបោះពុម្ពផ្សាយជាបន្ទាន់ ។

**មាត្រា ១៤.-**

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបចោលម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងករណីដូចខាងក្រោម :

ក- អ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយតាមរយៈពេលដែលបានកំណត់ក្នុងមាត្រា ១២ ចំណុច ខ និងចំណុច ឃ ។

ខ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ។

គ- ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនគោរពល័ក្ខខ័ណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់នៅក្នុង មាត្រា ៨ ។

ឃ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយលែងមានអាស័យដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ជឿជាក់ដោយផ្អែកលើភ័ស្តុតាងថា ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនមែនជាម្ចាស់ស្របច្បាប់ ។

ច- ជឿជាក់ថាម៉ាកដែលបានចុះបញ្ជីរួច ហើយប្រហាក់ប្រហែលឬដូចគ្នាទៅនឹងម៉ាកល្បីដែលជាកម្មសិទ្ធិរបស់ភាគីទីបី ។

**មាត្រា ១៥.-**

ម៉ាកដែលបានចុះបញ្ជីរួច ប៉ុន្តែមិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ ត្រូវបានលុបចេញពីបញ្ជី ។ ប្រសិនបើម្ចាស់ម៉ាកបង្ហាញថា កាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាក ហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេ ម៉ាកនោះ នឹងមិនត្រូវបានលុបចេញពីបញ្ជីឡើយ ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យក្រសួងពាណិជ្ជកម្មលុបម៉ាកចេញពីបញ្ជី ១ (មួយ) ខែ មុនកាលបរិច្ឆេទ ៥(ប្រាំ) ឆ្នាំ នៃការមិនបានប្រើប្រាស់ ឬក្រោយកាលបរិច្ឆេទនេះ ។

## ជំពូកទី ៤

## ម៉ាកសមូហភាព

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងពីមាត្រា ៣ ដល់មាត្រា ១៥ ព្រមទាំងមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់នេះ ត្រូវអនុវត្តចំពោះម៉ាកសមូហភាព ។

មាត្រា ១៧.-

បែបបទនៃការចុះបញ្ជីម៉ាកសមូហភាពមានដូចតទៅ ៖

ក- ពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពត្រូវបញ្ជាក់ថាជាម៉ាកសមូហភាព និងត្រូវភ្ជាប់មកជាមួយនូវបទបញ្ញារួមស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ម៉ាកសមូហភាពនោះមួយច្បាប់ ។

ខ- ម្ចាស់ម៉ាកសមូហភាព ដែលបានចុះបញ្ជីហើយ ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីអំពីការផ្លាស់ប្ដូរទាំងឡាយតាមបទបញ្ញាដែលបានយោងក្នុងកថាខណ្ឌ ក ។

មាត្រា ១៨.-

បន្ថែមលើខ្លឹមសារដូចមានចែងក្នុងមាត្រា ១៣ ចំណុច ក និងចំណុច ខ មន្ត្រីកាន់កាប់បញ្ជីត្រូវចាត់ទុកការចុះបញ្ជីម៉ាកសមូហភាពជាមោឃៈ ប្រសិនបើជនដែលទាមទារនូវមោឃភាពនោះបង្ហាញថា មានតែម្ចាស់ដែលបានចុះបញ្ជីម្នាក់ឯងប៉ុណ្ណោះដែលប្រើប្រាស់ម៉ាក ឬបង្ហាញថាម្ចាស់ដែលបានចុះបញ្ជីប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់រំលោភទៅនឹងបទបញ្ញារួមដែលបានបញ្ញត្តិនៅក្នុងមាត្រា ១៧ ចំណុច ក ឬបង្ហាញថាម្ចាស់ដែលបានចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់តាមរបៀបមួយដែលអាចបំភាន់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជនអំពីប្រភពដើម ឬលក្ខណៈរួមផ្សេងទៀតនៃទំនិញ ឬសេវាដែលពាក់ព័ន្ធ ។

## ជំពូកទី ៥

## ការផ្ដល់អាជ្ញាប័ណ្ណចំពោះម៉ាក

មាត្រា ១៩.-

ការផ្ដល់អាជ្ញាប័ណ្ណចំពោះម៉ាកត្រូវបានកំណត់ដូចខាងក្រោម ៖

ក- កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយអំពីការចុះបញ្ជីម៉ាក ឬពាក្យស្នើសុំ

ទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះ ត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាព ពីសំណាក់អ្នកប្រគល់អាជ្ញាប័ណ្ណ ចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញា-ប័ណ្ណដែលម៉ាកនោះត្រូវបានប្រើប្រាស់ ។ ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែង អំពីការត្រួតពិនិត្យគុណភាពនោះ ឬប្រសិនបើការត្រួតពិនិត្យគុណភាពនោះមិនត្រូវបាន អនុវត្តដោយមានប្រសិទ្ធភាពទេ កិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកជាមិនបាន ការ ។

ខ- ការចុះបញ្ជីម៉ាកសមូហភាពមួយ ឬពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហ-ភាពនោះមិនអាចជាកម្មវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណបានឡើយ ។

## ជំពូកទី ៦

## ពាណិជ្ជនាម

**មាត្រា ២០.-**

នាម ឬសញ្ញាសំគាល់មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយប្រសិន បើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសំគាល់ដែលបានកំណត់នោះប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និងជាពិសេសអាចបំភាន់ដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាសដែលកំណត់ដោយនាមនោះ ។

**មាត្រា ២១.-**

ការការពារនិងការរំលោភលើពាណិជ្ជនាមត្រូវបានចែងដូចខាងក្រោម :

ក- ទោះជាច្បាប់ ឬបទបញ្ញាទាំងឡាយចែងអំពីកាតព្វកិច្ចក្នុងការចុះ បញ្ជីពាណិជ្ជនាមក៏ដោយ ក៏នាមទាំងនោះត្រូវបានការពារប្រឆាំងនឹងទង្វើមិនស្របច្បាប់ របស់ភាគីទីបី ទោះមុនការចុះបញ្ជី ឬគ្មានការចុះបញ្ជីក៏ដោយ ។

ខ- ការប្រើប្រាស់ពាណិជ្ជនាមជាបន្តបន្ទាប់ដោយភាគីទីបី ទោះបីជា ពាណិជ្ជនាម ឬម៉ាក ឬជាម៉ាកសមូហភាព ឬការប្រើប្រាស់ណាមួយដែលអាចធ្វើឱ្យ សាធារណជនភាន់ច្រឡំត្រូវចាត់ទុកថាមិនស្របច្បាប់ ។

## ជំពូកទី ៧

## អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

មាត្រា ២២.-

អំពើនៃការប្រកួតប្រជែងណាដែលផ្ទុយពីគោលការណ៍នៃការអនុវត្តទៀងត្រង់នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថាជាការប្រកួតប្រជែងមិនស្មោះត្រង់ ។

មាត្រា ២៣.-

ទង្វើទាំងឡាយដូចខាងក្រោមត្រូវចាត់ទុកថាបានបង្កើតនូវអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ :

ក- ការបង្កើតឱ្យមានការភាន់ច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

ខ- ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះសហគ្រាស ទំនិញ ឬសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

គ- ការបញ្ជាក់ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឱ្យសាធារណជនភាន់ច្រឡំអំពីប្រភេទ ដំណើរការផលិត លក្ខណៈភាពសមស្របសំរាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ ។

## ជំពូកទី ៨

## ការរំលោភនិងវិធានការដោះស្រាយ

មាត្រា ២៤.-

ដោយផ្អែកតាមមាត្រា ១២ ខាងលើ ការរំលោភលើម៉ាកគឺជាការប្រព្រឹត្តដែលទាក់ទងទៅនឹងមាត្រា ១១ នៃច្បាប់នេះ ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាកដែល

បានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលពុំមានការយល់ព្រមពីម្ចាស់ម៉ាក ។

មាត្រា ២៥.-

ការប្រើប្រាស់នូវសញ្ញាដូចឬប្រហាក់ប្រហែល ដែលធ្វើឱ្យភាន់ច្រឡំទៅនឹងម៉ាកល្បីដែលបានចុះបញ្ជីរួចហើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញាទាំងនោះត្រូវបានយកមកប្រើប្រាស់ :

ក- ទាក់ទងទៅនឹងទំនិញនិងសេវា ដែលដូចឬប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច ។

ខ- ទាក់ទងទៅនឹងទំនិញនិងសេវា ដែលមិនដូចឬមិនប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បីដែលបានចុះបញ្ជីរួច ហើយការប្រើប្រាស់នូវសញ្ញាទាក់ទងនឹងទំនិញឬសេវានោះបញ្ជាក់នូវការពាក់ព័ន្ធគ្នារវាងទំនិញនិងសេវានោះជាមួយនឹងម្ចាស់នៃម៉ាកល្បី ហើយដែលផលប្រយោជន៍នៃម្ចាស់ម៉ាកល្បីអាចនឹងត្រូវខូចខាតដោយការប្រើប្រាស់នោះ ។

មាត្រា ២៦.-

ការប្រើប្រាស់នូវសញ្ញាដែលដូចឬប្រហាក់ប្រហែលនឹងម៉ាកល្បីដែលមិនបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញានោះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលនឹងទំនិញឬសេវានៃម៉ាកល្បីនោះ ។

មាត្រា ២៧.-

តាមសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណ តុលាការអាចចេញនូវសេចក្ដីសម្រេចបណ្ដោះអាសន្នមួយដើម្បីទប់ស្កាត់ការរំលោភ ការដែលនឹងមានការ

រំលោភ ឬធ្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ និងសម្រេចឱ្យសងការខូចខាត ហើយផ្តល់នូវដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ជាធរមាន ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណបានស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការ ដើម្បីឱ្យផ្តួសផុលនូវសំណងដីជាក់លាក់មួយ ប៉ុន្តែបើម្ចាស់ម៉ាក បានបដិសេធ ឬខកខានមិនបានធ្វើតាម អ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន ។

មាត្រា ២៨.-

តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬជនណាមួយដែលមានការពាក់ព័ន្ធដូចជា សមាគម ឬសហជីពនៃផលិតករ ឧស្សាហករ ឬពាណិជ្ជករ តុលាការអាចសំរេចឱ្យមានការជួសជុលសំណង ចំពោះករណីនៃការប្រកួតប្រជែងមិនស្មោះត្រង់ដូចមានចែងនៅក្នុងមាត្រា ២២ និងមាត្រា ២៣ ។

## ជំពូកទី ៩

## វិធានការបណ្តោះអាសន្ន

មាត្រា ២៩.-

តាមសំណើរបស់អ្នកប្តឹង តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជាបន្ទាន់និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភ ការរំលោភដែលប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ព័ន្ធ ។

មាត្រា ៣០.-

នៅពេលចាំបាច់ ជាពិសេសនៅពេលការយឺតយ៉ាវអាចបណ្តាលឱ្យមានភាពអន្តរាយដែលមិនអាចជួសជុលបានចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលភស្តុតាងអាចនឹងត្រូវបំផ្លាញ តុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្ន ប្រសិនបើដើមចោទផ្តល់នូវ ៖

ឥ- ភស្តុតាងត្រឹមត្រូវដែលមាន ដែលអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបញ្ជាក់ថា ដើមចោទគឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះ អាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ ។

ខ- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ក្នុងការការពារចុងចម្លើយនិងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន ។ ប្រាក់កក់ធានានេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ ។

**មាត្រា ៣១.-**

នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយ អំពីសេចក្តីសម្រេចស្តីពីការចាត់វិធានការបណ្តោះអាសន្ននោះ ។

**មាត្រា ៣២.-**

នៅពេលដែលវិធានការបណ្តោះអាសន្ន ត្រូវបានដាក់ចេញតាមមាត្រា ៣០ និងមាត្រា ៣១ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងទៅតុលាការស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញក្នុងរយៈពេល ១៥ ( ដប់ប្រាំ ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ។ តុលាការត្រូវផ្តល់នូវឱកាសសវនាការឱ្យដល់ភាគីដែលពាក់ព័ន្ធ ហើយត្រូវពិនិត្យវិធានការនោះឡើងវិញនិងតម្កល់ កែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់ ។

**មាត្រា ៣៣.-**

ក្នុងករណីដើមចោទ នៅក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការបណ្តោះអាសន្នហើយ ឬនៅ ក្នុងរយៈពេលមួយសមស្របដែលកំណត់ដោយតុលាការនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ពុំបានផ្តួចផ្តើមបន្តសំណុំរឿងបណ្តឹងដែលនាំដល់សេចក្តីសម្រេចអំពីអង្គសេចក្តីនៃករណី

តុលាការត្រូវលុបនូវវិធានការបណ្តោះអាសន្ននោះចោលវិញ ដោយផ្អែកតាមសំណើរបស់ចុងចម្លើយ ។

មាត្រា ៣៤.-

ក្នុងករណីដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោលវិញ ឬក្នុងករណីដែលតុលាការសម្រេចនូវអង្គសេចក្តីនៃករណីតាមដំណាក់ការជំនុំជម្រះក្តីស្របតាមមាត្រា ៣៣ តាមការផ្តួចផ្តើមរបស់ដើមចោទ ប៉ុន្តែបែរជាគ្មានការរំលោភ ឬការគំរាមរំលោភវិញ ដោយយោងតាមសំណើរបស់ចុងចម្លើយ តុលាការត្រូវសម្រេចឱ្យដើមចោទសងឱ្យចុងចម្លើយនូវសំណងសមស្របចំពោះការខូចខាតនានាដែលកើតមានឡើងដោយការអនុវត្តនូវវិធានការបណ្តោះអាសន្ននោះ ។

## ជំពូកទី ១០

## វិធានការតាមទាត់ច្រកព្រំដែន

មាត្រា ៣៥.-

ម្ចាស់ម៉ាកដែលបានចុះបញ្ជីហើយអាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យឃុំទុកនូវការធ្វើបែបបទទំនិញណាដែលសង្ស័យថាមានម៉ាកក្លែងក្លាយដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។

មាត្រា ៣៦.-

ពាក្យបណ្តឹងទាំងឡាយដែលបានលើកនៅក្នុងមាត្រា ៣៥ ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវអមដោយ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក ។

ខ- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹងនិងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន ។

គ- ការរៀបរាប់ពីល្អិតល្អន់ពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផង ប្រសិនបើមានសំណូមពរ ។

ឃ- ឈ្មោះនិងអាស័យដ្ឋានរបស់អ្នកប្តឹងនិងតំណាងរបស់គេដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់ ។

ង- លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ ។

ច- កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹងតាមមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថាត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកសម្រាប់ពិចារណានៅពេលក្រោយ ។

**មាត្រា ៣៨.-**

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតដែលកំណត់ដោយអនុក្រឹត្យ មានសិទ្ធិស្នើឱ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានាដែលមានតំលៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ សម្រាប់ការពារអ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬម្ចាស់ទំនិញនិងអាជ្ញាធរមានសមត្ថកិច្ច ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់នេះត្រូវបានកំណត់តាមរបៀបនិងបែបបទមួយដែលមិនត្រូវឱ្យរារាំងដល់ការអនុវត្តនីតិវិធីនេះដោយមិនសមហេតុផល ។

**មាត្រា ៣៩.-**

ក្នុងពេលយល់ព្រមតាមពាក្យបណ្តឹងក្នុងមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញដែលមានទាក់ទងទៅនឹងពាក្យបណ្តឹង ។ ការព្យួរទុកនេះត្រូវនៅជាធរមានក្នុងរយៈពេលដំបូងនិងក្នុងរយៈពេលដែលបានពន្យារមិនលើសពី

១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅអ្នកនាំចូលនិងអ្នកប្តឹងអំពីការល្បួរទុកនូវការធ្វើបែបបទទំនិញ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការល្បួរទុកនេះផង ។ រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនដំណឹងពីឈ្មោះនិងអាស័យដ្ឋាននៃអ្នកប្តឹងដល់អ្នកនាំចូលផងដែរ ។

## មាត្រា ៤០.-

ក្នុងរយៈពេលមិនហួសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដែលអ្នកប្តឹងបានទទួលនូវពត៌មានអំពីការឃាត់ទំនិញ ប្រសិនបើរដ្ឋបាលគយនិងរដ្ឋាករបានទទួលនូវពត៌មានថា ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្តីនៃករណីមិនត្រូវបានផ្តួចផ្តើមឡើងដោយភាគីមួយទៀតផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវមិនបានអនុវត្តនូវវិធានការបណ្តោះអាសន្នដើម្បីពន្យារការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែងតែក្នុងករណីដែលលក្ខខ័ណ្ឌផ្សេងៗទៀតសម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព ។

ក្នុងករណីសមស្រប រយៈពេលនេះអាចត្រូវពន្យារ ១០ (ដប់) ថ្ងៃទៀតនៃថ្ងៃធ្វើការ ។

ប្រសិនបើចំណាត់ការ ដែលនាំឱ្យមានការសម្រេចនូវអង្គសេចក្តីនៃករណីត្រូវបានផ្តួចផ្តើមឡើង ការពិនិត្យឡើងវិញមានទាំងការធ្វើសវនាការផង ត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយដើម្បីសម្រេចនៅក្នុងរយៈពេលមួយសមស្របថា តើវិធានការនេះត្រូវតម្កល់ កែតម្រូវ ឬលុបចោល ។

## មាត្រា ៤១.-

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធមានសិទ្ធិសម្រេចឱ្យអ្នកប្តឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញនិងអ្នកទទួលទំនិញនូវសំណងសមស្របចំពោះការខូចខាតរបស់គេដែលបណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទំនិញដូចមានចែងក្នុងមាត្រា ៣៩ ។ ក្នុងករណីភាគីណាមួយមិនយល់ព្រមតាមសេចក្តីសម្រេចនោះភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ ។

មាត្រា ៤២.-

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញពិនិត្យទំនិញដែលបានឃ្យទុកតាមបែបបទគយ ដូចមានចែងក្នុងមាត្រា ៣៩ និងដកយកនូវគំរូដើម្បីពិនិត្យសាកល្បងនិងវិភាគ ក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថាទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ ។

នៅពេលដែលទំនិញត្រូវបានបញ្ជាក់ឱ្យដឹងថាជាទំនិញពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយនិងរដ្ឋាករអាចជូនពត៌មានទៅម្ចាស់សិទ្ធិនូវឈ្មោះនិងអាស័យដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួលនិងបរិមាណទំនិញ ។ ដោយមិនឱ្យប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចផ្តល់ទៅឱ្យម្ចាស់សិទ្ធិនូវច្បាប់ចម្លងនៃឯកសារទំនិញទាំងនោះ ឬនូវពត៌មានដែលមាន ឬឯកសារដែលទាក់ទងទៅនឹងការនាំចូលឬនាំចេញនូវទំនិញប្រហាក់ប្រហែលពីមុនដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះតាមសំណូមពររបស់ម្ចាស់សិទ្ធិ ។

មាត្រា ៤៣.-

រដ្ឋបាលគយនិងរដ្ឋាករអាចឃ្យទុកនូវការធ្វើបែបបទទំនិញដែលពាក់ម៉ាកក្លែងក្លាយ ដែលខ្លួនបានពិនិត្យឃើញមានភស្តុតាងជាលើកដំបូងថា កំពុងតែមានឬអាចនឹងមានការនាំចូលនូវទំនិញប្រភេទនេះ ។

មាត្រា ៤៤.-

រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅឱ្យម្ចាស់សិទ្ធិ អំពីទីកន្លែងនិងថ្ងៃដែលឃ្យទុកនូវការធ្វើបែបបទរបស់គយ ហើយរដ្ឋបាលគយនិងរដ្ឋាករក៏អាចស្នើឱ្យម្ចាស់សិទ្ធិផ្តល់នូវពត៌មានទាំងឡាយដែលអាចជាជំនួយក្នុងការអនុវត្តនូវអំណាចរបស់ខ្លួនផងដែរ ។

មាត្រា ៤៥.-

ដោយអនុលោមទៅនឹងបញ្ញត្តិដែលមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ

អាជ្ញាធរសាធារណៈនិងមន្ត្រីទទួលបន្ទុកត្រូវបានលើកលែងពីការទទួលខុសត្រូវចំពោះវិធានការដោះស្រាយដោយសមស្រប នៅពេលដែលសកម្មភាពទាំងនោះត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់ ។

**មាត្រា ៤៦.-**

រដ្ឋបាលគយនិងរដ្ឋាករនិងអាជ្ញាធរមានសមត្ថកិច្ច តាមរយៈសេចក្តីសម្រេចរបស់តុលាការមានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយនោះ ។ រដ្ឋបាលគយនិងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យធ្វើការនាំចេញបន្តនូវទំនិញដែលមានម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះឱ្យនៅក្រោមនីតិវិធីផ្សេងទៀតរបស់គយឡើយ ។

**មាត្រា ៤៧.-**

ទំនិញពាក់ម៉ាកក្លែងក្លាយដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដែលនៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរអាចស្ថិតនៅក្រៅការអនុវត្តនៃច្បាប់នេះ ។

## ជំពូកទី ១១

## ការប្តូរម្ចាស់កម្មសិទ្ធិ

**មាត្រា ៤៨.-**

តាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវបានចុះបញ្ជី និងចុះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។ ការប្តូរបែបនេះនឹងមិនមានអានុភាព ចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

**មាត្រា ៤៩.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកសមូហភាព តម្រូវឱ្យមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាមុន ។

**មាត្រា ៥០.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃពាណិជ្ជនាម ត្រូវធ្វើឡើងដោយការផ្ទេរសហគ្រាសទាំងមូល ឬមួយផ្នែកហើយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

**មាត្រា ៥១.-**

ការប្តូរម្ចាស់កម្មសិទ្ធិនៃការចុះបញ្ជីម៉ាកត្រូវចាត់ទុកជាមោឃៈ ប្រសិនបើម៉ាកនោះទំនងជាមានលក្ខណៈបោកបញ្ឆោត ឬបណ្តាលឱ្យមានការភាន់ច្រឡំ ជាពិសេសចំពោះប្រភេទ ប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្របដើម្បីគោលបំណងនៃទំនិញ ឬសេវាដែលម៉ាកនោះបម្រុងប្រើប្រាស់ ឬកំពុងប្រើប្រាស់ ។

**មាត្រា ៥២.-**

កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយពាក់ព័ន្ធនឹងម៉ាកដែលបានចុះបញ្ជីរួចហើយ ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យា ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជីដែលត្រូវរក្សាការសម្ងាត់ចំពោះខ្លឹមសារនៃកិច្ចសន្យានោះ ប៉ុន្តែត្រូវចុះបញ្ជីនិងចុះផ្សាយនូវពត៌មានដែលពាក់ព័ន្ធ ។ កិច្ចសន្យាអាជ្ញាប័ណ្ណនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយរហូតដល់ការចុះបញ្ជីនោះត្រូវបានធ្វើរួចជាស្ថាពរ ។

## ជំពូកទី ១២
## ការកាន់កាប់បញ្ជីម៉ាក

**មាត្រា ៥៣.-**

ក្រសួងពាណិជ្ជកម្មមានតួនាទីបំពេញភារកិច្ចដែលទាក់ទងទៅនឹងនីតិវិធីដើម្បីធ្វើការចុះបញ្ជីម៉ាក និងដើម្បីធ្វើការគ្រប់គ្រងម៉ាកដែលបានចុះបញ្ជីរួចហើយ ដូចបានបញ្ជាក់នៅក្នុងច្បាប់នេះនិងនៅក្នុងបទបញ្ញាទាំងឡាយ ។

មាត្រា ៥៤.-

ក្រសួងពាណិជ្ជកម្ម ជាស្ថាប័នមានសមត្ថកិច្ចកាន់កាប់និងចុះបញ្ជីម៉ាក ។ ម៉ាកសម្ងហាភាពនឹងត្រូវចុះបញ្ជីនៅក្នុងផ្នែកពិសេសមួយនៃបញ្ជីម៉ាក ។ គ្រប់ការកត់ត្រាដែលមានចែងនៅក្នុងច្បាប់នេះ ត្រូវធ្វើនៅក្នុងបញ្ជីខាងលើ ។

ជនណាក៏ដោយក៏អាចមានសិទ្ធិសុំមើលបញ្ជីម៉ាកបានដែរ ហើយអាចដកស្រង់ចេញពីបញ្ជីនោះនូវពត៌មានផ្សេងៗ ដែលស្របទៅតាមល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបទបញ្ជា ។

មាត្រា ៥៥.-

ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពនៅក្នុងព្រឹត្តិប័ត្រផ្លូវការនូវគ្រប់ការចុះបញ្ជី ការចុះបញ្ជីសាឡើងវិញ ការបដិសេធ ការលុបម៉ាកចេញពីបញ្ជីនិងការងារផ្សេងៗទៀតដែលកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៦.-

តាមប្រការទាំងឡាយនៃបទបញ្ជា មន្ត្រីកាន់កាប់បញ្ជីអាចកែតម្រូវកំហុសផ្សេងៗនៅក្នុងការកត់ត្រាដែលបានធ្វើឡើង ដោយអនុលោមតាមច្បាប់នេះ ឬតាមបទបញ្ជាទាំងឡាយ ។

នៅពេលទទួលសំណើជាលាយលក្ខណ៍អក្សរហើយ ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថាជាការត្រឹមត្រូវដើម្បីធ្វើដូច្នោះ មន្ត្រីកាន់កាប់បញ្ជីអាចបន្តពេលវេលាសម្រាប់អនុវត្តសកម្មភាពណាមួយ ឬប្រកាន់យកនូវចំណាត់ការណាមួយតាមច្បាប់នេះ និងតាមបទបញ្ជាទាំងឡាយ ដោយជូនដំណឹងដល់ភាគីពាក់ព័ន្ធនិងតាមល័ក្ខខ័ណ្ឌដែលមន្ត្រីកាន់កាប់បញ្ជីដាក់បញ្ជាឱ្យ ។ ការបន្តនេះអាចត្រូវយល់ព្រម ទោះបីរយៈពេលអនុវត្តនូវសកម្មភាព ឬប្រកាន់យកនូវចំណាត់ការត្រូវផុតកំណត់ហើយក៏ដោយ ។

មាត្រា ៥៧.-

មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់នូវឱកាសសម្រាប់សវនាការដល់ភាគីណាមួយនៃបណ្តឹងនៅចំពោះមុខខ្លួនមុនពេលអនុវត្តអំណាចឆន្ទានុសិទ្ធិ ដែលបានប្រគល់ឱ្យដោយច្បាប់នេះនិងដោយបទបញ្ជាទាំងឡាយប្រឆាំងចំពោះភាគីនោះ ។

## ជំពូកទី ១៣

## ភ្នាក់ងារ

មាត្រា ៥៨.-

ក្នុងករណីដែលលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្មសំខាន់របស់អ្នកស្នើសុំស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា អ្នកស្នើសុំនោះត្រូវមានតំណាងជាភ្នាក់ងារដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥៩.-

អ្នកតំណាងដែលជាភ្នាក់ងារក្នុងការដាក់ពាក្យសុំចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ១៤

## ការអនុវត្តសន្ធិសញ្ញាអន្តរជាតិនិងការបកស្រាយ

មាត្រា ៦០.-

បទប្បញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញាអន្តរជាតិ អំពីកម្មសិទ្ធិឧស្សាហកម្មដែលព្រះរាជាណាចក្រកម្ពុជាជាភាគីមួយនៃសន្ធិសញ្ញានោះ ត្រូវយកមកអនុវត្តជាមួយនឹងច្បាប់នេះបានផងដែរ ។

ក្នុងករណីមានទំនាស់ជាមួយនឹងមាត្រាទាំងឡាយនៃច្បាប់នេះ បទប្បញ្ញត្តិនៃសន្ធិសញ្ញាអន្តរជាតិទាំងនោះត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

មាត្រា ៦១.-

នៅក្នុងច្បាប់នេះ :

**-ចំណាត់ថ្នាក់អន្តរជាតិ** មានន័យថា ចំណាត់ថ្នាក់ដែលអនុលោមតាមកិច្ចព្រមព្រៀងទីក្រុងនីស ដែលចែងអំពីចំណាត់ថ្នាក់អន្តរជាតិនៃទំនិញនិងសេវាកម្មសម្រាប់គោលបំណងនៃការចុះបញ្ជីម៉ាក ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៥៧ ដែលបានកែសម្រួលនៅពេលចុងក្រោយ

**-អនុសញ្ញាទីក្រុងប៉ារីស** មានន័យថា អនុសញ្ញាដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ស្តីពីការការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៨៨៣ ដែលបានកែសំរួលនៅពេលចុងក្រោយ

**-កាលបរិច្ឆេទអាទិភាព** មានន័យថា ពេលវេលានៃការស្នើសុំមុនគេដែលប្រើប្រាស់ជាមូលដ្ឋានសម្រាប់ទទួលនូវសិទ្ធិអាទិភាព ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស

**-បទបញ្ជា** មានន័យថា ប្រកាសឬសេចក្តីណែនាំដែលចេញដោយក្រសួងពាណិជ្ជកម្ម

**-ទំនិញដែលពាក់ម៉ាកក្លែងក្លាយ** មានន័យថា ទំនិញទាំងឡាយរួមទាំងសំបកវេចខ្ចប់ផងដែលមានម៉ាកដូចគ្នានឹងម៉ាកដែលបានចុះបញ្ជីត្រឹមត្រូវទាក់ទងទៅនឹងទំនិញនោះដោយគ្មានការអនុញ្ញាត ឬមិនអាចសំគាល់បាននូវលក្ខណៈខុសគ្នាពីទិដ្ឋភាពសំខាន់ៗនៃម៉ាក និងដែលរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកស្របច្បាប់ក្រោមច្បាប់នៃប្រទេសនាំចូល ។

## ជំពូកទី ១៥
## ទោសប្បញ្ញត្តិ

មាត្រា ៦២.-

សេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម អាចជាកម្មវត្ថុនៃការប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ដោយភាគីជំទាស់ណាមួយ ហើយបណ្តឹងតវ៉ានេះត្រូវធ្វើក្នុង

# ២. អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ឆ្នាំ២០០៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦/៩៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១. – គោលបំណង**

អនុក្រឹត្យនេះមានគោលបំណងកំណត់ នីតិវិធីនៃការចុះបញ្ជីម៉ាក ការបដិសេធ ភ្នាក់ងារតំណាង ការប្រកាសសិទ្ធិជាអាទិភាព ការលុបម៉ាកចេញពីបញ្ជី និងវិធានការតាមមាត់ច្រកព្រំដែន សំដៅអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២. – និយមន័យ**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ។

## ជំពូកទី ២

## លក្ខខណ្ឌទូទៅ នៃការស្នើសុំចុះបញ្ជីម៉ាក

**មាត្រា ៣. – គំរូពាក្យស្នើសុំ**

គំរូពាក្យស្នើសុំ ដែលបោះពុម្ពរួចត្រូវចែកជូន ដល់អ្នកដាក់ពាក្យស្នើសុំដោយឥតគិតថ្លៃ ដោយមន្ត្រីកាន់កាប់បញ្ជី ។

គំរូពាក្យស្នើសុំ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៤. – ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ និងការបកប្រែ**

តាមការតម្រូវនៃច្បាប់ ឬអនុក្រឹត្យនេះ ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ។ ឯកសារណាមួយ ដែលប្រើប្រាស់អមភ្ជាប់ជាមួយពាក្យស្នើសុំ ដែលបង្កើតជាផ្នែកមួយ នៃពាក្យស្នើសុំនោះ ឬ ឯកសារដែលបានដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ដែលប្រើប្រាស់ភាសាណាមួយ ក្រៅពីភាសាខ្មែរ ឬ ភាសាអង់គ្លេស ត្រូវភ្ជាប់មកជាមួយ នូវការបកប្រែជាភាសាខ្មែរ ឬ ភាសាអង់គ្លេស ។

**មាត្រា ៥. – ការបញ្ជាក់ឈ្មោះ អាសយដ្ឋាន សញ្ជាតិ និង និវេសនដ្ឋាន របស់អ្នកដាក់ពាក្យស្នើសុំ**

១-ឈ្មោះរបស់រូបវន្តបុគ្គល ត្រូវបញ្ជាក់ដោយនាមត្រកូល , និងនាមខ្លួនរបស់បុគ្គលនោះ ឈ្មោះនីតិបុគ្គល ត្រូវបញ្ជាក់ដោយឈ្មោះពេញលេញ ជាផ្លូវការរបស់នីតិបុគ្គលនោះ ។

២-អាសយដ្ឋានរបស់អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ ដើម្បីបំពេញតម្រូវការជាធម្មតាសម្រាប់សម្រួលដល់ការបញ្ជូនតាមប្រៃសណីយ៍ ។ ក្នុងករណីណាក៏ដោយ អាសយដ្ឋាន ត្រូវមានការបញ្ជាក់ផងដែរ នូវលេខផ្ទះ ទូរស័ព្ទ និង ទូរសារ ។

៣-សញ្ជាតិត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះជាពលរដ្ឋនៃរដ្ឋ ឬប្រទេសនោះ។ ចំពោះនីតិបុគ្គលត្រូវបញ្ជាក់ឈ្មោះរដ្ឋ ឬប្រទេស ដែលនីតិបុគ្គលនោះ ត្រូវបានបង្កើតឡើង តាមច្បាប់របស់រដ្ឋ ឬប្រទេសនោះ ព្រមទាំងការិយាល័យ របស់នីតិបុគ្គលនោះដែលបានចុះបញ្ជីរួច ។

៤-និវេសនដ្ឋាន ត្រូវបញ្ជាក់នូវឈ្មោះរដ្ឋ ឬប្រទេស ដែលបុគ្គលនោះមានទីលំនៅជាអចិន្ត្រៃយ៍ ។

## មាត្រា ៦. – ហត្ថលេខាក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន និង សមាគម

១-ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិមួយ ត្រូវមានឈ្មោះរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ជាឈ្មោះពេញលេញ និងត្រូវចុះហត្ថលេខា ដោយម្ចាស់ភាគហ៊ុនទាំងអស់ ឬដោយម្ចាស់ភាគហ៊ុនណាមួយ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីចុះហត្ថលេខា ដោយមានបញ្ជាក់ថា ម្ចាស់ភាគហ៊ុននោះចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនសហកម្មសិទ្ធិ ឬដោយតតិយជនណាម្នាក់ដែលមន្ត្រី កាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យចុះហត្ថលេខាលើឯកសារនោះ ។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមក្រុមហ៊ុនមូលធន ជូសមុខឱ្យនីតិបុគ្គលមួយ ត្រូវចុះហត្ថលេខាដោយអភិបាលមួយរូប ឬដោយលេខាធិការ ឬមន្ត្រីសំខាន់ដទៃទៀត របស់នីតិបុគ្គលនោះ ឬចុះហត្ថលេខាដោយតតិយជនណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា ជននោះត្រូវអនុញ្ញាតឱ្យធ្វើការចុះហត្ថលេខាលើឯកសារនោះ ហើយឯកសារនោះត្រូវមានប្រថាប់ត្រា របស់នីតិបុគ្គលនោះផង។ ឯកសារដែលត្រូវចុះហត្ថលេខា ក្នុងនាមសមាគមមួយ ត្រូវចុះហត្ថលេខាដោយបុគ្គលណាម្នាក់ ដែលមន្ត្រីកាន់កាប់បញ្ជីទទួលស្គាល់ថា បុគ្គលនោះបានទទួលសិទ្ធិស្របច្បាប់ ដើម្បីចុះហត្ថលេខា ហើយត្រូវប្រថាប់ត្រារបស់សមាគមនោះផង ។

២-នៅពេលចាំបាច់ មន្ត្រីកាន់កាប់បញ្ជី អាចស្នើសុំឱ្យផ្តល់ភស្តុតាងនៃការប្រគល់សិទ្ធិ ក្នុងការចុះហត្ថលេខានោះ ។

## មាត្រា ៧. – ភ្នាក់ងារតំណាង

លិខិតប្រគល់សិទ្ធិ ដែលចាត់តាំងភ្នាក់ងារតំណាងមួយឱ្យធ្វើការដាក់ពាក្យ អាចភ្ជាប់ជាមួយនឹងពាក្យស្នើសុំចុះបញ្ជី ឬ ត្រូវប្រគល់លិខិតប្រគល់សិទ្ធិនោះ ទៅឱ្យមន្ត្រីកាន់កាប់បញ្ជី ក្នុងរយៈពេល ០២ (ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យ។ ប្រសិនបើការប្រគល់សិទ្ធិនេះ មិនត្រូវបានធ្វើឡើង

និង ធ្វើឡើងមិនសមស្របតាមមាត្រា៥៨ និង មាត្រា៥៩ នៃច្បាប់ និង មាត្រា២៨ នៃអនុក្រឹត្យនេះទេនោះ ចំណាត់ការតាមនីតិវិធីណាមួយ ក្នុងការចុះបញ្ជី នឹងមិនត្រូវធ្វើឡើងឡើយ ។

**មាត្រា ៨. - កម្រៃផ្សេងៗ**

កម្រៃផ្សេងៗ ដែលតម្រូវតាមច្បាប់ ឬតាមអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

## ជំពូកទី ៣

## នីតិវិធីនៃការចុះបញ្ជីម៉ាក ការបដិសេធការចុះបញ្ជីម៉ាក និងការលុបម៉ាកចេញពីបញ្ជី

### ផ្នែកទី ១

### ពាក្យស្នើសុំចុះបញ្ជីម៉ាក នីតិវិធីនៃការចុះបញ្ជីម៉ាក និងការបោះពុម្ពផ្សាយ

**មាត្រា ៩. - ចំណាត់ថ្នាក់នៃម៉ាក**

ក្នុងការចុះបញ្ជី និងការបោះពុម្ពផ្សាយម៉ាក មន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាម "ចំណាត់ថ្នាក់អន្តរជាតិ នៃទំនិញ និង សេវា នៃការចុះបញ្ជីម៉ាក" ដែលអនុម័តដោយកិច្ចព្រមព្រៀងទីក្រុង នីស ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៥៧ ហើយដែលចំណាត់ថ្នាក់នេះ បានធ្វើវិសោធនកម្មជាបន្តបន្ទាប់ ។

**មាត្រា ១០. - ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក**

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមួយ ត្រូវធ្វើឡើងតាមរយៈគំរូពាក្យស្នើសុំ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ។ ពាក្យស្នើសុំមួយ អាចធ្វើឡើងសម្រាប់ការស្នើសុំចុះបញ្ជីម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់មួយ ឬច្រើននៃចំណាត់ថ្នាក់អន្តរជាតិ ។

ការប្រើប្រាស់ម៉ាកពុំមែនជាលក្ខខណ្ឌដែលតម្រូវ នៅពេលដាក់ពាក្យស្នើសុំ ចុះបញ្ជីម៉ាកឡើយ ។

**មាត្រា ១១. - ការផ្តល់គំរូម៉ាក**

១-ពាក្យស្នើសុំចុះបញ្ជី ត្រូវភ្ជាប់មកជាមួយនូវគំរូម៉ាក ក្រោមរូបភាព[illegible] និងមិនរលុប ដែលមានទំហំមិនលើសពី ៨សង្ទីម៉ែត្រ គុណ ៨សង្ទីម៉ែត្រ ឬទំហំ[illegible]

ដែលបានផ្តល់ជូន នៅលើគំរូពាក្យស្នើសុំចុះបញ្ជីម៉ាក ។ គ្រប់ករណីទាំងអស់ គំរូម៉ាកត្រូវពិពណ៌នាគ្រប់ចំណុចលំអិតទាំងអស់ ដែលចំណុចលំអិតទាំងនោះ អាចនឹងត្រូវទាមទារក្នុងពេលណាមួយដែលចាំបាច់ដោយមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើ មានលក្ខខណ្ឌតម្រូវ ចំណុចលំអិតទាំងនោះ ត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំ ឬដោយភ្នាក់ងារតំណាង ដែលបានទទួលសិទ្ធិ ។

២-គំរូម៉ាកបន្ថែមចំនួន ១៥ (ដប់ប្រាំ) ទៀត ត្រូវភ្ជាប់ជាមួយនឹងគ្រប់ពាក្យស្នើសុំចុះបញ្ជីម៉ាក។ គំរូម៉ាក ដែលបិទភ្ជាប់នៅលើពាក្យស្នើសុំ និងគំរូម៉ាកបន្ថែម ត្រូវមានលក្ខណៈដូចគ្នាបេះបិទ ។

៣-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ថា គំរូម៉ាកណាមួយនៅមិនទាន់សមស្របសម្រាប់ការចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជី អាចទាមទារឱ្យផ្តល់គំរូម៉ាកមួយទៀត ដែលសមស្រប ដើម្បីជំនួសគំរូចាស់ ។

៤-នៅពេលដែលគំរូ ឬការចម្លងឡើងវិញផ្សេងទៀត ពុំបានធ្វើឡើងតាមលក្ខណៈ ដូចបានពោលខាងលើនោះ គំរូម៉ាក ឬរូបភាពចម្លងនៃម៉ាក អាចនឹងត្រូវផ្តល់ក្រោមរូបភាព ជាទំហំពេញលេញ ឬ បំព្រួញ និងតាមទម្រង់មួយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថាសមស្រប ។

## មាត្រា ១២. – សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាក

តាមការតម្រូវរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងករណីដែលម៉ាកមួយ មានពាក្យមួយព្យាង្គ ឬច្រើនព្យាង្គ ជាអក្សរ ក្រៅពីអក្សរខ្មែរ ឬអក្សរឡាតាំង ការបំពេញពាក្យស្នើសុំតាមគំរូ ដូចមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ហើយនិងការផ្តល់នូវគំរូម៉ាកបន្ថែម ត្រូវភ្ជាប់មកជាមួយផងដែរនូវការសរសេរ សម្លេងអាន និងការបកប្រែអត្ថន័យរបស់ម៉ាកនោះ ឱ្យបានពេញលេញតាមពាក្យមួយព្យាង្គៗ ដោយបញ្ជាក់នូវភាសា ដែលពាក្យនីមួយៗនោះ ត្រូវបានប្រើប្រាស់ ។

## មាត្រា ១៣. – ការប្រកាសសិទ្ធិអាទិភាព និងការបកប្រែពាក្យស្នើសុំលើកដំបូង

១-អនុលោមតាមមាត្រា៦ នៃច្បាប់ ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចអមមកជាមួយសេចក្តីប្រកាសទាមទារសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំលើកដំបូង នៅក្រៅប្រទេស ក្នុងកម្រិតជាតិ ឬកម្រិតតំបន់ ដែលបានធ្វើឡើងដោយអ្នកដាក់ពាក្យស្នើសុំ ឬអ្នកទទួលសិទ្ធិ ដូចមានចែងក្នុងអនុសញ្ញាទីក្រុង ប៉ារីស ដែលផ្តល់សិទ្ធិអាទិភាពនៅក្នុងរដ្ឋណាមួយ ជាសមាជិករបស់អនុសញ្ញានោះ ។ ក្នុងករណីនេះមន្ត្រីកាន់កាប់បញ្ជី អាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ នូវច្បាប់ចម្លង នៃពាក្យស្នើសុំចុះបញ្ជីលើកដំបូងមួយច្បាប់ ដែលបានបញ្ជាក់ថា ត្រឹមត្រូវពីការិយាល័យទទួលពាក្យស្នើសុំចុះបញ្ជីនោះ ក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌ (៣) នៃមាត្រានេះ ។ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬអ្នកទទួលសិទ្ធិរបស់គាត់ អាចធ្វើការទាមទារសិទ្ធិអាទិភាព ពីការចុះបញ្ជីលើកដំបូង ដែលបានធ្វើឡើងនៅក្នុងរដ្ឋ ឬប្រទេសណាមួយ ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ ។

២-ការប្រកាសអំពីសិទ្ធិអាទិភាព ដែលធ្វើឡើងតាមមាត្រា៦ នៃច្បាប់ និង មាត្រា១៣ កថាខ័ណ្ឌ (១) នៃអនុក្រឹត្យនេះ ត្រូវបញ្ជាក់នូវ ៖

ក- កាលបរិច្ឆេទដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង

ខ- លេខដាក់ពាក្យនៃការស្នើសុំចុះបញ្ជីម៉ាកលើកដំបូង អនុលោមតាមកថាខ័ណ្ឌ (៣) ខាងក្រោមនៃមាត្រានេះ

គ- ឈ្មោះប្រទេស ដែលអ្នកស្នើសុំចុះបញ្ជីម៉ាក បានដាក់ពាក្យលើកដំបូង ឬ ក្នុងករណីដែលពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ទៅជាការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្រោមរូបភាពតំបន់ ឬ អន្តរជាតិ។ អ្នកដាក់ពាក្យស្នើសុំ ត្រូវបញ្ជាក់ឈ្មោះការិយាល័យ និង ឈ្មោះប្រទេស ដែលពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ ត្រូវដាក់ ។

៣-ប្រសិនបើនៅពេលដាក់សេចក្តីប្រកាស ដែលបានចែងក្នុងកថាខ័ណ្ឌ (១) និង (២) ខាងលើ ហើយអ្នកដាក់ពាក្យពុំទាន់ដឹងលេខដាក់ពាក្យ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូងទេ អ្នកដាក់ពាក្យស្នើសុំ ត្រូវផ្តល់លេខដាក់ពាក្យនោះ ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានប្រកាសសុំសិទ្ធិអាទិភាពនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំផ្តល់ នូវភស្តុតាងគ្រប់គ្រាន់ ដែលបង្ហាញថា ការដែលគាត់ពុំអាចអនុវត្តបានត្រឹមត្រូវ តាមកាលកំណត់ខាងលើ ដោយសារមានកាលៈទេសៈជាឧបសគ្គមួយចំនួន ហួសពីសមត្ថភាពគ្រប់គ្រងរបស់គាត់ មន្ត្រីកាន់កាប់បញ្ជីអាចពន្យារពេល ០៣ (បី) ខែទៀតចំពោះកាលកំណត់ នៃការផ្តល់នូវលេខដាក់ពាក្យ ដែលមានចែងក្នុងកថាខ័ណ្ឌនេះ ។

៤-ក្នុងករណីមានការស្នើសុំសិទ្ធិអាទិភាព នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ចំនួន ០២ (ពីរ) ឬ ច្រើនជាង ដែលអនុលោមតាមកថាខ័ណ្ឌ (១) ខាងលើ ការបញ្ជាក់អំពីការដាក់ពាក្យស្នើសុំសិទ្ធិអាទិភាព អាចបញ្ចូល ក្នុងប្រកាសទាមទារសិទ្ធិអាទិភាព តែមួយបាន ។

៥-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីរកឃើញថា លក្ខខណ្ឌតម្រូវទាំងឡាយតាមមាត្រា៦ នៃច្បាប់ និង កថាខ័ណ្ឌ (១) (២) និង (៣) ខាងលើ មិនត្រូវបំពេញគ្រប់គ្រាន់ទេនោះ ការប្រកាសទាមទារសិទ្ធិអាទិភាព នឹងមិនត្រូវចាត់ទុកថា បានធ្វើឡើងឡើយ ។

៦-មុនពេលធ្វើការចុះបញ្ជីម៉ាក អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចធ្វើការកែតម្រូវការប្រកាសទាមទារ សិទ្ធិអាទិភាពរបស់ខ្លួន ដែលធ្វើឡើងតាមកថាខ័ណ្ឌនានាខាងលើបាន ។

**មាត្រា ១៤. – ច្បាប់ចម្លងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានអនុញ្ញាតរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទនៃការទាមទាររបស់មន្ត្រីកាន់កាប់បញ្ជី ដើម្បីផ្តល់នូវច្បាប់ចម្លង នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកលើកដំបូង ដោយមានការបញ្ជាក់នូវភាពត្រឹមត្រូវ ។

**មាត្រា ១៥. – ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក**

ការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខា ដោយអ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងស្របច្បាប់ ហើយត្រូវដាក់ជូនទៅមន្ត្រីកាន់កាប់បញ្ជី ។

កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នឹងមិនត្រូវផ្តល់ជូនវិញទេ ក្នុងករណីដែលមានការដកពាក្យស្នើសុំចុះបញ្ជីម៉ាក ទៅវិញនោះ ។

**មាត្រា ១៦. – ការកត់ត្រាពាក្យស្នើសុំចុះបញ្ជីម៉ាក និងកាលបរិច្ឆេទដាក់ពាក្យស្នើសុំ**

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវកត់ត្រានៅលើសំណុំឯកសារ នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗនូវកាលបរិច្ឆេទពិតប្រាកដ និង លេខរៀងដាក់ពាក្យនៃពាក្យស្នើសុំចុះបញ្ជី ដោយមានសរសេរអក្សរ KH ភ្ជាប់នឹងរបាផ្ដេក ហើយសរសេរលេខចំនួន ០៥ (ប្រាំ) ខ្ទង់យ៉ាងតិច ដែលកំណត់តាមលំដាប់លំដោយបន្តបន្ទាប់ ព្រមទាំងលេខចុងក្រោយពីរខ្ទង់នៃឆ្នាំ ដែលទទួលបានសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ ។ នៅពេលដែលមានការកែតម្រូវណាមួយ ឬនៅពេលដែលទទួលបានឯកសារដទៃទៀត ដែលដាក់ជូនក្នុងកាលបរិច្ឆេទខុសគ្នានោះ មន្ត្រីកាន់កាប់បញ្ជីត្រូវកត់ត្រាកាលបរិច្ឆេទជាក់ស្តែង នៃការទទួលឯកសារទាំងនោះ ។

២-លេខដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ត្រូវយកមកប្រើក្នុងគ្រប់ទំនាក់ទំនង ជាបន្តបន្ទាប់ ដែលពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីម៉ាក ។

៣-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នៅពេលពាក្យស្នើសុំចុះបញ្ជី បំពេញបាននូវព័ត៌មានគ្រប់គ្រាន់ និងត្រឹមត្រូវដូចខាងក្រោម ៖

ក- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ខ- អាសយដ្ឋានទំនាក់ទំនង

គ- គំរូម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- យថាប្រភេទរបស់ទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ

ង- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលតម្រូវសម្រាប់ចំណាត់ថ្នាក់នីមួយៗ នៃទំនិញ ឬសេវា ដែលស្នើសុំចុះបញ្ជីម៉ាក ។

៤-មន្ត្រីកាន់កាប់បញ្ជី ត្រូវចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នូវលេខរៀង និងកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំ ។

**មាត្រា ១៧.- ការច្រានចោលការដាក់ពាក្យស្នើសុំចុះបញ្ជី ឬការយល់ព្រមទទួលដោយមានលក្ខខណ្ឌចំពោះការចុះបញ្ជី និងសវនាការ**

១-នៅពេលពិនិត្យសំណុំឯកសារ ពាក្យស្នើសុំចុះបញ្ជីម៉ាក ដែលធ្វើឡើងតាមមាត្រា៨ (ក) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីសម្រេចច្រានចោល ពាក្យស្នើសុំចុះបញ្ជីម៉ាកណាមួយ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ អំពីការច្រានចោលនោះ ទៅអ្នកដាក់ពាក្យស្នើសុំដោយភ្ជាប់នូវព័ត៌មានលំអិតទាំងអស់ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយស្នើឱ្យអ្នកដាក់ពាក្យស្នើសុំធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងឆ្លើយតបទៅមន្ត្រីកាន់កាប់បញ្ជី ជាលាយលក្ខណ៍អក្សរ ឬធ្វើការដាក់ពាក្យស្នើសុំធ្វើសវនាការ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីពេលទទួលបានសេចក្តីជូនដំណឹងអំពី ការច្រានចោលនោះ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនបានអនុវត្តទៅតាមកាលកំណត់ នៃការជូនដំណឹងនេះទេ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះ នឹងត្រូវចាត់ទុកថា បានដកពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

២-នៅពេលពិនិត្យខ្លឹមសារម៉ាក ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ដោយធ្វើឡើងតាមមាត្រា៨ (ខ) នៃច្បាប់ ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រមទទួលយកពាក្យស្នើសុំ ក្នុងលក្ខខណ្ឌនៃការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ លើចំណុចណាមួយរបស់ម៉ាក ឬការកម្រិតកំណត់សិទ្ធិ ឬ លក្ខខណ្ឌផ្សេងៗទៀត មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងអំពីការសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ទៅឱ្យអ្នកដាក់ពាក្យស្នើសុំ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មិនឯកភាពចំពោះការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក អាចដាក់ពាក្យស្នើសុំធ្វើសវនាការ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួន ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹងពីមន្ត្រីកាន់កាប់បញ្ជី ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកឯកភាព ទៅនឹងសំណូមពរឱ្យធ្វើការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិ ឬការកម្រិតកំណត់ នៃសិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីវិញ ជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួន ទៅតាមសេចក្តីជូនដំណឹងខាងលើ ។ ប្រសិនបើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក មិនធ្វើការឆ្លើយតបតាមកាលកំណត់ និងតាមវិធីណាមួយក្នុងចំណោមវិធីខាងលើ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវចាត់ទុកថា បានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួន ។

៣-ការស្នើសុំធ្វើសវនាការមួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្ញើជូនទៅមន្ត្រីកាន់កាប់បញ្ជី។ នៅពេលដែលទទួលបានពាក្យស្នើសុំនេះ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ០១ (មួយ)ខែ មុនកាលបរិច្ឆេទ ដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវអញ្ជើញមកចូលរួមក្នុងសវនាការ ។

## មាត្រា ១៨. - ការបដិសេធពាក្យស្នើសុំចុះបញ្ជី ឬ ការយល់ព្រម ដោយមានលក្ខខណ្ឌរបស់មន្ត្រីកាន់កាប់បញ្ជី ដែលអ្នកដាក់ពាក្យស្នើសុំធ្វើការជំទាស់

១-បន្ទាប់ពីសវនាការ ឬបន្ទាប់ពីការពិនិត្យពិចារណា លើការស្នើសុំកែតម្រូវ ឬការផ្តល់យោបល់ជាលាយលក្ខណ៍អក្សរ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធការចុះបញ្ជី ឬយល់ព្រមចុះបញ្ជី ដោយមានលក្ខខណ្ឌឱ្យមានការកែតម្រូវ ការកែសម្រួល ការលះបង់ទាមទារសិទ្ធិ ឬការកម្រិតកំណត់សិទ្ធិ ឬលក្ខខណ្ឌផ្សេងៗទៀត ហើយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី នៅតែមិនយល់ព្រមទៅនឹងការច្រានចោល ឬការយល់ព្រមទទួលចុះបញ្ជីជូនដោយមានលក្ខខណ្ឌ មន្ត្រីកាន់កាប់បញ្ជី ត្រូវបដិសេធជាលាយលក្ខណ៍អក្សរ ទៅអ្នកដាក់ពាក្យស្នើសុំ អំពីសេចក្តីសម្រេចរបស់ខ្លួន ។ ក្នុងរយៈពេល ០១ (មួយ) ខែ ចាប់ពីកាលបរិច្ឆេទនៃការផ្តល់សេចក្តីជូនដំណឹងនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី អាចស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជី ធ្វើការបញ្ជាក់ជាលាយលក្ខណ៍អក្សរ អំពីមូលហេតុដែលនាំឱ្យឈានដល់សេចក្តីសម្រេចរបស់ខ្លួន ព្រមទាំងឯកសារយោងទាំងឡាយ ដែលប្រើប្រាស់នៅក្នុងការធ្វើសេចក្តីសម្រេចនេះ ។

២-អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មានសិទ្ធិប្តឹងតវ៉ា អំពីការបដិសេធមិនព្រមចុះបញ្ជី របស់មន្ត្រីកាន់កាប់បញ្ជី ទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្ម ឬទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី ។

៣-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា នៃក្រសួងពាណិជ្ជកម្មទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច របស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា។

## មាត្រា ១៩. - ការយល់ព្រមចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជី ការចុះបញ្ជីម៉ាក ការបោះពុម្ពផ្សាយ និង ការចេញវិញ្ញាបនបត្រ

១-ប្រសិនបើ មន្ត្រីកាន់កាប់បញ្ជីយល់ព្រម ចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ដោយមាន ឬ គ្មានលក្ខខណ្ឌ ឬការកម្រិតកំណត់ណាមួយ ដែលលក្ខខណ្ឌ និងការកំណត់ទាំងនោះ ត្រូវបានយល់ព្រម ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រនៃការ

ចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

២-មន្ត្រីកាន់កាប់បញ្ជី ត្រូវផ្តល់នូវលេខរៀងមួយតាមលំដាប់លំដោយ នៃការចុះបញ្ជីម៉ាកនៅលើវិញ្ញាបនបត្រចុះបញ្ជី ។

៣-ការចុះបញ្ជីម៉ាកមួយត្រូវមាន ៖

ក- គំរូម៉ាក ដែលត្រូវបានចុះបញ្ជី

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលស្នើសុំចុះបញ្ជី

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ( ប្រសិនបើមាន)

ង- កាលបរិច្ឆេទនៃការដាក់ពាក្យ និងកាលបរិច្ឆេទនៃការចុះបញ្ជី

ច- ប្រសិនបើសិទ្ធិអាទិភាពត្រូវបានទាមទារ ហើយការទាមទារសិទ្ធិនោះត្រូវបានយល់ព្រម ត្រូវបញ្ជាក់ឈ្មោះ រដ្ឋ ឬប្រទេស និងលេខដាក់ពាក្យដែលបានដាក់ពាក្យស្នើសុំលើកដំបូង។

ឆ- ចំណាត់ថ្នាក់ និង ទំនិញ ឬសេវាដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកមួយ ដែលបានកំណត់ក្នុងកថាខ័ណ្ឌ (១) ខាងលើ ត្រូវមានព័ត៌មានមួយចំនួនដូចតទៅ ៖

ក- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និង កាលបរិច្ឆេទនៃសិទ្ធិអាទិភាព ( ប្រសិន បើមាន)

ខ- គំរូម៉ាក ដែលបានចុះបញ្ជី

គ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

ឃ- ចំណាត់ថ្នាក់ និង ទំនិញ ឬ សេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានបញ្ជាក់អំពីចំណាត់ថ្នាក់នៃទំនិញ ឬសេវានោះ ស្របតាមចំណាត់ថ្នាក់អន្តរជាតិ

ង- ឈ្មោះ និងអាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជី

ច- ឈ្មោះ និងអាសយដ្ឋានរបស់ភ្នាក់ងារតំណាង ( ប្រសិនបើមាន) ។

**មាត្រា ២០. - បណ្តឹងជំទាស់**

១-ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទ នៃការបោះពុម្ពផ្សាយ ដូចមាន ចែងក្នុងមាត្រា១៩នៃអនុក្រឹត្យនេះរាល់លិខិតជំទាស់របស់ជនណា ដែលមានការពាក់ព័ន្ធនឹងការ ចុះបញ្ជីម៉ាក តាមមាត្រា១០ (គ) នៃច្បាប់ ត្រូវធ្វើឡើងតាមគំរូដែលកំណត់ ដោយក្រសួងពាណិជ្ជកម្ម ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

២-អនុលោមតាមមាត្រា១០ (ង) នៃច្បាប់ ក្នុងរយៈពេល ៩០ (កៅសិប ) ថ្ងៃ គិតពីកាល បរិច្ឆេទ នៃការជូនដំណឹងពីបណ្តឹងជំទាស់ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ត្រូវផ្តល់អំណះអំណាងជាចម្លើយ តបវិញ ជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីហេតុផលជាមូលដ្ឋាន ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក របស់ខ្លួន និងមានភ្ជាប់មកជាមួយនូវឯកសារគាំទ្រនានាជាភស្តុតាងផង ។

**មាត្រា ២១. - សេចក្តីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក និង ភស្តុតាង**

១-ដើម្បីរក្សាសុពលភាពនៃការចុះបញ្ជីម៉ាក ឬការចុះបញ្ជីម៉ាកសាឡើងវិញ ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬមិនបានប្រើប្រាស់ម៉ាកក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីម៉ាក ។

២-នៅពេលម៉ាក ត្រូវបានចុះបញ្ជីសាឡើងវិញ ម្ចាស់ម៉ាកត្រូវប្រកាសអំពីការប្រើប្រាស់ម៉ាក ឬ មិនបានប្រើប្រាស់ម៉ាករបស់ខ្លួន ក្នុងរយៈពេល ០១ (មួយ) ឆ្នាំ បន្ទាប់ពីខួបលើកទី ០៥ (ប្រាំ) នៃកាលបរិច្ឆេទចុះបញ្ជីសាឡើងវិញ ។

៣-សេចក្តីប្រកាសអំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើឡើងតាមគំរូដែលបាន កំណត់ ដោយក្រសួងពាណិជ្ជកម្ម និងត្រូវបង់កម្រៃតាមប្រកាសអន្តរក្រសួង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ។

៤-ម៉ាកដែលបានចុះបញ្ជីរួច នឹងត្រូវលុបចេញពីបញ្ជីវិញ ក្នុងករណីដែលម្ចាស់ម៉ាក ឬភ្នាក់ងារ តំណាងខកខានមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកនោះ ដូចដែលបានកំណត់ក្នុង កថាខណ្ឌ (១) ខាងលើ ។

**មាត្រា ២២. - ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ**

១-ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ តាមមាត្រា១២ (ខ) នៃច្បាប់ អាចធ្វើឡើង ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ មុនពេលផុតសុពលភាព នៃការចុះបញ្ជីម៉ាក ហើយពាក្យស្នើសុំចុះបញ្ជី សាជាថ្មីឡើងវិញនេះ ត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ឬដោយភ្នាក់ងារតំណាង របស់ខ្លួន ។

២-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ អាចធ្វើឡើងបាន ដោយមានការទូទាត់កម្រៃនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ដែលត្រូវធ្វើនៅក្នុងរយៈពេលកំណត់ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ (១) ខាងលើ ឬ ធ្វើឡើងក្នុងរយៈពេលនៃការអនុគ្រោះ ដែលអនុញ្ញាតដោយមាត្រា១២ (ឃ) នៃច្បាប់ ។

៣-ការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ត្រូវតែកត់ត្រានៅក្នុងបញ្ជីម៉ាក ហើយត្រូវបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៤-មន្ត្រីកាន់កាប់បញ្ជីត្រូវចេញវិញ្ញាបនបត្រ នៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ ទៅឱ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច ហើយវិញ្ញាបនបត្រនោះត្រូវមានព័ត៌មានដូចខាងក្រោម :

ក- លេខចុះបញ្ជីដើមរបស់ម៉ាក

ខ- គំរូម៉ាក

គ- កាលបរិច្ឆេទនៃការចុះបញ្ជីម៉ាកសាជាថ្មីឡើងវិញ និងកាលបរិច្ឆេទផុតកំណត់

ឃ- ឈ្មោះ និង អាសយដ្ឋានរបស់ម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួច

ង- ឈ្មោះ និង អាសយដ្ឋានរបស់ភ្នាក់ងារតំណាង (ប្រសិនមាន)

ច- ទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃការចុះបញ្ជីម៉ាក ដោយមានការបញ្ជាក់អំពីចំណាត់ថ្នាក់ នៃទំនិញ ឬសេវាស្របតាមចំណាត់ថ្នាក់អន្តរជាតិ ។

## ផ្នែកទី ២
## ម៉ាកសមូហភាព និងមោឃភាពនៃការចុះបញ្ជី

### មាត្រា ២៣. - ម៉ាកសមូហភាព

មាត្រា៩ រហូតដល់មាត្រា២២ នៃអនុក្រឹត្យនេះ ត្រូវយកមកអនុវត្តចំពោះម៉ាកសមូហភាព តាមលក្ខខណ្ឌតម្រូវមួយចំនួនដូចខាងក្រោម ៖

១-ការទទួលយកពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព លុះត្រាតែនៅក្នុងពាក្យស្នើសុំចុះបញ្ជីនោះត្រូវកំណត់ថា ជាម៉ាកសមូហភាព និងមានភ្ជាប់មកជាមួយ នូវច្បាប់ចម្លងនៃបទបញ្ជារួមគ្រប់គ្រងការប្រើប្រាស់ម៉ាកនោះមួយច្បាប់ ដោយមានការបញ្ជាក់ត្រឹមត្រូវ ពីអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ។ ការបញ្ជាក់ ដែលធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក នោះពុំចាំបាច់តម្រូវឱ្យមានការធ្វើនីត្យានុកូលកម្ម ណាមួយឡើយ ។

២-បទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវកំណត់[illegible] គុណភាពរបស់ទំនិញ ឬសេវាដែលម៉ាកសមូហភាពនោះ ត្រូវជ្រើសរើសយកទៅប្រើ[illegible]

លក្ខខណ្ឌទាំងឡាយ ដែលបុគ្គលប្រើប្រាស់ម៉ាកសមូហភាពនោះ ត្រូវធ្វើតាម ។ បទបញ្ជានោះត្រូវផ្តល់នូវការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ចំពោះការប្រើប្រាស់ម៉ាកសមូហភាព ដោយស្របទៅតាមប្រការនានានៃបទបញ្ជានោះ ហើយត្រូវកំណត់នូវទណ្ឌកម្មសមល្មម ចំពោះរាល់ការប្រើប្រាស់ដែលផ្ទុយទៅនឹងបទបញ្ជានោះ ។

៣-ច្បាប់ចម្លងមួយច្បាប់ នៃបទបញ្ជារួមស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ត្រូវភ្ជាប់បន្ថែមមកជាមួយនឹងការចុះបញ្ជីម៉ាកសមូហភាពមួយ ។

៤-ការបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកសមូហភាព តាមមាត្រា១៩ (១) នៃអនុក្រឹត្យនេះត្រូវរួមបញ្ចូលសេចក្តីសង្ខេបនៃបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ដែលបានភ្ជាប់បន្ថែមទៅនឹងការចុះបញ្ជីម៉ាកសមូហភាព ។

៥-សេចក្តីជូនដំណឹងអំពីការផ្លាស់ប្តូរព័ត៌មាននានា ដែលប៉ះពាល់ដល់បទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកសមូហភាព ចាំបាច់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

៦-គ្រប់សេចក្តីជូនដំណឹង អំពីការផ្លាស់ប្តូរព័ត៌មានបែបនេះ ចាំបាច់ត្រូវកត់ត្រានៅក្នុងបញ្ជីម៉ាក ។ រាល់ការផ្លាស់ប្តូរព័ត៌មានទាំងឡាយណា នៅក្នុងបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាក នឹងពុំមានប្រសិទ្ធភាពជាធរមានទេ រហូតទាល់តែការកត់ត្រានេះត្រូវបានធ្វើឡើង ។ សេចក្តីសង្ខេបអំពីការផ្លាស់ប្តូរព័ត៌មាន ដែលបានកត់ត្រារួច ចាំបាច់ត្រូវបោះពុម្ពផ្សាយជាសាធារណៈ ។

៧-ក្នុងគោលបំណងនៃការប្រើប្រាស់ម៉ាកសមូហភាព ដែលទាក់ទងនឹងមាត្រា១៥ និង មាត្រា១៦ នៃច្បាប់ ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជីរួច អាចប្រើប្រាស់ម៉ាកសមូហភាពនោះ ដោយខ្លួនឯងបាន លុះត្រាតែម៉ាកនោះ ត្រូវបានប្រើប្រាស់ផងដែរដោយបុគ្គលដទៃទៀត ដែលបានទទួលសិទ្ធិតាមបទបញ្ជារួម ស្តីពីការគ្រប់គ្រងការប្រើប្រាស់ម៉ាកនេះ ។ ការប្រើប្រាស់ម៉ាកសមូហភាព ដោយបុគ្គលទាំងនោះ ត្រូវបានចាត់ទុកថា ម៉ាកនោះបានប្រើប្រាស់ ដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ។

**មាត្រា២៨.- មោឃភាព និង ការលុបម៉ាកចេញពីបញ្ជីដោយផ្អែកលើការមិនបានប្រើប្រាស់**

១-អនុលោមតាមមាត្រា១០ (គ) មាត្រា១៣ និង មាត្រា១៥ នៃច្បាប់ ភាគីដែលមានផលប្រយោជន៍ មានសិទ្ធិដាក់ពាក្យស្នើសុំមោឃភាព ចំពោះការចុះបញ្ជីម៉ាក ទោះផុតកំណត់រយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការក៏ដោយ ។

២-អនុលោមតាមមាត្រា១៣ (ខ) នៃច្បាប់ មន្ត្រីកាន់កាប់បញ្ជី មានសិទ្ធិលុបម៉ាកចេញពីបញ្ជី នៅពេលម្ចាស់ម៉ាកដែលបានចុះបញ្ជី មិនបានបំពេញតាមលក្ខខណ្ឌណាមួយ នៃមាត្រា២ [illegible] និង មាត្រា៤ នៃច្បាប់ ។

៣-អនុលោមតាមមាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយត្រូវបានលុបចេញពីបញ្ជី នៅពេលម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិបានប្រើប្រាស់ម៉ាកនោះ ខុសទម្រង់ដើមដែលបានចុះបញ្ជី ហើយរំលោភបំពានទៅលើម៉ាករបស់អ្នកផ្សេង ដែលបានចុះបញ្ជីរួច ។

៤-អនុលោមតាមមាត្រា៤ (ង) មាត្រា១៤ (ង) មាត្រា២២ មាត្រា២៣ និង មាត្រា២៨ នៃច្បាប់ ម៉ាកមួយ ត្រូវបានលុបចេញពីបញ្ជីនៅពេលម្ចាស់ម៉ាកនោះ ឬអ្នកទទួលសិទ្ធិបានបន្ថែមស្លាកសញ្ញា ដូច ឬស្រដៀង ធ្វើឱ្យកន្លំច្រឡំ ទៅនឹងស្លាកសញ្ញាល្បីរបស់អ្នកផ្សេង ដែលបានប្រើប្រាស់មុន ។

៥-ការលុបម៉ាកមួយចេញពីបញ្ជី ចាំបាច់ត្រូវតែបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ ។

៦-មានតែការលុបម៉ាកចេញពីបញ្ជី ដោយផ្អែកលើមូលហេតុមិនបានប្រកាស អំពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាកតែម្យ៉ាងគត់ ដែលត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីឡើងវិញ តាមការស្នើសុំរបស់ម្ចាស់ម៉ាក ឬភ្នាក់ងារតំណាងក្នុងរយៈពេលមិនលើសពី ៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃសម្រេចលុប ។

៧-ក្រោយពីមានសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជី អំពីការផ្តល់មោឃភាពនៃការចុះបញ្ជី ឬ រក្សាទុកការចុះបញ្ជី ឬមួយសម្រេចឱ្យកែតម្រូវម៉ាកដែលបានចុះបញ្ជី បើភាគីណាមួយមិនយល់ព្រមនឹង សេចក្តីសម្រេចនោះ អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

៨-អនុលោមតាមមាត្រា៦២ នៃច្បាប់ ភាគីមានផលប្រយោជន៍ មានសិទ្ធិប្តឹងតវ៉ា អំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា របស់ក្រសួងពាណិជ្ជកម្ម ទៅតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច ។

៩-ការបង្កើតក្រុមប្រឹក្សាប្តឹងតវ៉ា សមាសភាព និង ដែនអំណាចនៃក្រុមប្រឹក្សាប្តឹងតវ៉ា និង នីតិវិធីដោះស្រាយទំនាស់នឹងត្រូវកំណត់ ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

១០-អនុលោមតាមមាត្រា៦២ នៃច្បាប់ នៅពេលតុលាការសម្រេចលើបណ្តឹងតវ៉ា តម្រូវឱ្យលុបម៉ាកចេញពីបញ្ជី ឬរក្សាទុក ឬកែតម្រូវម៉ាក មន្ត្រីកាន់កាប់បញ្ជី ត្រូវអនុវត្តតាមសេចក្តីសម្រេចនោះ ។

## ផ្នែកទី ៣

## ការកំណត់បែបបទរដ្ឋបាលសម្រួលដល់ការចុះបញ្ជី និងការដោះស្រាយ វិវាទ ក្នុងវិស័យការផ្ទេរសិទ្ធិ

**មាត្រា ២៥.- អាសយដ្ឋានសម្រាប់ទាក់ទង**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ចាំបាច់ត្រូវផ្តល់មកឱ្យមន្ត្រីកាន់កាប់បញ្ជី នូវអាសយដ្ឋានសម្រាប់ ទាក់ទងនៅក្នុងប្រទេសកម្ពុជា ដែលប្រើប្រាស់ក្នុងគោលបំណងនៃការដាក់ពាក្យ ។

ជនទាំងឡាយណា ដែលពាក់ព័ន្ធនឹងកិច្ចការនានាទាក់ទងនឹងម៉ាក ត្រូវផ្តល់អាសយដ្ឋានទាក់ទងក្នុងប្រទេសកម្ពុជាដល់មន្ត្រីកាន់កាប់បញ្ជី ។

**មាត្រា ២៦. – ការផ្លាស់ប្តូរឈ្មោះ អាសយដ្ឋាន ឬ អាសយដ្ឋានសម្រាប់ទាក់ទង**

១-ការស្នើសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ចំពោះពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីរួច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-មុនពេលអនុវត្តតាមសំណើនៃការសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬ អាសយដ្ឋាន ទាក់ទង មន្ត្រីកាន់កាប់បញ្ជីត្រូវទាមទាររកភស្តុតាងនៃការសុំប្តូរនោះ ។

៣-ប្រសិនបើសំណើសុំប្តូរឈ្មោះ សញ្ជាតិ អាសយដ្ឋាន ឬអាសយដ្ឋានសម្រាប់ទាក់ទង ត្រូវបានអនុញ្ញាត មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការកែតម្រូវ ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬកត់ត្រាក្នុងបញ្ជីដើមនៃម៉ាក និង កត់ត្រាក្នុងបញ្ជីម៉ាក ។

**មាត្រា ២៧. – ការប្តូរម្ចាស់កម្មសិទ្ធិ កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ**

១-សំណើសុំប្តូរម្ចាស់កម្មសិទ្ធិ ដែលអនុញ្ញាតដោយច្បាប់តាមមាត្រា៤៨ ត្រូវធ្វើឡើងតាមគំរូដែលមានចែងក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម រួចផ្ញើជូនមកមន្ត្រីកាន់កាប់បញ្ជី ដោយត្រូវទូទាត់កម្រៃ ដូចមានចែងក្នុងប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

២-ការបោះពុម្ពផ្សាយជាសាធារណៈ អំពីការប្តូរម្ចាស់កម្មសិទ្ធិ ត្រូវបញ្ជាក់នូវព័ត៌មានដូចតទៅ ៖

ក- ម៉ាក ដែលពាក់ព័ន្ធនឹងការប្តូរម្ចាស់កម្មសិទ្ធិនេះ

ខ- លេខដាក់ពាក្យ និង លេខចុះបញ្ជី

គ- កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក កាលបរិច្ឆេទទាមទារសិទ្ធិអាទិភាព ( ប្រសិនបើមាន) និងកាលបរិច្ឆេទនៃការចុះបញ្ជីម៉ាក

ឃ- ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកដើម និង ឈ្មោះ អាសយដ្ឋានម្ចាស់ម៉ាកថ្មី ដែលពាក់ព័ន្ធ នឹងការប្តូរម្ចាស់កម្មសិទ្ធិនេះ

ង- ថ្ងៃ ខែ ឆ្នាំ ប្តូរឈ្មោះម្ចាស់កម្មសិទ្ធិ ។

៣-កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ដែលបានដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដើម្បីស្នើសុំធ្វើការកត់ត្រាតាមមាត្រា៥២ នៃច្បាប់ ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រថតចម្លងមួយច្បាប់ នៃវិញ្ញាបនបត្រកម្មសិទ្ធិ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណច្បាប់ដើម ឬច្បាប់ចម្លង ដែលបញ្ជាក់ភាពត្រឹមត្រូវមួយច្បាប់ ។

**មាត្រា ២៨. – ការចាត់តាំងភ្នាក់ងារតំណាង អាសយដ្ឋានសម្រាប់ទាក់ទង**

ការចាត់តាំងភ្នាក់ងារតំណាងមួយ ត្រូវធ្វើឡើងដោយមានលិខិតប្រគល់សិទ្ធិ ដែលត្រូវបញ្ជាក់ភាពស្របច្បាប់ និងចុះហត្ថលេខា ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកច្រើននាក់ ការចុះហត្ថលេខាត្រូវធ្វើឡើង ដោយអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងនោះ ។ អាសយដ្ឋានរបស់ភ្នាក់ងារតំណាង ត្រូវបានចាត់ទុកថាជាអាសយដ្ឋានប្រើប្រាស់សម្រាប់ទាក់ទងរវាងបុគ្គលម្នាក់ ឬ ច្រើននាក់ដែលត្រូវបានចាត់តាំងជាភ្នាក់ងារតំណាង ហើយព័ត៌មានផ្សេងៗត្រូវផ្ញើតាមរយៈភ្នាក់ងារតំណាងនោះ ។

**មាត្រា ២៩. – ចំនួនថ្ងៃដែលពុំត្រូវរាប់បញ្ចូល**

នៅពេលដែលថ្ងៃចុងក្រោយសម្រាប់បំពេញការងារ ឬសម្រាប់ចាត់វិធានការណាមួយ ត្រូវចំថ្ងៃឈប់សម្រាក ថ្ងៃបន្ទាប់ត្រូវបានចាត់ទុកថា ស្របច្បាប់ ចំពោះការបំពេញការងារ ឬ ចាត់វិធានការ ។

**មាត្រា ៣០. – ការស្នើសុំពិនិត្យបញ្ជីម៉ាក និងការស្នើសុំដកស្រង់ព័ត៌មានពីបញ្ជីម៉ាក**

ការស្នើសុំពិគ្រោះយោបល់អំពីបញ្ជីម៉ាក ត្រូវបានអនុញ្ញាត ដោយផ្អែកតាមសំណើជាលាយលក្ខណ៍អក្សរ របស់ភាគីណាមួយដែលមានផលប្រយោជន៍ មន្ត្រីកាន់កាប់បញ្ជី ត្រូវធ្វើការថតចម្លងឯកសារក្នុងបញ្ជីម៉ាក និងឯកសារដទៃទៀត ព្រមទាំងបញ្ជាក់ភាពត្រឹមត្រូវផង ។

**មាត្រា ៣១. – ការកែតម្រូវកំហុស**

ការកែតម្រូវកំហុសតាមមាត្រាទី៥៦ នៃច្បាប់ អាចធ្វើឡើងដោយមន្ត្រីកាន់កាប់បញ្ជី នៅពេលបានទទួលសំណើជាលាយលក្ខណ៍អក្សរ ហើយដែលសំណើនោះបានបំពេញតាមលក្ខខណ្ឌទាំងឡាយ ដែលមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្រប ឬ ធ្វើឡើងតាមគំនិតផ្តួចផ្តើមផ្ទាល់របស់មន្ត្រីកាន់កាប់បញ្ជី ។ រាល់ការកែតម្រូវ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅបុគ្គលទាំងអស់ដែលមានការពាក់ព័ន្ធ ហើយត្រូវបោះពុម្ពផ្សាយជាសាធារណៈ ដោយមន្ត្រីកាន់កាប់បញ្ជី បើយល់ឃើញថា ជាការចាំបាច់ ។

**មាត្រា ៣២. – សវនាការ**

១-មន្ត្រីកាន់កាប់បញ្ជី ត្រូវចាត់ចែងឱ្យមានសវនាការ បើភាគីណាមួយ ឬភាគីទាំងពីរនៃជំលោះស្នើសុំជាលាយលក្ខណ៍អក្សរ ឱ្យមានសវនាការមុនពេលចេញសេចក្តីសម្រេចណាមួយ ។ ពាក្យស្នើសុំសវនាការនេះ ត្រូវធ្វើឡើងនៅមុនពេល ឬក្រោយពេល ០១ (មួយ) ខែ នៃថ្ងៃដាក់ពាក្យបណ្តឹង ឬឯកសារគាំទ្ររបស់ខ្លួនមកមន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានពាក្យស្នើសុំសវនាការ [illegible]ការកំណត់ខាងលើ តាមឆន្ទានុសិទ្ធិដែលផ្តល់ដោយច្បាប់ ឬដោយអនុក្រឹត្យនេះ មន្ត្រីកាន់កាប់បញ្ជីអាច

ចេញសេចក្តីសម្រេចរបស់ខ្លួន ដោយគ្មានសវនាការ ឬបើយល់ថា ចាំបាច់ត្រូវអញ្ជើញភាគីនៃជម្លោះមកធ្វើសវនាការ ។

២-នៅពេលទទួលបានសំណើសុំធ្វើសវនាការ មន្ត្រីកាន់កាប់បញ្ជី ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីកាលបរិច្ឆេទ នៃការបើកសវនាការយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការមុនពេលបើកសវនាការ ទៅឱ្យបុគ្គលដែលបានដាក់ពាក្យស្នើសុំធ្វើសវនាការ និងបុគ្គលដែលពាក់ព័ន្ធដទៃទៀត ។

**មាត្រា ៣៣. – ទំនាក់ទំនងតាមរយៈប្រៃសណីយ៍**

១-សេចក្តីជូនដំណឹង ពាក្យស្នើសុំ ឬឯកសារដទៃទៀត ដែលផ្ញើទៅឱ្យមន្ត្រីកាន់កាប់បញ្ជី តាមបញ្ញើប្រៃសណីយ៍ ត្រូវបានចាត់ទុកថា បានផ្តល់នៅត្រឹមកាលបរិច្ឆេទ ដែលបញ្ញើទាំងនោះត្រូវបានទទួលដោយការិយាល័យមន្ត្រីកាន់កាប់បញ្ជី។ នៅពេលទទួលបានឯកសារទាំងនោះ ការិយាល័យមន្ត្រីកាន់កាប់បញ្ជី ត្រូវវាយត្រាចូល ចុះលេខ ថ្ងៃ ខែ ឆ្នាំទទួលជាបន្ទាន់ ដើម្បីជាភស្តុតាងបញ្ជាក់ អំពីពេលវេលាទទួលឯកសារទាំងនោះ ។

២-កថាខ័ណ្ឌ ១ ខាងលើ នឹងមិនត្រូវបានអនុវត្តទេ ចំពោះការកំណត់អំពីកាលបរិច្ឆេទដាក់ពាក្យក្នុងករណីផ្ទុយនឹងមាត្រា១៦ នៃអនុក្រឹត្យនេះ ។

**មាត្រា ៣៤. – ភស្តុតាង**

១-ភស្តុតាងទាំងឡាយដែលដាក់ជូនពិនិត្យ ត្រូវធ្វើឡើងតាមរយៈលិខិតប្រកាស ឬតាមរយៈលិខិតថ្លែងសច្ចា ។

២-ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីយល់ថា សមស្របចំពោះករណីដោយឡែកណាមួយ មន្ត្រីកាន់កាប់បញ្ជី អាចសាកសួរដោយផ្ទាល់មាត់ជាជំនួស ឬជាការបន្ថែមលើភស្តុតាងដទៃទៀត ហើយអនុញ្ញាតឱ្យសាក្សីណាមួយចូលរួម ដើម្បីបញ្ជាក់លើលិខិតថ្លែងសច្ចា ឬលិខិតប្រកាសរបស់ខ្លួន ។

**មាត្រា ៣៥. – លិខិតប្រកាស និងលិខិតថ្លែងសច្ចា**

លិខិតប្រកាស ឬលិខិតថ្លែងសច្ចា ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីកុងស៊ុល ឬសារការី ឬអ្នកប្រកបវិជ្ជាជីវៈច្បាប់ ដែលមានការទទួលស្គាល់ត្រឹមត្រូវ ។

**មាត្រា ៣៦. – អាជ្ញាធរមានសមត្ថកិច្ច**

អាជ្ញាធរមានសមត្ថកិច្ច ដែលមានចែងក្នុងមាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ មាត្រា៤២ និងមាត្រា៤៦ នៃច្បាប់ រួមមានអង្គភាពគយ និងរដ្ឋាករ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យគុណភាព...

អាហារ៍ណ និងបង្ក្រាបការក្លែងបន្លំ ហៅកាត់ថាកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម និង នគរបាលមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ ។

**មាត្រា ៣៧.- ការបោះពុម្ពផ្សាយ និង ព្រឹត្តិបត្រផ្លូវការ**

ចំណុចពិសេសទាំងឡាយរបស់ម៉ាក និងចំណាត់ការនានា ព្រមទាំងព័ត៌មានផ្សេងទៀត ដែលតម្រូវឱ្យបោះពុម្ពផ្សាយដោយច្បាប់ ឬអនុក្រឹត្យនេះ ត្រូវតែបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ តាមការណែនាំរបស់មន្ត្រីកាន់កាប់បញ្ជី ។

## ជំពូកទី ៤

## វិធានការតាមមាត់ច្រកព្រំដែន

**មាត្រា ៣៨.- ពាក្យប្តឹង**

១-អនុលោមតាមមាត្រា៣៥ និងមាត្រា៣៦ នៃច្បាប់ និង ច្បាប់ ស្តីពីកាគ្រប់គ្រង គុណភាពសុវត្ថិភាពលើផលិតផលទំនិញ និងសេវា ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬអ្នកទទួលអាជ្ញាប័ណ្ណ ឬភ្នាក់ងារតំណាងស្របច្បាប់ អាចធ្វើពាក្យប្តឹងទៅរដ្ឋបាលគយ និង រដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការឱ្យព្យួរទុកនូវការធ្វើបែបបទទំនិញណា ដែលសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី ។

២-ក្នុងរង្វង់មិនលើសពី ៣០ (សាមសិប ) ថ្ងៃ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសអន្តរក្រសួងមួយ អំពីគំរូនៃពាក្យប្តឹង និងតម្រូវការនានាស្របតាមច្បាប់ជាធរមាន។

៣-ពាក្យប្តឹងនោះមានសុពលភាព ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹង។ ពេលផុតសុពលភាព អ្នកដាក់ពាក្យត្រូវធ្វើពាក្យប្តឹងឡើងវិញ បើសំណូមពរនៃការឃាត់ និងត្រួតពិនិត្យទំនិញនៅមាននៅឡើយ ។

**មាត្រា ៣៩.- កម្រៃរដ្ឋបាល**

ពាក្យប្តឹងនីមួយៗ ត្រូវអមមកជាមួយនូវការទូទាត់កម្រៃរដ្ឋបាល ដែលកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។

**មាត្រា ៤០.- កាតព្វកិច្ចរបស់អ្នកដាក់ពាក្យប្តឹង**

ក្រៅពីកាតព្វកិច្ចនានាដែលមានចែងក្នុងមាត្រា៣៥ មាត្រា៣៦ និងមាត្រា៣៨ នៃច្បាប់ អ្នកដាក់ពាក្យមានភារកិច្ចទទួលខុសត្រូវ ចំពោះមធ្យោបាយដឹកជញ្ជូន ឃ្លាំងដែលត្រូវស្តុកទំនិញនៅពេល

ឃាត់រក្សាទុក ។ ឃ្លាំងស្តុកទំនិញត្រូវស្ថិតនៅក្នុងបរិវេណកំពង់ផែ ឬក្នុងបរិវេណមាត់ច្រកនាំចេញ នាំចូល ដែលបានកំណត់ និងគ្រប់គ្រងដោយអាជ្ញាធរមានសមត្ថកិច្ច តាមច្បាប់ជាធរមាន ។ ការចំណាយនានាក្នុង ការបំផ្លាញចោលទំនិញមិនស្របច្បាប់ ជាកាតព្វកិច្ចរបស់អ្នកដាក់ពាក្យ ។

**មាត្រា ៤១. - ការបដិសេធចំពោះការឃាត់ទុកទំនិញសង្ស័យថា មានម៉ាកក្លែងក្លាយ**

អង្គភាពគយ និងរដ្ឋាករ ឬ កាំកុងត្រូល អាចមានសិទ្ធិបដិសេធការស្នើសុំឃាត់ទំនិញ ដែលសង្ស័យ ឬមានម៉ាកក្លែងក្លាយ តែក្នុងករណីដែលអ្នកដាក់ពាក្យស្នើសុំឃាត់ទំនិញ មិនបានអនុវត្តតាម ការទាមទារណាមួយ របស់អង្គភាពគយ និងរដ្ឋាករ ឬ កាំកុងត្រូល ដែលស្របតាមមាត្រានានានៃច្បាប់ និងអនុក្រឹត្យនេះប៉ុណ្ណោះ ។

**មាត្រា ៤២. - ចំណាត់ការ និង រយៈវេលា**

បែបបទ និងរយៈវេលានៃចំណាត់ការនានារបស់អង្គភាពគយ និងរដ្ឋាករ និង ឬកាំកុងត្រូល ត្រូវអនុលោមតាមជំពូកទី១០ នៃច្បាប់ និង មាត្រានានានៃអនុក្រឹត្យនេះ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៤៣. -**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤៤. -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមាន ប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ភ្នំពេញ, ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ នៃអនុក្រឹត្យ លេខ២៤៤អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៦
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ :

- "ច្បាប់" សំដៅដល់ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ។
- "ការបដិសេធ" (Refusal) សំដៅដល់ការមិនយល់ព្រមចុះបញ្ជីម៉ាកដែលស្នើសុំដោយ អ្នកដាក់ពាក្យពីសំណាក់មន្ត្រីកាន់កាប់បញ្ជី ។
- "បណ្តឹងជំទាស់" (Opposition) សំដៅដល់បណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេច របស់មន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការចុះបញ្ជីម៉ាកមួយ ត្រូវបានបោះពុម្ពផ្សាយ ក្នុងព្រឹត្តិបត្រផ្លូវការ ។
- បណ្តឹងតវ៉ា (Appeal) សំដៅដល់ការប្តឹងតវ៉ាទៅនឹងសេចក្តីសំរេចចុងក្រោយរបស់មន្ត្រីកាន់កាប់បញ្ជី ឬ សេចក្តីសំរេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ។
- "មោឃភាព ឬ ការលុបម៉ាកចេញពីបញ្ជី " (Invalidation or Cancellation) សំដៅដល់ការលុបម៉ាកណាមួយ ដែលបានចុះបញ្ជីរួចដោយមន្ត្រីកាន់កាប់បញ្ជី ។
- "សេចក្តីប្រកាសពីការប្រើប្រាស់ ឬមិនប្រើប្រាស់" (Affidavit of Use/Non-Use) សំដៅដល់សេចក្តីប្រកាសរបស់ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬ ដោយភ្នាក់ងារតំណាងអំពីការប្រើប្រាស់ ឬ មិនបានប្រើប្រាស់ម៉ាករបស់ខ្លួនដែលបានចុះបញ្ជីរួច ។
- "លិខិតថ្លែងសច្ចា" (Affidavit) សំដៅដល់លិខិតអំណះអំណាង ដែលត្រូវបានភ្ជាប់ជាមួយនឹងលិខិតស្នើសុំឱ្យមន្ត្រីកាន់កាប់បញ្ជីចាត់ការនូវកិច្ចការណាមួយ ដូចជាការសុំលុបម៉ាក ការសុំរក្សាទុកការចុះបញ្ជីម៉ាក ឬស្នើសុំចាត់វិធានការណាមួយចំពោះការរំលោភបំពានម៉ាក ។
- "ការច្រានចោល" (Rejection) សំដៅដល់ការមិនយល់ព្រមជាលើកដំបូងរបស់មន្ត្រីកាន់កាប់បញ្ជីចំពោះពាក្យស្នើសុំ ឬការចុះបញ្ជីម៉ាក ។
- "មន្ត្រីកាន់កាប់បញ្ជី" (Registrar) សំដៅដល់ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។
- "សវនាការ" (Hearing) សំដៅដល់ការប្រជុំដោះស្រាយវិវាទរបស់មន្ត្រីកាន់កាប់បញ្ជី មុននឹងសំរេចលើករណីជំទាស់តវ៉ានានារបស់ដើមបណ្តឹង ។

# ៣. ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

## ចុះថ្ងៃទី០៨ ឧសភា ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ៤៤១ MIH / 2014

# ប្រកាស
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម ៖

- រៀបចំបេសកកម្ម និងរចនាសម្ព័ន្ធរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- រៀបចំតួនាទី និងភារកិច្ចរបស់ការិយាល័យនានា នៃនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- ធានាគុណភាព និងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារកម្មសិទ្ធិឧស្សាហកម្មរបស់ក្រសួង។

**ប្រការ៣.-**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មមានមុខងារ និងភារកិច្ចដូចតទៅ ៖

- ជាសេនាធិការឱ្យអគ្គនាយកដ្ឋានឧស្សាហកម្ម លើការងារកម្មសិទ្ធិឧស្សាហកម្ម

- រៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការក្នុងការពង្រឹងការការពារសិទ្ធិលើកម្មសិទ្ធិឧស្សាហកម្មក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការរៀបចំគោលនយោបាយ អំពីការច្នៃប្រឌិត និងបង្កើតថ្មី ក្នុងក្របខណ្ឌនៃការអភិវឌ្ឍន៍បច្ចេកវិទ្យា
- រៀបចំលិខិតបទដ្ឋានគតិយុត្ត នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការផ្ដល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការចុះបញ្ជីគំនូរឧស្សាហកម្ម គំនូរបង្ហាញនៃសៀគ្វីបង្រួម
- អនុវត្តនីតិវិធីសម្រាប់ការផ្ដល់ និងការគ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកបង្កាត់ពូជដំណាំ និងសម្រាប់ការចុះបញ្ជី និងការគ្រប់គ្រងគំនូរឧស្សាហកម្ម និងគំនូរបង្ហាញនៃសៀគ្វីបង្រួមក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តយន្តការជំរុញការច្នៃប្រឌិត និងបង្កើតថ្មី
- ផ្សព្វផ្សាយតាមរយៈព្រឹត្តិផ្លូវការ ឬតាមមធ្យោបាយផ្សេងទៀត សម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ សិទ្ធិអ្នកបង្កាត់ពូជដំណាំ គំនូរឧស្សាហកម្ម និងគំនូរបង្ហាញនៃសៀគ្វីបង្រួម
- គ្រប់គ្រងមណ្ឌលច្នៃប្រឌិត មណ្ឌលបង្កើតតក្កកម្ម មណ្ឌលស្រាវជ្រាវ និងពិនិត្យកម្មសិទ្ធិឧស្សាហកម្ម មណ្ឌលផ្សព្វផ្សាយ បណ្ដុះបណ្ដាលកម្មសិទ្ធិឧស្សាហកម្ម
- រៀបចំការអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ដុះបណ្ដាលជំនាញកម្មសិទ្ធិឧស្សាហកម្ម
- ផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មានស្ដីពីកម្មសិទ្ធិឧស្សាហកម្ម ធ្វើជាឧបករណ៍ដើម្បីជំរុញការច្នៃប្រឌិតថ្មី ការបង្កើតតក្កកម្ម ការស្រាវជ្រាវ ក្នុងគោលបំណងអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងព្រះរាជាណាចក្រកម្ពុជា
- អនុវត្តនីតិវិធីក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ ក្នុងការចុះបញ្ជីកម្មសិទ្ធិឧស្សាហកម្ម
- សម្របសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអង្គការអន្តរជាតិ រួមទាំងសហការជាមួយដៃគូអភិវឌ្ឍនានា លើការងារកម្មសិទ្ធិឧស្សាហកម្ម
- បូកសរុបរបាយការណ៍ វាយតម្លៃលទ្ធផលការងារ និងអភិវឌ្ឍវិស័យកម្មសិទ្ធិឧស្សាហកម្ម
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធានស្ថាប័នប្រគល់ជូន។

**ប្រការ៤._**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៥._**

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្មមានការិយាល័យក្រោមឱវាទចំនួន៥ និងមជ្ឈមណ្ឌលចំនួន១ ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យប្រកាសនីយបត្រតក្កកម្ម
- ការិយាល័យគំនូរឧស្សាហកម្ម
- មជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី
- ការិយាល័យសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- ការិយាល័យដោះស្រាយវិវាទ និងសហប្រតិបត្តិការ។


ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

**ប្រការ៦._**

ការិយាល័យជំនាញនីមួយៗដឹកនាំដោយប្រធានមួយរូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

មជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី ដឹកនាំដោយប្រធាន ១ រូប ថ្នាក់ស្មើនឹងប្រធានការិយាល័យ និងអមដោយអនុប្រធានមួយចំនួនជាជំនួយការ ថ្នាក់ស្មើនឹងអនុប្រធានការិយាល័យ។

**ប្រការ៧._**

តួនាទី និងភារកិច្ចរបស់ការិយាល័យជំនាញនីមួយៗ មានដូចតទៅ ៖

**១- ការិយាល័យរដ្ឋបាល**

**ក- តួនាទី**

ការិយាល័យរដ្ឋបាល ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងាររដ្ឋបាលបូកសរុប។

**ខ- ភារកិច្ច**

ការិយាល័យរដ្ឋបាលមានភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងការងារបុគ្គលិកមន្ត្រីរាជការក្នុងនាយកដ្ឋាន បូកសរុប វាយតម្លៃសមត្ថភាព គុណភាពមន្ត្រីរាជការ
- គ្រប់គ្រងលិខិតចេញ ចូលគ្រប់ប្រភេទ និងបែងចែកលិខិតទាំងនោះទៅតាមការិយាល័យជំនាញ និងថែរក្សាឯកសារ
- គ្រប់គ្រងសារពើភ័ណ្ឌ ចលនទ្រព្យ និងអចលនទ្រព្យរបស់នាយកដ្ឋាន និងបណ្ណាល័យរបស់នាយកដ្ឋាន និងបែងចែកផ្គត់ផ្គង់សម្ភារការិយាល័យក្នុងនាយកដ្ឋាន
- រៀបចំផែនការសកម្មភាព និងផែនការថវិកា របស់នាយកដ្ឋាន
- សម្របសម្រួលការងារជាមួយការិយាល័យនានាក្នុងនាយកដ្ឋាន និងស្ថាប័នពាក់ព័ន្ធ លើការងារកម្មសិទ្ធិឧស្សាហកម្ម
- បូកសរុបរបាយការណ៍ វាយតម្លៃលទ្ធផលការងារ និងអភិវឌ្ឍវិស័យកម្មសិទ្ធិឧស្សាហកម្ម
- លើកគម្រោងចំណាយរដ្ឋបាលប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំបដិសណ្ឋារកិច្ច និងកិច្ចប្រជុំ សិក្ខាសាលារបស់នាយកដ្ឋាន
- អង្កេត និងវាយតម្លៃលើលទ្ធផលការងារដែលបានអនុវត្តដោយការិយាល័យជំនាញនីមួយៗ
- ទទួលពិនិត្យ និងវាយតម្លៃសំណុំលិខិតស្នើសុំក្នុងការចុះបញ្ជីភ្នាក់ងារដែលប្រកបអាជីវកម្មធ្វើជាតំណាងរបស់អ្នកដាក់ពាក្យសុំ
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**២- ការិយាល័យប្រកាសនីយបត្រតក្កកម្ម**

**ក- តួនាទី**

ការិយាល័យប្រកាសនីយបត្រតក្កកម្ម ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញនៃសៀគ្វីបង្រួម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: ៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: ៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

ខ- ភារកិច្ច

ការិយាល័យប្រកាសនីយបត្រតក្កកម្ម មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការក្នុងការពង្រឹងការការពារប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញនៃសៀគ្វីបង្រួម
- រៀបចំបទដ្ឋានគតិយុត្ត នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម
- ទទួលស្រាវជ្រាវ ពិនិត្យ និងវាយតម្លៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញនៃសៀគ្វីបង្រួម
- អនុវត្តនីតិវិធីលើការផ្តល់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម
- អនុវត្តនីតិវិធីសំណុំលិខិតស្នើសុំអន្តរជាតិ សម្រាប់ប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញនៃសៀគ្វីបង្រួម តាមប្រព័ន្ធអន្តរជាតិនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មតាមប្រព័ន្ធថ្នាក់តំបន់ និងតាមកិច្ចសហប្រតិបត្តិការរបស់រដ្ឋ
- គ្រប់គ្រងប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរបង្ហាញនៃសៀគ្វីបង្រួមដែលបានផ្តល់សិទ្ធិការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការ ផ្តល់យោបល់បច្ចេកទេសដល់មណ្ឌលស្រាវជ្រាវ និងពិនិត្យប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍
- រៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយតាមព្រឹត្តិបត្រផ្លូវការ និងមធ្យោបាយផ្សេងទៀតអំពី ៖
  - សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម ការផ្តល់ប្រកាសនីយបត្រតក្កកម្ម និងការងារពាក់ព័ន្ធផ្សេងៗទៀត
  - សំណុំលិខិតស្នើសុំវិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ ការផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងការងារពាក់ព័ន្ធផ្សេងៗទៀត
  - សំណុំលិខិតស្នើសុំចុះបញ្ជីគំនូរបង្ហាញនៃសៀគ្វីបង្រួម និងការងារពាក់ព័ន្ធផ្សេងៗទៀត។
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៣- ការិយាល័យគំនូរឧស្សាហកម្ម

ក- តួនាទី

ការិយាល័យគំនូរឧស្សាហកម្ម ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារគំនូរឧស្សាហកម្ម។

ខ- ភារកិច្ច

ការិយាល័យគំនូរឧស្សាហកម្ម មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងការពង្រឹងការការពារសិទ្ធិលើគំនូរឧស្សាហកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំបទដ្ឋានគតិយុត្ត នីតិវិធី បទបញ្ញាពាក់ព័ន្ធនឹងការចុះបញ្ជីគំនូរឧស្សាហកម្ម



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- ទទួល ស្រាវជ្រាវ ពិនិត្យ និងវាយតម្លៃសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម
- អនុវត្តនីតិវិធីសម្រាប់ការចុះបញ្ជីគំនូរឧស្សាហកម្ម សំណុំលិខិតស្នើសុំអន្តរជាតិ គំនូរឧស្សាហកម្ម តាមប្រព័ន្ធអន្តរជាតិ ប្រព័ន្ធតំបន់ និងតាមកិច្ចសហប្រតិបត្តិការរបស់រដ្ឋ
- គ្រប់គ្រងគំនូរឧស្សាហកម្មដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយតាមព្រឹត្តិបត្រផ្លូវការ និងមធ្យោបាយផ្សេងទៀតអំពីសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម ការចុះបញ្ជីគំនូរឧស្សាហកម្ម និងការងារពាក់ព័ន្ធផ្សេងៗទៀត
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៤- មជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី

### ក- តួនាទី

មជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារជំរុញការច្នៃប្រឌិត និងបង្កើតថ្មី ការអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្តុះបណ្តាលជំនាញកម្មសិទ្ធិឧស្សាហកម្ម។

### ខ- ភារកិច្ច

មជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងទិសដៅផែនការ ក្នុងការជំរុញ និងអភិវឌ្ឍការច្នៃប្រឌិត ការបង្កើតតក្កកម្ម និងការស្រាវជ្រាវផ្សេងៗ
- រៀបចំបទដ្ឋានគតិយុត្ត នីតិវិធី បទបញ្ញាពាក់ព័ន្ធសម្រាប់ជំរុញសកម្មភាពច្នៃប្រឌិត និងបង្កើតថ្មី
- អនុវត្តយន្តការជំរុញការច្នៃប្រឌិត និងបង្កើតថ្មី
- គ្រប់គ្រង និងដំណើរការមជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី
- ផ្សព្វផ្សាយ និងប្រើប្រាស់ព័ត៌មានស្តីពីកម្មសិទ្ធិឧស្សាហកម្ម ធ្វើជាឧបករណ៍សម្រាប់ជំរុញការច្នៃប្រឌិតថ្មី ការបង្កើតការស្រាវជ្រាវក្នុងគោលបំណងអភិវឌ្ឍវិទ្យាសាស្ត្រ បច្ចេកវិទ្យានៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំការតាំងពិព័រណ៍អំពីការច្នៃប្រឌិតតក្កកម្ម និងស្នាដៃពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម
- ជួយប្រឹក្សាយោបល់អំពីព័ត៌មានកម្មសិទ្ធិឧស្សាហកម្មដល់សាធារណជន
- រៀបចំ និងអនុវត្តគម្រោងបណ្តុះបណ្តាលដល់សាធារណជនពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៥- ការិយាល័យសិទ្ធិអ្នកបង្កាត់ពូជដំណាំ

### ក- តួនាទី

ការិយាល័យសិទ្ធិអ្នកបង្កាត់ពូជដំណាំ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

ខ- ភារកិច្ច

ការិយាល័យសិទ្ធិអ្នកបង្កាត់ពូជដំណាំ មានភារកិច្ចដូចតទៅ ៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និងផែនការក្នុងការពង្រឹងការការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ
- រៀបចំបទដ្ឋានគតិយុត្ត នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការចុះបញ្ជី និងការគ្រប់គ្រងការផ្តល់សិទ្ធិដល់អ្នកបង្កាត់ពូជដំណាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ទទួលស្រាវជ្រាវ និងពិនិត្យសំណុំលិខិតស្នើសុំផ្តល់សិទ្ធិការពារអ្នកបង្កាត់ពូជដំណាំ
- អនុវត្តនីតិវិធីសម្រាប់ការផ្តល់សិទ្ធិការពារអ្នកបង្កាត់ពូជដំណាំ
- អនុវត្តនីតិវិធីលើសំណុំលិខិតស្នើសុំអន្តរជាតិ សម្រាប់ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំតាមប្រព័ន្ធអន្តរជាតិ ប្រព័ន្ធថ្នាក់តំបន់ និងតាមកិច្ចសហប្រតិបត្តិការរបស់រដ្ឋ
- គ្រប់គ្រងការការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំដែលបានផ្តល់ការការពារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំចងក្រង បោះពុម្ព និងផ្សព្វផ្សាយតាមព្រឹត្តិបត្រផ្លូវការ និងមធ្យោបាយផ្សេងទៀត អំពីសំណុំលិខិតស្នើសុំផ្តល់សិទ្ធិការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ លទ្ធផលស្រាវជ្រាវ ឬពិនិត្យលើសំណុំលិខិតស្នើសុំ លទ្ធផលនៃការពិសោធន៍ពូជថ្មីនៃដំណាំ ការផ្តល់វិញ្ញាបនបត្រការពារសិទ្ធិអ្នកបង្កាត់ពូជដំណាំ និងការងារពាក់ព័ន្ធផ្សេងៗទៀត
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

## ៦- ការិយាល័យដោះស្រាយវិវាទ និងសហប្រតិបត្តិការ

ក- តួនាទី

ការិយាល័យដោះស្រាយវិវាទ និងសហប្រតិបត្តិការ ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារសហប្រតិបត្តិការ និងសម្រុះសម្រួលវិវាទ ពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្ម។

ខ- ភារកិច្ច

ការិយាល័យដោះស្រាយវិវាទ និងសហប្រតិបត្តិការ មានភារកិច្ចដូចតទៅ ៖

- រៀបចំបទដ្ឋានគតិយុត្ត នីតិវិធី និងបទបញ្ញាពាក់ព័ន្ធនឹងការសម្រុះសម្រួលដោះស្រាយវិវាទកម្មសិទ្ធិឧស្សាហកម្ម
- សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ អង្គការអន្តរជាតិ និងការិយាល័យពាក់ព័ន្ធ លើការងារកម្មសិទ្ធិឧស្សាហកម្ម
- រៀបចំចងក្រងឯកសារ និងផ្សព្វផ្សាយព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងកម្មសិទ្ធិឧស្សាហកម្មដល់សាធារណជន
- ផ្សព្វផ្សាយគោលនយោបាយ និងផែនការក្នុងការពង្រឹងការការពារកម្មសិទ្ធិឧស្សាហកម្ម
- សហការស្រាវជ្រាវ និងទប់ស្កាត់ការធ្វើអាជីវកម្មមិនស្របច្បាប់ ដែលរំលោភបំពានលើសិទ្ធិជាម្ចាស់នៃកម្មសិទ្ធិឧស្សាហកម្ម ដែលទទួលបានការការពារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥ ២៣ ២១១ ៧៧៥
ទូរសារលេខ: (៨៥៥ ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- សិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ជាតិ និងច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិឧស្សាហកម្ម
- សម្រុះសម្រួល និងដោះស្រាយវិវាទពាក់ព័ន្ធនឹងការងារកម្មសិទ្ធិឧស្សាហកម្ម
- និងទទួលអនុវត្តភារកិច្ចផ្សេងទៀត ដែលប្រធាននាយកដ្ឋានប្រគល់ជូន។

**ប្រការ៨._**

ការបែងចែកភារកិច្ចរបស់មន្ត្រីនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ជាសមត្ថកិច្ចរបស់ប្រធាននាយកដ្ឋាន។

**ប្រការ៩._**

ប្រកាសលេខ ៦៨៩ ឧរថ.បល.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និងគ្រប់អង្គភាពក្រោមឱវាទក្រសួងត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

  *« ដើម្បីជូនជ្រាប »*
- ដូចប្រការ១០

  *« ដើម្បីអនុវត្ត »*
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធនៃប្រកាសលេខ ៤៥១ MIH / 2014 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤



# ៤. ប្រកាសស្តីពី ភ្នាក់ងារតំណាងស្របច្បាប់នៃម៉ាកក្នុង ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. 064 MOC / SM 2011

# ប្រកាស

## ស្តីពី

## ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៩/១០២៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦.១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ .បក ចុះថ្ងៃទី ១២ កក្កដា ឆ្នាំ ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញប្រកាសលេខ ២១១ MOC/SM ២០០៧ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា របស់ក្រសួងពាណិជ្ជកម្ម

-បានឃើញប្រកាសលេខ ១០៥ MOC/SM ២០០៩ ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពី អំពីនីតិវិធីណែនាំការចុះបញ្ជី និងការការពារម៉ាកសម្រាប់ការសម្គាល់ភូមិសាស្ត្រទំនិញ

-យោងតាមសំណូមពរចាំបាច់នៃការងារ

## ស ម្រេ ច

### ប្រការ ១ : គោលដៅ

ប្រកាសនេះមានគោលដៅកំណត់នូវលក្ខខណ្ឌតម្រូវ និងនីតិវិធីទទួលស្គាល់បុគ្គលធ្វើជាតំណាងស្របច្បាប់នៃម្ចាស់ម៉ាក់ ដោយអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៨២៥
អ៊ីម៉ែល: moccab@moc.gov.kh

## ប្រការ ២ ៖ គោលបំណង

ប្រកាសនេះមានគោលបំណង ៖

១- គ្រប់គ្រង និងពង្រឹងសមត្ថភាពរបស់តំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដើម្បីសម្រួលដល់ការងារចុះបញ្ជី និង កិច្ចការដទៃទៀតដែលទាក់ទងនឹងម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ឱ្យមានភាពរលូនប្រកបដោយប្រសិទ្ធភាព។

២- ផ្តល់ភាពងាយស្រួលដល់ម្ចាស់ម៉ាកក្នុងការធ្វើអាជីវកម្ម និង ការការពារសិទ្ធិរបស់ខ្លួន តាមរយៈតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

## ប្រការ ៣ ៖ និយមន័យ និង វិសាលភាព

ម៉ាកសំដៅដល់ ម៉ាក និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

ប្រកាសនេះគ្រប់ដណ្តប់ទៅលើការងារផ្សេងៗដែលទាក់ទងទៅនឹងម៉ាក ដូចជា ការចុះបញ្ជី ការធ្វើអាជីវកម្ម ការវាយតម្លៃទ្រព្យកម្មសិទ្ធិបញ្ញា និងការអនុវត្តន៍សិទ្ធិរបស់ម្ចាស់ម៉ាកក្នុង និង ក្រៅប្រទេស ជាដើម។

## ប្រការ ៤ ៖ ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក

១- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល តំណាងឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ដើម្បីបំពេញកិច្ចការចំពោះមុខនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។ ភ្នាក់ងារតំណាងស្របច្បាប់ នៃម្ចាស់ម៉ាក ត្រូវមានលក្ខណៈសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ហើយត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួង ពាណិជ្ជកម្ម។

២- បរិមាណភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក មិនត្រូវបានកំណត់ចំនួនឡើយ។ រូបវន្តបុគ្គលដែលបានប្រឡងជាប់ជាស្ថាពរ ត្រូវបានចាត់ទុកថាមានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ក្នុងការធ្វើជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

៣- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក អាចបង្ហាញខ្លួនក្នុងតុលាការនៃព្រះរាជាណាចក្រកម្ពុជា តែក្នុងករណី មិនផ្ទុយនឹងច្បាប់ និង បទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា។

៤- ផ្អែកតាមសំណើ រូបវន្តបុគ្គលណាមួយអាចនឹងត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក លុះត្រាតែបុគ្គលនោះ បំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ និង
- មាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង
- មានទីតាំងប្រកបអាជីវកម្ម ឬការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង
- ជាប់ជាស្ថាពរក្នុងការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឬត្រូវបានចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ដូចមានចែងក្នុងប្រការ ២៦ និង
- មិនផ្ទុយនឹងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

៥- ផ្អែកតាមសំណើ នីតិបុគ្គលអាចនឹងត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្នុងបញ្ជីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក លុះត្រាតែ ÷

- មានបុគ្គលិកជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកយ៉ាងតិចមួយនាក់ឈរឈ្មោះអោយ និង
- មាននិវេសនដ្ឋានអចិន្ត្រៃយ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

៦-រូបវន្តបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកម្នាក់ អាចឈរឈ្មោះអោយនីតិបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់តែមួយគត់។

## ប្រការ ៥ : ការរៀបចំការប្រឡង

ក្នុងករណីមានចំនួនបេក្ខជនសមស្រប ការប្រឡងសមត្ថភាពសម្រាប់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក នឹងត្រូវរៀបចំធ្វើឡើង យ៉ាងតិចមួយដងក្នុងមួយឆ្នាំ ឬតាមការចាំបាច់។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងរៀបចំបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និង លេខាធិការដ្ឋានប្រឡង។

## ប្រការ ៦ : ក្រុមប្រឹក្សាប្រឡង

១- ក្រុមប្រឹក្សាប្រឡងមានតួនាទីជ្រើសរើសមន្ត្រីជំនាញ ដើម្បីបង្រៀនដល់បេក្ខជនត្រៀមប្រឡង និងរៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក។

២- ក្រុមប្រឹក្សាប្រឡង មានសមាសភាពចំនួន ០៧ រូប រួមមាន ÷

ក-ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម

ខ-ប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងពាណិជ្ជកម្ម

គ-មន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ចំនួន ០៣រូប និងមន្ត្រីនាយកដ្ឋានបុគ្គលិក នៃក្រសួងពាណិជ្ជកម្ម ចំនួន ០២រូប ដែលស្នើសុំតែងតាំងដោយប្រធាននាយកដ្ឋានសាមី។

៣- ប្រធាន និងអនុប្រធានក្រុមប្រឹក្សាប្រឡង ត្រូវជ្រើសរើសចេញពីសមាជិករបស់ខ្លួន។

៤-ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និងប្រធាននាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម អាចតែងតាំងមន្ត្រីមួយរូបតាមជម្រើសរបស់ខ្លួន ដើម្បីកាន់តំណែងជំនួសក្នុងក្រុមប្រឹក្សាប្រឡង សម្រាប់រយៈពេលណាមួយ។

## ប្រការ ៧ : សិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រឡង

១- រៀបចំសមាសភាពគណៈកម្មការប្រឡង និង លេខាធិការដ្ឋានប្រឡង ដើម្បីសុំការឯកភាពពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

២- ជ្រើសរើសគ្រូបង្រៀនជំនាញកម្មសិទ្ធិបញ្ញាក្នុងចំណោមមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលមានសមត្ថភាព និងគរុកោសល្យ ដើម្បីបង្រៀនដល់បេក្ខជនត្រៀមប្រឡង។

៣- ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំដែលចាំបាច់ទៅគណៈកម្មការប្រឡង សម្រាប់ការរៀបចំវិញ្ញាសាប្រឡង ពិនិត្យមើលសេចក្តីព្រាង និងធ្វើការជ្រើសរើសអត្ថបទចុងក្រោយ សម្រាប់វិញ្ញាសាប្រឡង។

៤- ក្រុមប្រឹក្សាត្រូវសម្រេច ជាពិសេស ទៅលើបញ្ជីសៀវភៅ និងឯកសារ ដែលបេក្ខជនអាចប្រើប្រាស់ក្នុងពេលប្រឡង និងណែនាំលេខាធិការដ្ឋានប្រឡង អំពីវិធានការដែលត្រូវធ្វើចំពោះបេក្ខជន ដែលបានរកឃើញថា កំពុង ឬ មានបំណងលួចចម្លង។

៥- ក្រុមប្រឹក្សាត្រូវកំណត់ពិន្ទុសម្រាប់វិញ្ញាសានីមួយៗ ត្រួតពិនិត្យពិន្ទុ ដែលផ្តល់ដោយគណៈកម្មការប្រឡង ហើយសម្រេចបឋមថា បេក្ខជនមួយណាបានប្រឡងជាប់ ឬ ធ្លាក់។ សមាជិកណាមួយរបស់ក្រុមប្រឹក្សា ដែលបានធ្វើជាសមាជិករបស់គណៈកម្មការប្រឡង ហើយបានឱ្យពិន្ទុបេក្ខជនប្រឡង មិនអាចចូលរួមក្នុងការសម្រេចចិត្តនេះបានទេ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

## ប្រការ ៨ ៖ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាប្រឡង

ក្រុមប្រឹក្សា ត្រូវកោះប្រជុំដោយប្រធានរបស់ខ្លួន។ កូរ៉ុមនៃកិច្ចប្រជុំ ដែលមានសមាជិកចំនួន ០៤(បួន) រូប អាចដំណើការកិច្ចប្រជុំបាន។ សេចក្តីសម្រេចបឋមរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សេចក្តីសម្រេចរបស់អង្គប្រជុំត្រូវយកតាមសម្លេង ៥០ ភាគរយ បូក ១ របស់សមាជិកចូលរួម ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាព។

ប្រធានក្រុមប្រឹក្សាប្រឡង ត្រូវរាយការណ៍សុំសេចក្តីសម្រេចចុងក្រោយពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អំពីសមាសភាពបេក្ខជនដែលប្រឡងជាប់ជាស្ថាពរ។

## ប្រការ ៩ ៖ អាណត្តិរបស់ក្រុមប្រឹក្សាប្រឡង

សមាជិកក្រុមប្រឹក្សាប្រឡងដែលបានតែងតាំង នឹងកាន់មុខតំណែងមានរយៈពេល ០៣ (បី) ឆ្នាំ។ នៅពេលផុតរយៈពេលនេះ សមាជិកក្រុមប្រឹក្សាអាចត្រូវបានតែងតាំងសាជាថ្មី។

## ប្រការ ១០ ៖ គណៈកម្មការប្រឡង

១- ក្នុងការរៀបចំប្រឡង ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងគណៈកម្មការប្រឡងមួយ ឬច្រើន តាមការស្នើសុំរបស់ក្រុមប្រឹក្សាប្រឡង

២- គណៈកម្មការនីមួយៗ ត្រូវបង្កើតឡើងដោយមានការចូលរួមពីមន្ត្រីនាយកដ្ឋានកម្មសិទ្ធិបញ្ញា និង មន្ត្រីនាយកដ្ឋានបុគ្គលិកនៃក្រសួងពាណិជ្ជកម្ម

៣- សមាជិកច្រើនបំផុត ០៣ (បី) រូប របស់ក្រុមប្រឹក្សាប្រឡង អាចត្រូវបានតែងតាំងជាសមាជិករបស់គណៈកម្មការ។

## ប្រការ ១១ ៖ ភារកិច្ចរបស់គណៈកម្មការប្រឡង

គណៈកម្មការប្រឡង មានភារកិច្ចទទួលខុសត្រូវ ÷

១- រៀបចំវិញ្ញាសាប្រឡង ដោយអនុលោមទៅតាមការណែនាំរបស់ក្រុមប្រឹក្សា និង បញ្ជាក់ពីសារៈសំខាន់ពាក់ព័ន្ធរបស់សំណួរនីមួយៗ នៅពេលដែលចាំបាច់

២- ផ្តល់ចម្លើយនៃវិញ្ញាសាប្រឡង ជាមួយនឹងតារាងកំណត់ពិន្ទុ

៣- ប្រគល់ចម្លើយនិងពិន្ទុរបស់បេក្ខជនទៅអោយក្រុមប្រឹក្សា

៤- កិច្ចការផ្សេងៗទៀត ដែលប្រគល់ជូនដោយក្រុមប្រឹក្សា។

## ប្រការ ១២ ៖ លេខាធិការដ្ឋានប្រឡង

ក្រសួងពាណិជ្ជកម្ម នឹងផ្តល់ទីកន្លែង សម្ភាររដ្ឋបាលចាំបាច់ដែលបានមកពីការបង់ប្រាក់ឧបត្ថម្ភក្នុងការប្រឡង ទៅឱ្យក្រុមប្រឹក្សា និង គណៈកម្មការប្រឡង សម្រាប់បង្កើតលេខាធិការដ្ឋានប្រឡង។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីមែល: moccab@moc.gov.kh

## ប្រការ ១៣ : ភារកិច្ចរបស់លេខាធិការដ្ឋាន

១- លេខាធិការដ្ឋានត្រូវ:

- ជួយការងារក្រុមប្រឹក្សា និងគណៈកម្មការប្រឡង
- ផ្សព្វផ្សាយពតិមាន អំពីវគ្គបណ្តុះបណ្តាលត្រៀមប្រឡង
- ទទួលពាក្យសុំចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលត្រៀមប្រឡង និង ប្រឡង
- ត្រៀមមធ្យោបាយក្នុងការបង្រៀន និង ប្រឡង
- ចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យការប្រឡង
- បំពេញការងារផ្សេងៗតាមការណែនាំរបស់ក្រុមប្រឹក្សានិងគណៈកម្មការប្រឡង ។

២- លេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវចំពោះការបោះពុម្ពផ្សាយព័ត៌មានទាំងអស់ដែលបេក្ខជនត្រូវការ រួមមាន កាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះឈ្មោះ និងឯកសារដែលចាំបាច់នានា សម្រាប់ការដាក់ពាក្យ

៣- អនុលោមទៅតាមការណែនាំជាលាយលក្ខណ៍អក្សររបស់ក្រុមប្រឹក្សា លេខាធិការដ្ឋានប្រឡងនឹងសម្រេចអំពីការចុះឈ្មោះបេក្ខជន ។ លេខាធិការដ្ឋានត្រូវរៀបចំធ្វើការប្រឡង ហើយចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យការប្រឡង ។

## ប្រការ ១៤ : សេចក្តីជូនដំណឹងអំពីការប្រឡងជ្រើសរើស

សេចក្តីជូនដំណឹងអំពីការប្រឡងជ្រើសរើស ត្រូវផ្សព្វផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ និង ឬ បណ្តាញសារព័ត៌មាន ដែលបញ្ជាក់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះឈ្មោះ និង កាលបរិច្ឆេទនៃការប្រឡង និងឯកសារ ដែលតម្រូវ ។

## ប្រការ ១៥ : ពាក្យសុំចុះឈ្មោះប្រឡង

១- ពាក្យសុំចុះឈ្មោះប្រឡង ត្រូវដាក់នៅលេខាធិការដ្ឋានប្រឡង

២- ពាក្យសុំចុះឈ្មោះត្រូវបញ្ជាក់ពី គោត្តនាម នាមខ្លួន អាសយដ្ឋាន និង សញ្ជាតិ របស់បេក្ខជន និងត្រូវភ្ជាប់មកជាមួយនូវ ÷

ក- ភស្តុតាងបញ្ជាក់ពីលក្ខណៈសម្បត្តិ ដូចមានចែងក្នុងប្រការ ២១

ខ- លិខិតបញ្ជាក់ថា បានបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀមដោយជោគជ័យ ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម ។

## ប្រការ ១៦ : ការចុះឈ្មោះ និងសេចក្តីជូនដំណឹង

១- លេខាធិការដ្ឋានប្រឡងត្រូវជូនដំណឹងដល់បេក្ខជន អំពីការទទួលយក ឬការបដិសេធពាក្យសុំចុះឈ្មោះរបស់បេក្ខជន ។ ក្នុងករណីពាក្យស្នើសុំត្រូវបានបដិសេធ ត្រូវបញ្ជាក់ពីមូលហេតុ ។

២- កាលបរិច្ឆេទ ពេលវេលា និង ទីកន្លែង នៃការប្រឡង នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៩២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ១៧ ៖ អនាមិកភាព**

១- អនាមិកភាពនៃបេក្ខជននឹងត្រូវបានគោរព នៅពេលចម្លើយរបស់បេក្ខជនត្រូវបានដាក់ពិន្ទុ ។

២- ចម្លើយរបស់បេក្ខជនអាចត្រូវបានបោះពុម្ពផ្សាយ និងប្រើប្រាស់នៅពេលណាមួយ សម្រាប់ការស្រាវជ្រាវ សម្រាប់គោលបំណងស្ថិតិ ឬ ការបណ្តុះបណ្តាល ដោយគោរពអនាមិកភាពរបស់បេក្ខជន ។

**ប្រការ ១៨ ៖ លទ្ធផល**

១- ក្រសួងពាណិជ្ជកម្មនឹងរាយនាមនៅក្នុងបញ្ជីឈ្មោះ តាមលំដាប់ព្យញ្ជនៈរបស់បេក្ខជនដែលបានទទួលជោគជ័យក្នុងការប្រឡង ។

២- លេខាធិការដ្ឋានប្រឡងទទួលខុសត្រូវក្នុងការចងក្រង ផ្សព្វផ្សាយស្ថិតិ ស្តីពីលទ្ធផលនៃការប្រឡង ។ ក្រុមប្រឹក្សា នឹងសម្រេចអំពីព័ត៌មានដែលត្រូវផ្សព្វផ្សាយ ។

**ប្រការ ១៩ ៖ ការរក្សាការសម្ងាត់**

អនុលោមទៅតាមប្រការ១៧ សមាជិកក្រុមប្រឹក្សា សមាជិកគណៈកម្មការ និងបុគ្គលិកដែលធ្វើការនៅក្នុងលេខាធិការដ្ឋានប្រឡង ត្រូវរក្សាការសម្ងាត់ទាំងក្នុងអំឡុងពេល និងក្រោយពេលកាន់ការងារ នូវរាល់ព័ត៌មាន ទាំងអស់ និង ការពិភាក្សាណាមួយដែលធ្វើឡើងទាក់ទងនឹងបេក្ខជន ។

**ប្រការ ២០ ៖ ការបណ្តុះបណ្តាលត្រៀមប្រឡង**

១- បេក្ខជនដែលអាចចុះឈ្មោះចូលរៀនត្រៀមប្រឡង ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ ឬ លិខិតបញ្ជាក់ដែលមានតម្លៃស្មើ ដោយមានបញ្ជាក់ភាពត្រឹមត្រូវ ។

២- អ្នកចូលរៀនត្រៀមប្រឡងត្រូវដាក់ពាក្យស្នើសុំ និង បង់ថ្លៃចូលរៀន តាមការកំណត់របស់ក្រុមប្រឹក្សាប្រឡង ដើម្បីសម្រួលដល់ការចំណាយចាំបាច់នានា ។

៣- មន្ត្រីរបស់ក្រសួងពាណិជ្ជកមត្រូវបានលើកលែងក្នុងការបង់ថ្លៃចូលរៀន ។

៤- វគ្គបណ្តុះបណ្តាលត្រៀមប្រឡង ត្រូវប្រើប្រាស់ពេលយ៉ាងតិចហុកសិប (៦០) ម៉ោង ។

**ប្រការ ២១ ៖ លក្ខខណ្ឌចុះឈ្មោះប្រឡង**

១- បេក្ខជនដែលដាក់ពាក្យសុំចុះឈ្មោះប្រឡង ត្រូវបញ្ចប់វគ្គបណ្តុះបណ្តាលត្រៀម មុនកាលបរិច្ឆេទប្រឡង ដែលបានរៀបចំឡើងនៅចន្លោះពេលទៀងទាត់មួយ ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

២- មន្ត្រីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានចូលបម្រើការងារយ៉ាងតិច ៥ ឆ្នាំ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង ។

៣- បេក្ខជនទាំងឡាយដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ជំនាញកម្មសិទ្ធិបញ្ញា ឬខ្ពស់ជាង ដែលទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច និងមានបទពិសោធន៍ក្នុងការងារកម្មសិទ្ធិបញ្ញា ចំនួន ៥ ឆ្នាំយ៉ាងតិច



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

នៅក្នុងភ្នាក់ងារកម្មសិទ្ធិបញ្ញា ឬ ក្រុមហ៊ុនច្បាប់ ឬ ក្នុងការិយាល័យដែលទទួលបន្ទុកកម្មសិទ្ធិបញ្ញានៃក្រុមហ៊ុនណាមួយ ត្រូវបានលើកលែងក្នុងការចូលរៀនវគ្គត្រៀមប្រឡង។

៤- បេក្ខជនត្រូវដាក់ពាក្យស្នើសុំចុះឈ្មោះប្រឡង។ ក្រុមប្រឹក្សាប្រឡងជាអ្នកកំណត់តម្លៃពាក្យស្នើសុំចុះឈ្មោះប្រឡង ដើម្បីមានថវិកាទ្រទ្រង់ការចំណាយចាំបាច់នានាក្នុងដំណើរការប្រឡង។

៥- មន្ត្រីនៃក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង និង លេខាធិការដ្ឋាន ដែលកំពុងកាន់មុខតំណែង មិនមានសិទ្ធិចុះឈ្មោះប្រឡងទេ។ មន្ត្រីទាំងនោះនឹងមានសិទ្ធិចុះឈ្មោះប្រឡង បន្ទាប់ពីតំណែងរបស់ខ្លួនត្រូវបានបញ្ចប់។

## ប្រការ ២២ : កម្មវិធីសិក្សា និងការប្រឡង

កម្មវិធីសិក្សា និង ការប្រឡងសំដៅផ្តល់ ដល់បេក្ខជននូវចំណេះដឹងជ្រៅជ្រះពី ÷

១- សញ្ញាណជាមូលដ្ឋាននៃកម្មសិទ្ធិបញ្ញា

២- ច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជា ដែលរួមមាន : ច្បាប់ និងបទប្បញ្ញត្តិនានា ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និង ច្បាប់ និង បទប្បញ្ញត្តិនានា ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ របស់ព្រះរាជាណាចក្រកម្ពុជា។

៣- ច្បាប់កម្ពុជាដទៃទៀតដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍របស់ភ្នាក់ងារតំណាងស្របច្បាប់។

៤- កិច្ចព្រមព្រៀង អនុសញ្ញា សន្ធិសញ្ញាអន្តរជាតិ ដែលត្រូវបានចាត់ទុកដោយក្រុមប្រឹក្សាថា មានសារៈសំខាន់ចំពោះការអនុវត្តន៍ការងាររបស់ភ្នាក់ងារតំណាងស្របច្បាប់។

៥- ការអនុវត្តន៍ជាក់ស្តែងក្នុងការចុះបញ្ជី ការប្តឹងជំទាស់ និងដោះស្រាយវិវាទ កម្មសិទ្ធិបញ្ញា។

## ប្រការ ២៣ : វិញ្ញាសារប្រឡង

១- ការប្រឡងមានវិញ្ញាសារសរសេរ និង ឬ ផ្ទាល់មាត់។

២- ក្រុមប្រឹក្សានឹងសម្រេចអំពីវិញ្ញាសា និងរយៈពេលប្រឡង។ វិញ្ញាសាប្រឡងនឹងរៀបចំចេញពីកម្មវិធីសិក្សាដូចក្នុងប្រការ ២២។

## ប្រការ ២៤ : ការដាក់ពិន្ទុ

ក្រុមប្រឹក្សាត្រូវផ្តល់ការណែនាំដែលចាំបាច់ដល់គណៈកម្មការប្រឡង ដើម្បីធានាឱ្យប្រាកដថា ចម្លើយរបស់បេក្ខជនត្រូវបានដាក់ពិន្ទុតាមរបៀបតែមួយ។

## ប្រការ ២៥ : ការប្រឡងជាប់ជាស្ថាពរ

បេក្ខជន ដែលប្រឡងជាប់ជាស្ថាពរ នឹងត្រូវបានទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

## ប្រការ ២៦ : ករណីលើកលែងក្នុងការប្រឡង

អ្នកត្រួតពិនិត្យខ្លឹមសារម៉ាកលម្អិត ដែលមានបទពិសោធន៍ក្នុងការងារយ៉ាងតិចចំនួន ០៦ ឆ្នាំ និង មន្ត្រីជំនាញច្បាប់កម្មសិទ្ធិបញ្ញាដែលធ្លាប់បង្រៀនជំនាញកម្មសិទ្ធិបញ្ញាដល់បេក្ខជនត្រៀមប្រឡង ដែលទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម នឹងត្រូវចាត់ទុកថា មានគុណសម្បត្តិបច្ចេកទេសគ្រប់គ្រាន់ ដោយមិនបាច់ចូលរួមក្នុងការប្រឡង និងត្រូវបានចាត់ទុកថាប្រឡងជាប់ជាស្ថាពរ ។

## ប្រការ ២៧ : រយៈពេលនៃការទទួលស្គាល់

ការទទួលស្គាល់ភ្នាក់ងារតំណាងស្របច្បាប់ជារូបវន្តបុគ្គល មិនមានរយៈពេលកំណត់ឡើយ ។ ចំពោះនីតិបុគ្គលរយៈពេលនៃការទទួលស្គាល់នេះក៏គ្មានរយៈពេលកំណត់ដែរ ដរាបណានីតិបុគ្គលនោះ នៅតែមានរូបវន្តបុគ្គលជាភ្នាក់ងារតំណាង ឈរឈ្មោះអោយ ។

## ប្រការ ២៨ : ភ្នាក់ងារស្របច្បាប់នៃម្ចាស់ម៉ាកដែលមានស្រាប់

ដើម្បីធានាគុណភាពភ្នាក់ងារស្របច្បាប់នៃម្ចាស់ម៉ាក នីតិបុគ្គលទាំងឡាយណាដែលបានទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មកម្មសិទ្ធិបញ្ញា (Intellectual Property Automation System-IPAS) រួចហើយមុនប្រកាសនេះចូលជាធរមាន ត្រូវជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់ដែលជារូបវន្តបុគ្គលដើម្បីឈរឈ្មោះអោយក្នុងរយៈពេល ៥ ឆ្នាំ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ពុំនោះសោតទេ នីតិបុគ្គលទាំងឡាយនោះ នឹងបាត់បង់សិទ្ធិជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ។

## ប្រការ ២៩ : មោឃភាពនៃការទទួលស្គាល់

មោឃភាពនៃការទទួលស្គាល់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ត្រូវបានកំណត់ដូចខាងក្រោម ÷

១- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក សុំបញ្ចប់ការទទួលស្គាល់ដោយខ្លួនឯង ។

២- ទទួលបានការទទួលស្គាល់ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ដោយមធ្យោបាយក្លែងបន្លំណាមួយ ។

៣- លែងមាននិវេសនដ្ឋាន និងទីតាំងប្រកបអាជីវកម្ម ឬការងារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤- ប្រព្រឹត្តផ្ទុយនឹងច្បាប់ និង បទប្បញ្ញត្តិ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ ។

៥- ធ្វើឱ្យខូចប្រយោជន៍ធ្ងន់ធ្ងរដល់អ្នកដាក់ពាក្យសុំចុះបញ្ជីម៉ាក ឬអ្នកដែលមានសិទ្ធិលើម៉ាក ។

៦- មិនបានបង់ប្រាក់កម្រៃសមាជិកភាពប្រចាំឆ្នាំ ។

៧- ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក បាត់បង់សមត្ថភាព ឬ ទទួលមរណភាព ។

៨- ចំពោះនីតិបុគ្គល លែងមានរូបវន្តបុគ្គលជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឈរឈ្មោះអោយ ។



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ៣០ ៖ កម្រៃសម្រាប់ការចុះបញ្ជីទទួលស្គាល់ភ្នាក់ងារតំណាង**

ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកដែលទទួលស្គាល់ជាផ្លូវការ និងជារូបវន្តបុគ្គល ត្រូវបង់កម្រៃសមាជិកភាពរបស់ខ្លួនប្រចាំឆ្នាំ តាមប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម។

**ប្រការ ៣១ ៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣២ ៖**

នាយិកាខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១១

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចំលងជូន:**

- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ **ម៉ែន សំអន**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលាខេត្ត រាជធានី
- ដូចប្រការ ៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែល: moccab@moc.gov.kh

# ៥. ប្រកាសស្តីពី ការបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មាធិការប្រឡងសម្រាប់រៀបចំការប្រឡងជ្រើសរើសន្លាក់ខារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ៤៧៤ MOC / SM 2012

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមប្រឹក្សាប្រឡង គណៈកម្មការប្រឡង សម្រាប់រៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រម លេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- យោងប្រកាសលេខ ០៤៥ MOC / SM 2011 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.** បង្កើតក្រុមប្រឹក្សាប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់អាណត្តិ ៣ (បី)ឆ្នាំ ដំបូង ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១.ឯកឧត្តម | វ៉ា | រតសាន | ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ប្រធាន |
| ២.លោក | អ៊ុំ | សុថា | ប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៣.លោក | ស៊ឹម | សុខខេង | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិកអចិន្ត្រៃយ៍ |
| ៤.លោក | អប់ | វ៉ាឌី | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ៥.លោក | ង៉ោ | ធូ | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦.លោក | ហេង | សំបូរ | អនុប្រធានការិយាល័យនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |
| ៧.លោក | ខេង | បូរី | អនុប្រធានការិយាល័យនៃនាយកដ្ឋានបុគ្គលិក | សមាជិក |



ក្រសួងពាណិជ្ជកម្ម
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៩៧៨
ទូរសារលេខ: (៨៥៥) ២៣ ៨៦៦ ៩២៥
អ៊ីម៉ែល: moccab@moc.gov.kh

**ប្រការ ២.** បង្កើតគណៈកម្មការប្រឡង ជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើជាសេនាធិការឲ្យក្រុមប្រឹក្សាប្រឡង សម្រាប់អាណត្តិដំបូងនេះ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១.លោក | ស៊ឹម សុខខេង | អនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា | ប្រធាន |
| ២.លោក | ង៉ោ ធូ | អនុប្រធាននាយកដ្ឋានបុគ្គលិក | អនុប្រធាន |
| ៣.លោក | គឹម ធនសំណាង | អនុប្រធានការិ.នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា | លេខាធិការ |
| ៤.លោកស្រី | ឡាយ ចាន់ធឿន | អនុប្រធានការិ.នៃនាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥.លោក | លី ឡាមី | អនុប្រធានការិ.នៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា | សមាជិក |

**ប្រការ ៣.** ក្រុមប្រឹក្សាប្រឡង និងគណៈកម្មការប្រឡង ត្រូវបំពេញមុខងាររបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឲ្យបានសមស្របតាមនីតិវិធីជាធរមាន ធានាបាននូវប្រសិទ្ធភាព តម្លាភាព និងមានកាតព្វកិច្ចអនុវត្តឲ្យបានត្រឹមត្រូវនូវសិទ្ធិអំណាច ភារកិច្ចរបស់ខ្លួន ដូចមានចែងក្នុងប្រការ៧ ប្រការ៨ និងប្រការ១១ នៃប្រកាសលេខ ០៤៥ MOC / SM 2011 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៥.** ក្រុមប្រឹក្សាប្រឡងមានសិទ្ធិបង្កើតលេខាធិការដ្ឋានប្រឡង ដែលមានទីចាត់ការនៅក្នុងនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងអាចចាត់តាំងមន្ត្រីមួយចំនួនជាជំនួយការ តាមការចាំបាច់។

**ប្រការ ៦.** នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់អង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
-ដូចប្រការ៦
-ឯកសារ-កាលប្បវត្តិ



**ក្រសួងពាណិជ្ជកម្ម**
លេខ ១៩-៦១ ផ្លូវក្រសួងពាណិជ្ជកម្ម (ផ្លូវ១១៣បេ)
ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៨៦៦ ០៨៨/៨៦៦ ៤៧៨
ទូរសារលេខៈ (៨៥៥) ២៣ ៨៦៦ ៤២៥
អ៊ីម៉ែលៈ moccab@moc.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
**នាយកដ្ឋានកម្មសិទ្ធិបញ្ញា**
**និងនាយកដ្ឋានបុគ្គលិក**

# កំណត់បង្ហាញ

**ខ្លឹមសារសង្ខេប ៖** ការរៀបចំប្រកាសស្តីពីការបង្កើត ក្រុមប្រឹក្សា និងគណៈកម្មការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា។

| **យោបល់អន្តរនាយកដ្ឋានកម្មសិទ្ធិបញ្ញា និងនាយកដ្ឋានបុគ្គលិក** | **មតិសម្រេចរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម** |
|---|---|
| **គោរពជូន**<br>**ឯ.ឧ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ**<br>**និងឯ.ឧ អគ្គនាយកពាណិជ្ជកម្មក្នុងប្រទេស**<br><br>ដើម្បីចាត់តាំងអនុវត្តឲ្យបានត្រឹមត្រូវតាមប្រកាស លេខ ០៩៥ MOC / SM2011 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ពិសេស ខ្លឹមសារនៃប្រការ៥ រហូតដល់ប្រការ ១៣ នៃប្រកាសនេះ និងក្នុងគោលដៅពង្រឹងប្រសិទ្ធភាព នៃការអនុវត្តនីតិវិធីច្បាប់ដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា<br><br>នាយកដ្ឋានកម្មសិទ្ធិបញ្ញា រួមសហការជាមួយនាយកដ្ឋានបុគ្គលិក បានរៀបចំជា *ប្រកាស ស្តីពីការការបង្កើតក្រុមប្រឹក្សាប្រឡងគណៈកម្មការប្រឡង សម្រាប់រៀបចំការប្រឡងជ្រើសរើសភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក* ដូចមានខ្លឹមសារនៃសេចក្តីព្រាង ចំនួន ០១ច្បាប់ គោរពជូនភ្ជាប់ជាមួយនេះ។<br><br>គោរពជូន ឯកឧត្តម មេត្តាជ្រាប និងពិនិត្យ ដើម្បីស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមទេសរដ្ឋមន្ត្រី។<br><br>រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១២<br>ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា ប្រធាននាយកដ្ឋានបុគ្គលិក | 10/10/12 |

| **យោបល់ឯ.ឧ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ** |
|---|
| [illegible handwritten comment]<br>8 តុលា 2012 |

4513
oct 8/12

# ៦. ប្រកាសរួមស្តីពី ការកែប្រែកម្រងសេវាសាធារណៈនៃ តារាងឧបសម្ព័ន្ធភ្ជាប់នឹងការប្រកាសរួមលេខ ៩៨៥ សហវ ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០១៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៤៤១១ ព.ណ.ករ.......

ថ្ងៃ អង្គារ ៦រោច ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាប្រធាន ក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈ ជនទាំងអស់មេត្តាជ្រាបថា៖ ក្រសួងពាណិជ្ជកម្ម នឹងចាប់ផ្តើមអនុវត្តប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ចាប់ពី***ថ្ងៃចន្ទ ១៥កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨***តទៅ។ តារាងស្តីពីសេវាសាធារណៈនេះ មានបិទផ្សាយនៅទីស្តីការក្រសួងពាណិជ្ជកម្ម តាមបណ្តានាយកដ្ឋានជំនាញ បញ្ជរបង់ប្រាក់រួមក្រសួងពាណិជ្ជកម្ម និងតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម www.moc.gov.kh ។

ជាមួយគ្នានេះដែរ ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនបន្ថែមថា៖

១-ក្រសួងពាណិជ្ជកម្ម នឹងបន្តអនុវត្តប្រកាសរួមលេខ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈ នៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ***រហូតដល់ថ្ងៃអាទិត្យ ១៤កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧*** ។

២-ក្រុមហ៊ុន សហគ្រាស និងអ្នកនាំចេញ ដែលបាននាំចេញទំនិញពីកម្ពុជា ហើយមិនតម្រូវការវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ គឺត្រូវបន្តអនុវត្តខ្លឹមសារប្រកាសរួមលេខ២៣៣ ព.ណ បអព.ប្រក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនីតិវិធីក្នុងការបំពេញបែបបទនាំចេញទៅក្រៅប្រទេស ដើម្បីក្រសួងពាណិជ្ជកម្មមានមូលដ្ឋានស្រង់ស្ថិតិ និងធ្វើការកាត់សន្និធិវត្ថុធាតុដើមនាំចូលប្រចាំខែរបស់ក្រុមហ៊ុន សហគ្រាស ។

អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ដែលជាប្រធានក្រុមហ៊ុន សហគ្រាស អាជីវកម្ម គ្រប់ប្រភេទ និងសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន ។

សូមអរគុណ!

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ...សហវ...

# ប្រកាសរួម
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួល អនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ស្ទួននៃអនុក្រឹត្យលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រើសារពើពន្ធ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្មអនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈសម្រាប់ជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ ._**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមនេះ។

**ប្រការ៣ ._**

ក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសរួម និងកម្រងសេវាសាធារណៈដែលរួមមានឧបសម្ព័ន្ធនៃប្រកាសរួមនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៤ .–**

ក្រសួងពាណិជ្ជកម្ម ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្ម ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

ដោយឡែកចំពោះការផ្តល់សេវាសាធារណៈរបស់មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមយន្តការ និងនីតិវិធីដែលមានស្រាប់រហូតដល់មានការប្រមូលផ្តុំសេវាឱ្យធ្វើឡើងតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៥ .–**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៦ .–**

រដ្ឋបាលកណ្តាលក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមសមត្ថកិច្ចប្រមូលចំណូលរៀងៗខ្លួន។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៧ .–**

ក្រសួងពាណិជ្ជកម្មត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងពាណិជ្ជកម្ម និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៨ ._**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសរួមនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៩ ._**

ត្រូវបាននិរាករណ៍ប្រកាសរួម ដូចខាងក្រោម ÷

- ប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- ប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការកែប្រែកម្រងសេវាសាធារណៈនៃតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ៩៨៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសរួមនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ ._**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០១៧

**នេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

កន្លែងទទួល ៈ

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ...០៦៤០១៧.... សហវ.ប្រក ចុះថ្ងៃទី...២៧.... ខែ...មិថុនា... ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | I. អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម | | | |
| | **នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម** | | | |
| | ក. ការសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | | | |
| ១ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ១ ៦៨០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ២ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលត្រូវចុះបញ្ជី | ៣០០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| | ខ. ការសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | |
| ៣ | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | ៤៨០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៤ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១៥០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| | គ. ការសុំចុះបញ្ជីកែប្រែ | | | |
| | ១ ក្រុមហ៊ុនពាណិជ្ជកម្ម | | | |
| ៥ | - ការកែប្រែផ្លាស់ប្តូរភាគហ៊ុន ការបន្ថយដើមទុន ការបង្កើនដើមទុន | ៨០០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៦ | - ការកែប្រែផ្សេងៗ(អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍ តម្កល់លក្ខន្តិកៈ ទីស្នាក់ការ ។ល។) | ២៤០ ០០០ ៛ | ៣-៧ ថ្ងៃ | |
| ៧ | - ពិន័យករណីមិនបានបំពេញបែបបទក្នុងការផ្លាស់ប្តូរ កែប្រែផ្សេងៗ នៅក្រសួងពាណិជ្ជកម្ម | ១ ០០០ ០០០ ៛ | | ១ ដង |
| ៨ | - ការបង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | ៤៨០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |
| ៩ | ២ សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលបានចុះបញ្ជី | ១០០ ០០០ ៛ | ៣-៧ ថ្ងៃ | ៩៩ ឆ្នាំ |

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| | ឃ. ការតម្កល់ប្រតិវេទីប្រចាំឆ្នាំ | | | |
| ១០ | ១ សេវាតម្កល់ប្រតិវេទ៍ប្រចាំឆ្នាំ | ៨០ ០០០ ៛ | ១ ថ្ងៃ | ១ ឆ្នាំ |
| ១១ | ២ ការពិន័យចំពោះការមិនតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំ | ២ ០០០ ០០០ ៛ | | |
| ១២ | ង. ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម | ៨០ ០០០ ៛ | ៣ ថ្ងៃ | |
| ១៣ | ច. ទទួលពាក្យស្នើសុំអនុវត្តដីការរក្សាការពារ និងទទួលពាក្យសម្របសម្រួលដោះស្រាយវិវាទ | ១ ០០០ ០០០ ៛ | ១ ថ្ងៃ | |
| ១៤ | ឆ. ការពិនិត្យនាមករណ៍ក្រុមហ៊ុន សហគ្រាស | ៤០ ០០០ ៛ | ១ ថ្ងៃ | ៣ ខែ |
| ១៥ | ជ. លិខិតបញ្ជាក់ផ្សេងៗ ផ្ទេរសិទ្ធិអ្នកប្រើប្រាស់ប្រព័ន្ធ (តាមការស្នើសុំ) | ១៦០ ០០០ ៛ | ៣-៥ ថ្ងៃ | ១ ដង |
| ១៦ | ឈ. ការទាញយកវិញ្ញាបនបត្រ ឬ ការទាញយកសម្រង់ព័ត៌មាន ជាថ្មីទៀតពីប្រព័ន្ធស្វ័យប្រវត្តកម្ម | ៨០ ០០០ ៛ | | ១ ដង |
| ១៧ | ញ. ការផាកពិន័យលើការក្លែងបន្លំឯកសារតម្រូវសម្រាប់ការចុះបញ្ជី | ១ ០០០ ០០០ ៛ | | ១ ដង |
| | ដ. ការងារពិគ្រោះយោបល់ផ្នែកច្បាប់ (តាមការស្នើសុំ) | | | |
| ១៨ | ១ សេវាពិគ្រោះយោបល់ចុះបញ្ជីពាណិជ្ជកម្ម ÷ | ៤០០ ០០០ ៛ | ១ ថ្ងៃ | |
| | - ពិនិត្យ និងបញ្ជាក់លើភាពស្របច្បាប់នៃឯកសារតម្រូវសម្រាប់ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | | | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យា ឬ លក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យ និងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ការបកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែលក្ខន្តិកៈ ក្រុមហ៊ុនដែលមានការចាំបាច់ | | | |

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
| --- | --- | --- | --- | --- |
| ១៩ | ២ សេវាពិគ្រោះយោបល់ផ្នែកច្បាប់ទាក់ទងនឹងការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ÷ | ២០០ ០០០ ៛ | ១ ថ្ងៃ | |
| | - បញ្ជាក់ពីអនុលោមភាពនៃច្បាប់លើការរៀបចំខ្លឹមសារនៃកិច្ចសន្យាឬលក្ខន្តិកៈបង្កើតក្រុមហ៊ុន | | | |
| | - ពិនិត្យនិងបញ្ជាក់លើសុពលភាពនៃសិទ្ធិប្រាតិភោគលើភាគហ៊ុនរបស់ក្រុមហ៊ុន | | | |
| | - ជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់បកប្រែភាសាលើឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារកែប្រែលក្ខន្តិកៈក្រុមហ៊ុនដែលមានការចាំបាច់ | | | |
| ២០ | ៣ សេវារៀបចំលក្ខន្តិកៈក្រុមហ៊ុន(ចុះបញ្ជីពាណិជ្ជកម្មថ្មី និងការកែប្រែលក្ខន្តិកៈ) | ៤០០ ០០០ ៛ | ២ ថ្ងៃ | |

# ៧. សេចក្តីជូនដំណឹងស្តីពី ការកត់ត្រាទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ០៧៣៨ ព.ណ.ករ

ភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការកត់ត្រាទទួលស្គាល់កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ និងកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស

ក្រសួងពាណិជ្ជកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងម្ចាស់ម៉ាកទាំងអស់ឲ្យបានជ្រាបថា អនុលោមតាមមាត្រា ១៩ និងមាត្រា ៥២ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងមាត្រា ២៧(៣) នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ រាល់ការដាក់ពាក្យស្នើសុំកត់ត្រាទទួលស្គាល់កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ (License Contract) ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស (Franchise Contract) ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ដូចមានគំរូពាក្យស្នើសុំជូនភ្ជាប់ ។ អ្នកស្នើសុំ ត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេសជាច្បាប់ដើម និងអមដោយអត្ថបទបកប្រែជាភាសាខ្មែរ ដែលត្រូវបញ្ជាក់ពីភាពត្រឹមត្រូវលើការបកប្រែទាំងនោះ ដោយភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ឬអង្គភាពវិជ្ជាជីវៈបកប្រែដែលទទួលស្គាល់ពីក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមសាធារណជន និងម្ចាស់ម៉ាកទាំងអស់ ត្រូវអនុវត្តតាមសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ។

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
**Nation - Religion - King**

គំរូទំរង់លេខ: ០៣៧
Form: 037-RRL/FC-Eng
កម្ពុជា *CAMBODIA*

*ជូនចំពោះ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួងពាណិជ្ជកម្ម*
*(To: Department of Intellectual Property, Ministry of Commerce)*

# ពាក្យស្នើសុំកត់ត្រាកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ/កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស
## *REQUEST FOR RECORDAL OF LICENSE CONTRACT/FRANCHISE CONTRACT*

១ - ម៉ាក (Mark):

២ - ជំពូក (Class):

៣ - លេខដាក់ពាក្យ (Application Number):

៤ - លេខចុះបញ្ជីដើម (Original Registration Number):

៥ - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកផ្តល់អាជ្ញាប័ណ្ណ (Name and Address of Licensor/Franchisor): ________________
______________________________________________________________

៦ - ឈ្មោះ និងអាសយដ្ឋានរបស់អ្នកទទួលអាជ្ញាប័ណ្ណ (Name and Address of Licensee/Franchisee): ________________
______________________________________________________________

៧ - ឈ្មោះរបស់ភ្នាក់ងារ/មេធាវី តំណាងក្នុងស្រុក និងអាសយដ្ឋានសំរាប់ទំនាក់ទំនង (Name of Local Agent/Attorney and Address for Service): ______________________________________________
______________________________________________________________

ទូរស័ព្ទ (Tel):________________ ទូរសារ (Fax):________________ អ៊ីម៉ែល (Email)________________________

៨ - ឯកសារដែលត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ (Documents Accompanying the Application):

- កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេសច្បាប់ដើម ឬច្បាប់ចម្លងដែលមានបញ្ជាក់ភាពត្រឹមត្រូវ (Original License/Franchise Contract or Notarized Copy thereof)
- ការបកប្រែកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ ឬកិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណពិសេស ពីភាសាអង់គ្លេស ទៅភាសាខ្មែរ (Translation of License/Franchise Contract from English to Khmer)
- លិខិតប្រគល់សិទ្ធិ និងលិខិតប្រគល់សិទ្ធិបន្តច្បាប់ដើម ប្រសិនបើភ្នាក់ងារ/មេធាវី តំណាងត្រូវបានជ្រើសតាំងថ្មី (Original Notarized Power of Attorney and Deed of Substitution, if the Agent/Attorney is newly appointed)
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកដើមថតចម្លង ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មីថតចម្លង (A Copy of Principal Mark Registration or Renewal Certificate)

ហត្ថលេខា និងត្រា (Signature and Stamp): ________________________

ឈ្មោះហត្ថលេខី (Name of Signatory): ________________________

មុខងារ (Title):________________________

កាលបរិច្ឆេទ (Date): ________________________

# ៨. សារាចរណែនាំស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាក ឆ្នាំ២០១៥

1835
12/08/15

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧ សរណន

ក្រសួងពាណិជ្ជកម្ម
លេខ 6274 ចូល
ថ្ងៃ 12 ខែ 08 ឆ្នាំ ២០១៥ ម៉ោង......
បញ្ជូនទៅ ......

# សារាចរណែនាំ
## ស្ដីពី
## ការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក

អនុលោមតាម ព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងសំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃ ដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និងការនាំចូលនិងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍវិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា រាជរដ្ឋាភិបាលសូមធ្វើការណែនាំអំពីការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ដូចតទៅ៖

១- សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកលើមុខទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្ដីពី ការអនុវត្តច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ជាធរមាន។

២- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលដៅមិនធ្វើពាណិជ្ជកម្ម ឬសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍ និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ ឬទំនិញប្រើរួចគ្រប់ប្រភេទ មិនស្ថិតក្រោមវិសាលភាពអនុវត្តនៃការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខឡើយ។

៣- ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការកត់ត្រាទទួលស្គាល់លិខិតប្រគល់សិទ្ធិនាំចូលជាទំនិញពាក់ម៉ាកផ្ដាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន។

៤- អ្នកទិញយកទៅប្រើប្រាស់ ឬដេប៉ូលក់ចែកចាយបន្ត អាចទិញទំនិញពីអ្នកចែកចាយប្រចាំបណ្ដាខេត្ត រាជធានី ឬតំបន់ផ្សេងទៀត ក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានការរើសអើង។ ក្នុងករណីដែលក្រសួងមានសមត្ថកិច្ចរកឃើញថា ក្រុមហ៊ុនណាមួយអនុវត្តផ្ទុយនឹងការណែនាំនេះ នឹងត្រូវបានធ្វើមោឃភាពនូវលិខិតទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬទទួលទោសប្បញ្ញត្តិចែងក្នុងមាត្រាច្បាប់ជាធរមាន។

៥- ក្រសួងពាណិជ្ជកម្ម ត្រូវចេញប្រកាសកំណត់នីតិវិធីលម្អិតស្ដីពី ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខឲ្យមានអនុលោមភាពតាមកិច្ចព្រមព្រៀងអន្តរជាតិ បញ្ញត្តិនៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន និងស្របតាមសារាចរណែនាំនេះ សំដៅធានាឲ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខ និងបម្រើឲ្យផលប្រយោជន៍របស់អ្នកប្រើប្រាស់ និងសាធារណជនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦- ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបណ្ដាក្រសួង ស្ថាប័ន ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចុះណែនាំដល់ក្រុមហ៊ុន អាជីវករ និងប្រជាជន អំពីខ្លឹមសារសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវផ្សព្វផ្សាយឲ្យបានទូលាយ និងអនុវត្តក្នុងដែនសមត្ថកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាព និងប្រកបទៅដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ[illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ៩. ប្រកាសស្តីពី នីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់ លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ព័ន្ធម៉ាកផ្តាច់មុខ

## ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
*Ministry of Commerce*

លេខ ១៥៤ ព.ណ. ការ.ប. ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីសម្រាប់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ/បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
- យោងតាមការងារចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងសំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និងការនាំចូល និងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា។

## ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅ៖

១- កំណត់នីតិវិធីលម្អិតសម្រាប់ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និង ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

២- កំណត់វិសាលភាពនៃ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និង ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

៣- កំណត់គោលការណ៍ក្នុងការបែងចែកទំនិញពាក់ម៉ាកផ្តាច់មុខនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៤- កំណត់នីតិវិធីដោះស្រាយវិវាទស្តីពី សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

៥- ចូលរួមចំណែកក្នុងការទប់ស្កាត់អំពើគេចពន្ធ ប្រមូលកម្រៃសេវាសាធារណៈ និងចំណូលពន្ធជូនរដ្ឋតាមបទប្បញ្ញត្តិជាធរមាន ។

## ប្រការ ៣.- វិសាលភាព

១- ប្រកាសនេះ មានវិសាលភាពអនុវត្តលើ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ សម្រាប់ទំនិញដែលបានចុះបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានកំណត់ក្នុងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ។

២- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខគ្របដណ្តប់តែទៅលើទំនិញសុទ្ធនិងថ្មី ដែលមិនទាន់បានដាក់លក់ជាលើកដំបូងក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.- និយមន័យ

១- "ការប្រគល់សិទ្ធិផ្តាច់មុខ" គឺជាការចេញលិខិតប្រគល់សិទ្ធិផ្តាច់មុខដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជូនទៅអ្នកទទួលសិទ្ធិដែលជានីតិបុគ្គលសម្រាប់នាំចូលទំនិញពាក់ម៉ាកផ្តាច់មុខមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- "ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ" គឺជាការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខដោយក្រសួងពាណិជ្ជកម្ម ផ្អែកតាមការស្នើសុំរបស់នីតិបុគ្គលដែលបានទទួលសិទ្ធិផ្តាច់មុខពីម្ចាស់ម៉ាក។

**ប្រការ ៥.- ពាក្យសព្ទ**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- "**លិខិតប្រគល់សិទ្ធិផ្តាច់មុខ**" សំដៅដល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខចេញដោយម្ចាស់ម៉ាកជូនទៅអ្នកទទួលសិទ្ធិ ដែលមានបញ្ជាក់ច្បាស់លាស់អំពី ម៉ាក ជំពូក និងប្រភេទនៃទំនិញ។

២- "**លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ**" សំដៅដល់លិខិតទទួលស្គាល់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជាដែលចេញដោយក្រសួងពាណិជ្ជកម្ម។

៣- "**ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក**" សំដៅដល់ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកសម្រាប់នាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ក្រោយពីទទួលបានពីការចុះបញ្ជីម៉ាករួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំដោយម្ចាស់ម៉ាកខ្លួនឯង ។

**ប្រការ ៦.- ទំនិញដែលមិនអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ**

ទំនិញដែលមិនអនុញ្ញាតឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខមានដូចខាងក្រោម៖

១- ទំនិញដែលបានប្រើរួចគ្រប់ប្រភេទ

២- ផលិតផលឱសថ

៣- មុខទំនិញហាមឃាត់ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៧.- ទំនិញជាប់កម្រិតកំណត់**

ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន ។

**ប្រការ ៨.- ការកម្រិតសិទ្ធិដែលទទួលបានពីការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ**

១- ម្ចាស់ម៉ាកដែលទទួលបានលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬអ្នកដែលទទួលបានលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា មិនមានសិទ្ធិហាមឃាត់លើការនាំចូលនូវមុខទំនិញដូចខាងក្រោម៖

ក- ទំនិញដែលនាំចូលយកមកប្រើប្រាស់ដោយព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

ខ- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅមិនធ្វើពាណិជ្ជកម្មនិងសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ និងទំនិញប្រើរួចគ្រប់ប្រភេទ។

២- បុគ្គល អង្គការ អង្គទូត និងក្រសួង ស្ថាប័ន ដែលមានបំណងនាំចូលទំនិញដូចមានចែងក្នុងប្រការ៨(១) ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ដោយមានភ្ជាប់មកជាមួយនូវឯកសារយោងដូចខាងក្រោម៖

ក- លិខិតអនុញ្ញាតពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំពោះអង្គទូត និងអង្គការអន្តរជាតិ ឬលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃចំពោះអង្គការ ឬសហគមន៍ក្នុងស្រុក ឬលិខិតអនុញ្ញាតពីក្រសួងអាណាព្យាបាល ដែលមានបញ្ជាក់ពីបរិមាណ និងម៉ូដែល ព្រមទាំងគោលបំណងយកមកប្រើប្រាស់ ។

ខ- មុននឹងធ្វើការនាំចូលត្រូវមានកិច្ចសន្យាទិញ លក់ និង/ឬ វិក្កយបត្រប្រូហ្វ៉រម៉ា (Pro-forma) ឬឯកសារពាណិជ្ជកម្មដែលមានតម្លៃប្រហាក់ប្រហែល ។

គ- ក្រោយការនាំចូលត្រូវផ្តល់នូវវិក្កយបត្រទិញ លក់ និង/ឬ តារាងបញ្ជាក់អំពីបញ្ជីវេចខ្ចប់ (Packing list) និង/ឬ អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading) និងប្រតិវេទន៍គយ (Customs Declaration) ។

៣- បន្ទាប់ពីចេញលិខិតអនុញ្ញាតនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដែលទទួលបានការលើកលែងក្នុងប្រការ៨ដោយលើកលែងចំណុច៤នៃប្រការនេះ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅរដ្ឋបាលគយនិងរដ្ឋាករនិងអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងជូនដំណឹងទៅអ្នកដែលបានទទួលសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដើម្បីជួយសម្រួលដល់ការនាំចូល។

៤- មិនតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតនាំចូលឡើយ ចំពោះទំនិញនិងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលគ្មានលក្ខណៈពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ៩.- សិទ្ធិដែលទទួលបានពីការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

១- សិទ្ធិនាំចូលនិងចែកចាយទំនិញពាក់ម៉ាកផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់តាមរយៈការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

២- អ្នកទទួលសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ មានសិទ្ធិប្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ចំពោះបុគ្គលណាដែលបាននាំចូលនិងចែកចាយទំនិញស្របគ្នាដោយបំពាននូវសិទ្ធិរបស់ខ្លួន ដើម្បីរកដំណោះស្រាយដូចមានចែងក្នុងប្រការ១៨ នៃប្រកាសនេះ ។

៣- សិទ្ធិនាំចូលនិងចែកចាយទំនិញពាក់ម៉ាកផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផុតរលត់វិញ នៅពេលដែលទំនិញពាក់ម៉ាកផ្តាច់មុខនីមួយៗនោះ ត្រូវបានលក់និងទូទាត់រួចរាល់លើកដំបូងនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១០.- បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិផ្តាច់មុខលើម៉ាក

១- សិទ្ធិផ្តាច់មុខលើម៉ាក

ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវយកម៉ាករបស់ខ្លួនមកធ្វើការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមមាត្រា៣ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ សិទ្ធិប្រើប្រាស់ម៉ាករួមមាន ការផលិត ការផ្សព្វផ្សាយ ការលក់ ការនាំចេញ ការនាំចូលជាដើម ដូចមានកំណត់ក្នុងមាត្រា១១ ២៤ និង ៦៦ នៃច្បាប់ខាងលើ។ សិទ្ធិផ្តាច់មុខដែលទទួលបានពីការចុះបញ្ជី អាចផ្ទេរទៅភាគីណាមួយ ដោយមានការយល់ព្រមពីម្ចាស់ម៉ាក និងធ្វើការកត់ត្រានិងតម្កល់នៅក្រសួងពាណិជ្ជកម្ម។

២- គោលការណ៍ផុតរលត់សិទ្ធិ (Exhaustion of Rights)

ក- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មិនត្រូវបានរាប់បញ្ចូលការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ម៉ាក ឬដោយបុគ្គលដែលមានការយល់ព្រមពីម្ចាស់ម៉ាកនោះឡើយ ដូចបានកំណត់ក្នុងមាត្រា១១(គ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលកម្ពុជាបានកំណត់យកគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ (National Exhaustion of Rights)។

ខ- ផ្អែកតាមគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬអ្នកទទួលសិទ្ធិដែលបានកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខមានសិទ្ធិប្តឹងរារាំងការនាំចូលស្របគ្នា (Parallel Importation) នូវទំនិញពាក់ម៉ាកដូចគ្នា ដោយភាគីទីបី។

## ប្រការ ១១.- នីតិវិធីកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

បុគ្គលដែលស្នើសុំការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមនីតិវិធីដូចខាងក្រោម៖

១- លក្ខខណ្ឌ

ក. បុគ្គលដែលអាចទទួលបាននូវការប្រគល់សិទ្ធិផ្តាច់មុខ ត្រូវមានទ្រង់ទ្រាយជានីតិបុគ្គល (អ្នកទទួលសិទ្ធិ) ។

ខ. ការប្រគល់សិទ្ធិផ្តាច់មុខត្រូវធ្វើឡើងតាមការព្រមព្រៀង រវាងអ្នកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយភាគីអ្នកប្រគល់សិទ្ធិ និងត្រូវបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខាក្នុងនាមអ្នកប្រគល់សិទ្ធិដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស ឬក្រសួងយុត្តិធម៌ ។

គ. ក្នុងករណីដែលម្ចាស់ម៉ាកមិនបានប្រគល់សិទ្ធិផ្តាច់មុខដោយផ្ទាល់ទៅអ្នកទទួលសិទ្ធិក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកទទួលសិទ្ធិដែលចង់ប្រគល់សិទ្ធិបន្ត ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម ដែលមានចែងអំពីសិទ្ធិប្រគល់សិទ្ធិបន្តទៀត។

ឃ. អ្នកទទួលសិទ្ធិ អាចដាក់ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៣(បី)ខែយ៉ាងយូរគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិ ។

ង. ការដាក់ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវបង់កម្រៃសេវាសាធារណៈទៅតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ ។

ច. ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ អាចធ្វើទៅបានលុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅអ្នកស្នើសុំ ក្នុងករណីដែលមិនអាចធ្វើការកត់ត្រាបាន ឬតម្រូវឲ្យបំពេញឯកសារបន្ថែម ។

ឆ. ទំនិញពាក់ម៉ាកផ្តាច់មុខដែលបានកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅក្រសួងពាណិជ្ជកម្មរួចហើយ មិនអាចអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់ជូនបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែការប្រគល់សិទ្ធិផ្តាច់មុខនោះ ត្រូវបានដកហូត ឬផុតសុពលភាព។

ជ. ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ លើទំនិញតែមួយនិងពាក់ម៉ាកដូចគ្នាក៏ប៉ុន្តែមានយថាប្រភេទខុសគ្នា អាចអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន លុះត្រាតែមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម។

ឈ.ការប្រគល់សិទ្ធិផ្តាច់មុខ នឹងគ្មានអានុភាពចំពោះអ្នកទទួលសិទ្ធិ និងភាគីទីបីឡើយ ប្រសិនបើលិខិតប្រគល់សិទ្ធិផ្តាច់មុខមិនបានយកមកធ្វើការកត់ត្រានិងតម្កល់ឲ្យបានត្រឹមត្រូវតាមប្រកាសនេះ ។

២- ឯកសារតម្រូវ

ក. ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវប្រើប្រាស់លិខិតផ្លូវការរបស់ក្រុមហ៊ុន និងត្រូវចុះហត្ថលេខា និងប្រថាប់ត្រាដោយអ្នកទទួលសិទ្ធិក្នុងស្រុក ឬម្ចាស់ម៉ាក។

ខ. លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពី៖

១. ឈ្មោះអ្នកប្រគល់សិទ្ធិ ឬ/និងអ្នកប្រគល់សិទ្ធិបន្ត និងអាសយដ្ឋានត្រឹមត្រូវតាមវិញ្ញាបនបត្រចុះបញ្ជីម៉ាក

២. ឈ្មោះនីតិបុគ្គលនិងទីស្នាក់ការក្រុមហ៊ុននៃអ្នកទទួលសិទ្ធិ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

៣. កម្មវត្ថុនៃការប្រគល់សិទ្ធិផ្តាច់មុខត្រូវបញ្ជាក់អំពី ម៉ាក លេខចុះបញ្ជី ជំពូក និងប្រភេទនៃទំនិញ

៤. ប្រទេស ឬដែនដីគ្របដណ្តប់ដោយសិទ្ធិដែលបានប្រគល់

៥. កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តនៃលិខិតប្រគល់សិទ្ធិ

៦. សុពលភាពដោយមិនឲ្យលើសពីរយៈពេល១០ឆ្នាំ

៧. ឈ្មោះ និងហត្ថលេខារបស់អ្នកប្រគល់សិទ្ធិ ព្រមទាំងកាលបរិច្ឆេទ ។

គ. ឯកសារភ្ជាប់មកជាមួយនឹងពាក្យស្នើសុំ៖

១. ច្បាប់ដើមនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ចំនួន០១ច្បាប់ ។

២. លិខិតអនុញ្ញាតឲ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលចំពោះមុខទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន ។

៣. ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកចំនួន ០១ច្បាប់ ។

៤. ច្បាប់ចម្លងនៃលក្ខន្តិកៈក្រុមហ៊ុន គោលការណ៍ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន០១ច្បាប់ ។

៥. ច្បាប់ចម្លងនៃប័ណ្ណប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់នីតិបុគ្គលចំនួន០១ច្បាប់ ។

៦. វិក្កយបត្របង់ប្រាក់កម្រៃសេវាសាធារណៈ ។

## ប្រការ ១២.- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក

១. តាមការស្នើសុំដោយស្ម័គ្រចិត្តពីម្ចាស់ម៉ាក ក្រសួងពាណិជ្ជកម្មអាចធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក សម្រាប់សម្រួលដល់ការនាំចូលនិងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ការស្នើសុំលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ម្ចាស់ម៉ាកត្រូវបំពេញតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ៣ ប្រការ៥ចំណុច៣ ប្រការ៦ និង/ឬ ប្រការ៧ ប្រការ៨ និងប្រការ១១ ចំណុច១(ង) ចំណុច២(ក) និងចំណុច២(គ) ដោយលើកលែងចំណុច២(គ)(១) នៃប្រការនេះ។

## ប្រការ ១៣.- សុពលភាព ភារកិច្ច និងសិទ្ធិ

១- សុពលភាព

ក- លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា មានសុពលភាព២(ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ខ- សុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា អាចមានរយៈពេលខ្លីជាង២(ពីរ)ឆ្នាំ ដោយផ្អែកតាមសុពលភាពអប្បបរមារបស់លិខិតណាមួយនៃ លិខិតប្រគល់សិទ្ធិផ្តាច់មុខ វិញ្ញាបនបត្រចុះបញ្ជីម៉ាក និងលិខិតអនុញ្ញាតឲ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬរាជរដ្ឋាភិបាល។

២- កាតព្វកិច្ច

ក- ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ ត្រូវបោះពុម្ពផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់ផ្តាច់មុខ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន៣(បី)លេខជាប់ៗគ្នា ។ ក្នុងករណីចាំបាច់ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ អាចបញ្ជូនច្បាប់ចម្លងនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខទៅអ្នកនាំចូលដោយផ្ទាល់ ដើម្បីអ្នកនាំចូលបានជ្រាបជាព័ត៌មាន ។

ខ- នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនោះ ក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និង/ឬ ក្នុងគេហទំព័រ www.cambodiaip.gov.kh ។

គ- អ្នកនាំចូលទំនិញតែមួយ ពាក់ម៉ាកដូចគ្នាទៅនឹងទំនិញដែលមានលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខរួចហើយ ត្រូវបញ្ចប់ប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន រួមទាំងទំនិញដែលស្តុកទុកក្នុងឃ្លាំងក្នុងរយៈពេល៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។

៣- សិទ្ធិ

ចាប់ពីរយៈពេល៩០(កៅសិប)ថ្ងៃ ដូចបានកំណត់ក្នុងប្រការ១៣ចំណុច២(គ)ខាងលើ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីចាត់វិធានការតាមបញ្ញត្តិច្បាប់ជាធរមាន ចំពោះទំនិញតែមួយពាក់ម៉ាកដូចគ្នា ។

**ប្រការ ១៤.- ការបាត់បង់សុពលភាពជាស្វ័យប្រវត្តិ**

សុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវបាត់បង់ជាស្វ័យប្រវត្តិ ប្រសិនបើៈ

ក- ការប្រគល់សិទ្ធិផ្តាច់មុខត្រូវបានដកហូតវិញ ឬ

ខ- សុពលភាពនៃការចុះបញ្ជីម៉ាកត្រូវបាត់បង់ដោយប្រការណាមួយ ឬ

គ- ការចុះបញ្ជីម៉ាកដែលបានចុះបញ្ជីរួចហើយត្រូវបានប្តូរម្ចាស់កម្មសិទ្ធិ ឬ

ឃ- ការនាំចូលទំនិញជាប់កម្រិតកំណត់ដែលបានអនុញ្ញាត ត្រូវបាននាំចូលគ្រប់ចំនួនរួចហើយ ឬ

ង- ការអនុញ្ញាតឲ្យនាំចូលទំនិញជាប់កម្រិតកំណត់ ត្រូវបានដកហូតវិញ ។

**ប្រការ ១៥.- មោឃភាពនៃការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ**

១- លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ បានចេញដោយក្រសួងពាណិជ្ជកម្មកន្លងមកដែលមិនបានកំណត់សុពលភាព ត្រូវចាត់ទុកជានិរាករណ៍ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ។

២- ជនណាដែលមានការពាក់ព័ន្ធអាចស្នើសុំក្រសួងពាណិជ្ជកម្ម ឲ្យផ្តល់មោឃភាពលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខបាន។

៣- ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើមោឃភាពលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ក្នុងករណីបុគ្គលដែលស្នើសុំនោះបង្ហាញថា៖

ក- លិខិតបញ្ជាក់ ឬលិខិតកត់ត្រានិងតម្កល់ មិនបានបំពេញលក្ខខណ្ឌតម្រូវនៃប្រការណាមួយនៃប្រកាសនេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬ

ខ- លិខិតប្រគល់សិទ្ធិផ្តាច់មុខមានភាពមិនប្រក្រតីដោយប្រការណាមួយ។

៤- ក្រសួងពាណិជ្ជកម្ម មានសិទ្ធិលុបការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬការកត់ត្រានិងតម្កល់លិខិតប្រគល់ផ្តាច់មុខប្រសិនបើ៖

ក- បុគ្គលណាដែលអនុវត្តផ្ទុយនឹងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬ

ខ- មានការស្នើសុំពីម្ចាស់ម៉ាក ឬពីអ្នកទទួលសិទ្ធិដោយភ្ជាប់មកជាមួយនូវឯកសារយោងគ្រប់គ្រាន់ ។

៥. ពាក្យស្នើសុំធ្វើមោឃភាពចំពោះលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវបង់ប្រាក់កម្រៃសេវាសាធារណៈដោយអ្នកដាក់ពាក្យស្នើសុំតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ ។

៦- ការធ្វើមោឃភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវមានអានុភាពអនុវត្តចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច។

**ប្រការ១៦.- ការបន្តសុពលភាព**

១- បុគ្គលដែលមានគោលបំណងបន្តសុពលភាពនៃ លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវដាក់ពាក្យស្នើសុំឲ្យបាន៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព ហើយត្រូវបំពេញតាមនីតិវិធីនិងលក្ខខណ្ឌ ដូចខាងក្រោម៖

ក- អ្នកដាក់ពាក្យស្នើសុំ ត្រូវបង់ប្រាក់កម្រៃសេវាសាធារណៈដូចបានកំណត់ក្នុងប្រកាសជាធរមាន ។

ខ- ច្បាប់ចម្លងនៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខ ដែលបានតម្កល់នៅក្រសួងពាណិជ្ជកម្ម នៅមានសុពលភាពនៅឡើយ ។ ក្នុងករណីលិខិតប្រគល់សិទ្ធិផ្ដាច់មុខបានផុតសុពលភាព អ្នកស្នើសុំត្រូវដាក់លិខិតប្រគល់សិទ្ធិផ្ដាច់មុខថ្មី។

គ- ត្រូវបំពេញលក្ខខណ្ឌ នីតិវិធី និងឯកសារតម្រូវដូចមាននៅពេលដាក់ពាក្យស្នើសុំដំបូង ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ ។

២- ក្នុងករណី លិខិតប្រគល់សិទ្ធិផ្ដាច់មុខ និងវិញ្ញាបនបត្រចុះបញ្ជីម៉ាក ព្រមទាំងលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន នៅមានសុពលភាពចាប់ពី ២(ពីរ)ឆ្នាំឡើងទៅ ការបន្តសុពលភាពត្រូវមានរយៈពេល២(ពីរ)ឆ្នាំ ។ ក្នុងករណីលិខិតប្រគល់សិទ្ធិ និងវិញ្ញាបនបត្រចុះបញ្ជីម៉ាក ព្រមទាំងលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន មានសុពលភាពតិចជាង២(ពីរ)ឆ្នាំ ការបន្តសុពលភាពត្រូវមានរយៈពេលស្មើនឹងសុពលភាពអប្បបរមានៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខ ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ឬលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន ។

៣- លិខិតបន្តសុពលភាពមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃផុតសុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ ហើយត្រូវបោះពុម្ពផ្សាយដូចមានចែងក្នុងប្រការ១៣ ចំណុច២(ក) និង (ខ) នៃប្រកាសនេះ។

**ប្រការ ១៧.-សិទ្ធិនិងរយៈពេលនៃបណ្ដឹងតវ៉ា**

១- ជនណាដែលមានការពាក់ព័ន្ធមានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាបណ្ដឹងតវ៉ា ឬតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងការបញ្ជាក់ ឬការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្ដាច់មុខរបស់ក្រសួងពាណិជ្ជកម្ម ។

២- សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាបណ្ដឹងតវ៉ាជាកម្មវត្ថុនៃបណ្ដឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេច។

**ប្រការ ១៨.- ការបំពានសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខ និងនីតិវិធីដោះស្រាយវិវាទ**

ការបំពានសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខត្រូវដោះស្រាយតាមនីតិវិធី ដូចខាងក្រោម៖

១- អ្នកទទួលសិទ្ធិស្របច្បាប់ អាចចេញលិខិតព្រមានដល់អ្នកនាំចូលទំនិញស្របគ្នាឲ្យបញ្ឈប់ការនាំចូលដែលបំពានទៅលើសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខរបស់ខ្លួន ។

២- តាមការស្នើសុំអន្តរាគមន៍ពីអ្នកទទួលសិទ្ធិស្របច្បាប់ ក្រសួងពាណិជ្ជកម្មអាចចេញលិខិតព្រមានដល់អ្នកនាំចូលទំនិញស្របគ្នា ឲ្យបញ្ឈប់ការនាំចូលដែលបំពានទៅលើសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្ដាច់មុខ។

៣- អ្នកទទួលសិទ្ធិស្របច្បាប់ និងអ្នកនាំចូលទំនិញស្របគ្នាអាចធ្វើការសម្រុះសម្រួលអំពីផលប៉ះពាល់ និងការខូចខាតអំពីការនាំចូលទំនិញស្របគ្នាដោយៈ

- អនុញ្ញាតឲ្យអ្នកនាំចូលស្របគ្នាបន្តលក់ទំនិញ ដែលរំលោភសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខតាមរយៈសងការខូចខាតជូនអ្នកទទួលសិទ្ធិស្របច្បាប់ក្នុងតម្លៃឯកភាពគ្នា ឬ
- អ្នកទទួលសិទ្ធិស្របច្បាប់ទទួលទិញទំនិញដែលនាំចូលស្របគ្នាតាមតម្លៃស្រុះស្រួល។

៤- ក្នុងករណីគ្មានការឯកភាពគ្នាតាមជម្រើសខាងលើ ទំនិញដែលនាំចូលនោះត្រូវបញ្ជូនត្រឡប់ទៅប្រភពដើមវិញ ។

៥- ភាគីវិវាទត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលសម្រុះសម្រួល ដោយចុះហត្ថលេខា ឬផ្តិតមេដៃចំពោះមុខ និងមានការចុះហត្ថលេខាដឹងឮ ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ជូនមួយច្បាប់មកក្រសួងពាណិជ្ជកម្ម។

៦- កំណត់ហេតុស្តីពីលទ្ធផលសម្រុះសម្រួលអាចប្រើប្រាស់ជាឯកសារយោងអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

៧- ក្នុងករណីគ្មានការឯកភាពលើការសម្រុះសម្រួលណាមួយ ភាគីវិវាទអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

**ប្រការ ១៩.- ភារអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន់ ស៊ូរស័ក្តិ**

**ចម្លងជូនៈ**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានគាំពារអ្នកប្រើប្រាស់
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។

# ១០. ប្រកាសស្តីពី នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាក វិញ្ញាតកម្ម ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ២៩៣ ព.ណ.ការប.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញាតកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ/បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- យោងតាមការងារចាំបាច់របស់ក្រសួងពាណិជ្ជកម្ម


ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះមានគោលបំណងការពារអ្នកប្រើប្រាស់ និងផលិតករ តាមរយៈការដាក់ឲ្យអនុវត្តនូវប្រព័ន្ធម៉ាកវិញ្ញាតកម្ម សំដៅជម្រាបដល់សាធារណជន ឬអ្នកប្រើប្រាស់ ថាមុខទំនិញ ឬសេវារបស់កម្មសិទ្ធិករ ដែលគាត់ប្រើប្រាស់ មានចរិតលក្ខណៈ ឬគុណភាពជាក់លាក់ ឬបានបំពេញនូវលក្ខណៈសម្បត្តិ ឬស្តង់ដារច្បាស់លាស់ ។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅកំណត់នីតិវិធីសម្រាប់ការចុះបញ្ជី កិច្ចការពារ និងការគ្រប់គ្រងម៉ាកវិញ្ញាតកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តលើសញ្ញាណាមួយ ដែលមានលក្ខណៈស្របតាមនិយមន័យនៃម៉ាកវិញ្ញាតកម្មដូចមានចែងក្នុងប្រការ ៤ និងបទប្បញ្ញត្តិពាក់ព័ន្ធ ហើយអាចត្រូវបានចុះបញ្ជី និងការពារក្រោមប្រព័ន្ធម៉ាកវិញ្ញាតកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

"ម៉ាកវិញ្ញាតកម្ម" សំដៅដល់ ឈ្មោះ និមិត្តសញ្ញា ឬរូបសញ្ញា ឬបង្គុំនៃសញ្ញាទាំងនោះដែលបង្ហាញថា ទំនិញនិង/ឬសេវានោះទាក់ទងនឹងម៉ាកវិញ្ញាតកម្មដែលបានប្រើប្រាស់ និងមានការបញ្ជាក់ពីម្ចាស់ម៉ាកបានចុះបញ្ជីរួចអំពី វត្ថុធាតុដើម ប្រភព វិធីសាស្ត្រ-របៀប ផលិតទំនិញឬផ្តល់សេវា គុណភាព ភាពច្បាស់លាស់ ឬចរិតលក្ខណៈផ្សេងទៀត។

**ប្រការ ៥.- បទប្បញ្ញត្តិដែលអនុវត្តបាន**

លើកលែងតែមានចែងផ្ទុយពីប្រកាសនេះ បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយនៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធត្រូវយកមកអនុវត្តផងដែរចំពោះម៉ាកវិញ្ញាតកម្ម។

**ប្រការ ៦.- សមត្ថកិច្ចគ្រប់គ្រង**

នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ចទទួលខុសត្រូវលើការចុះបញ្ជី កិច្ចការពារ និងការគ្រប់គ្រងម៉ាកវិញ្ញាតកម្ម តាមការផ្តល់សិទ្ធិដោយក្រសួងពាណិជ្ជកម្ម។

**ប្រការ ៧.- ភាពជាម្ចាស់ម៉ាកវិញ្ញាតកម្ម**

១. អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវមានទ្រង់ទ្រាយជានីតិបុគ្គល និងមានសមត្ថភាពបញ្ជាក់លើទំនិញនិង/ឬសេវា សម្រាប់ម៉ាកវិញ្ញាតកម្មដែលត្រូវចុះបញ្ជី។

២. អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច មិនត្រូវប្រើប្រាស់ផ្ទាល់ខ្លួន ឬមានការពាក់ព័ន្ធនឹងការផលិត ការស្វែងរកទីផ្សារ ឬការធ្វើអាជីវកម្មផ្សេងទៀតលើទំនិញឬសេវាដែលដូច ឬប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវាសម្រាប់ម៉ាកវិញ្ញាតកម្មដែលត្រូវចុះបញ្ជី ។

៣. មិនត្រូវអនុញ្ញាតឲ្យ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ឬម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច មកចុះបញ្ជីជាពាណិជ្ជសញ្ញា ឬសេវាសញ្ញាដែលដូច ឬប្រហាក់ប្រហែលចំពោះទំនិញឬសេវាដែលដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួចនោះឡើយ។

៤. មិនត្រូវអនុញ្ញាត ឲ្យអ្នកដាក់ពាក្យស្នើសុំ ឬម្ចាស់ពាណិជ្ជសញ្ញា ឬសេវាសញ្ញា ដែលបានដាក់ពាក្យ ឬចុះបញ្ជីរួចក្រោមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មកចុះបញ្ជីជាម៉ាកវិញ្ញាតកម្មដែលដូច ឬប្រហាក់ប្រហែលទៅនឹងពាណិជ្ជសញ្ញា ឬសេវាសញ្ញាចំពោះទំនិញឬសេវាដែលដូច ឬប្រហាក់ប្រហែលគ្នាឡើយ ។

៥. ការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ដែលបានចុះបញ្ជីរួចដោយភាគីណាមួយ ត្រូវមានការអនុញ្ញាតពីម្ចាស់ម៉ាកវិញ្ញាតកម្មនោះជាមុន។

**ប្រការ ៨.- ពាក្យស្នើសុំចុះបញ្ជី**

ពាក្យស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវធ្វើឡើងតាមគំរូពាក្យស្នើសុំជាភាសាខ្មែរ ឬអង់គ្លេស និងត្រូវដាក់ពាក្យដោយអនុលោមតាមមាត្រា ៥ ដល់ ៧ និងមាត្រា ៩ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយភ្ជាប់មកជាមួយនូវឯកសារតម្រូវដូចខាងក្រោម៖

១. លិខិតថ្លែងសច្ចារបស់អ្នកដាក់ពាក្យស្នើសុំ ថានឹងមិនពាក់ព័ន្ធក្នុងការផលិត ការស្វែងរកទីផ្សារ ឬផ្តល់សេវា ដែលមានលក្ខណៈដូច ឬប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវា ដែលម៉ាកវិញ្ញាតកម្ម នឹងត្រូវបានចុះបញ្ជី។

២. ភ័ស្តុតាងដែលបញ្ជាក់ថាអ្នកដាក់ពាក្យស្នើសុំនោះ មានទ្រង់ទ្រាយជានីតិបុគ្គល។

៣. បទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ត្រូវមានព័ត៌មានជាអប្បបរមាដូចខាងក្រោម៖

   ក. ស្តង់ដារដែលទាក់ទងនឹង វត្ថុធាតុដើម ប្រភព វិធីសាស្ត្រនៃការផលិតទំនិញ ឬការផ្តល់សេវា គុណភាព ភាពច្បាស់លាស់ ឬចរិតលក្ខណៈផ្សេងទៀតដែលនឹងត្រូវបញ្ជាក់ដោយម៉ាកវិញ្ញាតកម្មនោះ

   ខ. វិធីសាស្ត្រ-របៀបរបស់ម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច នឹងយកមកធ្វើ

ការផ្ទៀងផ្ទាត់ស្តង់ដារទាំងនោះ

គ. យន្តការរបស់ម្ចាស់ម៉ាកវិញ្ញាតកម្មដែលនឹងជួល ឲ្យធ្វើការគ្រប់គ្រងភាពត្រឹមត្រូវនៃការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និងភាពអនុលោមជាបន្តបន្ទាប់នៃស្តង់ដារខាងលើ

ឃ. វិធីសាស្ត្រ-របៀបនៃម៉ាកវិញ្ញាតកម្ម ដែលនឹងត្រូវបានប្រើប្រាស់លើទំនិញ និងសេវា

ច. កម្រៃសេវាដែលត្រូវបង់ជូនម្ចាស់ម៉ាកវិញ្ញាតកម្ម សម្រាប់ការប្រើប្រាស់ម៉ាកវិញ្ញាតកម្មនោះ ប្រសិនបើមាន

ឆ. នីតិវិធីដោះស្រាយវិវាទ។

៤. ឯកសារតម្រូវផ្សេងទៀត ដែលកំណត់ដោយច្បាប់ ឬបទប្បញ្ញត្តិជាធរមាន ឬបានបញ្ជាក់ក្នុងពាក្យស្នើសុំ។

៥. ម៉ាកវិញ្ញាតកម្មដែលដាក់ពាក្យស្នើសុំចុះបញ្ជីដោយនីតិបុគ្គលបរទេស ត្រូវភ្ជាប់មកជាមួយនូវភ័ស្តុតាងនៃការចុះបញ្ជី ឬពាក្យស្នើសុំចុះបញ្ជីម៉ាកនោះក្នុងប្រទេសដើម ។

៦. លិខិតប្រគល់សិទ្ធិដែលមានបញ្ជាក់ភាពត្រឹមត្រូវ ប្រសិនបើពាក្យស្នើសុំនោះត្រូវបានដាក់តាមរយៈភ្នាក់ងារតំណាងម្ចាស់ម៉ាក ។

**ប្រការ ៩.- កម្រៃសេវាសាធារណៈ**

កម្រៃសេវាសាធារណៈនៃម៉ាកវិញ្ញាតកម្ម ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ ។ នៅពេលកម្រៃសេវាសាធារណៈនៃម៉ាកវិញ្ញាតកម្មមិនទាន់បានកំណត់ ប្រកាសរួមរវាងក្រសួងទាំងពីរ ស្តីពីកម្រៃសេវាសាធារណៈក្នុងការចុះបញ្ជីម៉ាកដែលមានជាធរមានត្រូវបានយកមកអនុវត្ត ។

**ប្រការ ១០.- ការត្រួតពិនិត្យខ្លឹមសារពាក្យស្នើសុំ**

១. នៅពេលដែលអ្នកដាក់ពាក្យស្នើសុំ ដាក់ពាក្យនិងបង់កម្រៃសេវាចុះបញ្ជីរួចរាល់ មន្ត្រីកាន់កាប់បញ្ជីនៃនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវត្រួតពិនិត្យមើលដូចខាងក្រោម៖

ក. ម៉ាកនោះមានលក្ខណៈសម្បត្តិដែលត្រូវការពារជាម៉ាកវិញ្ញាតកម្ម ស្របតាមប្រការ ៤ និងប្រការ ៧ នៃប្រកាសនេះ

ខ. ពាក្យស្នើសុំនោះ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ និង

គ. ម៉ាកវិញ្ញាតកម្មនោះ មិនអាចចុះបញ្ជីបានតាមមាត្រា ៤ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងមាត្រា១០ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

២. ក្នុងករណីដែលពាក្យសម្គាល់ប្រភពភូមិសាស្ត្រ ត្រូវបានប្រើប្រាស់ជាម៉ាកវិញ្ញាតកម្ម ឬជាផ្នែកមួយនៃម៉ាកវិញ្ញាតកម្ម ដើម្បីបញ្ជាក់ថាទំនិញនិង/ឬសេវានោះ ពិតជាមានប្រភពដើមក្នុងតំបន់ភូមិសាស្ត្រដែលបញ្ជាក់ដោយពាក្យនោះ មន្ត្រីកាន់កាប់បញ្ជីមិនត្រូវបដិសេធការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ផ្អែកតែលើមូលដ្ឋានថាជាម៉ាកមានលក្ខណៈពិពណ៌នាភូមិសាស្ត្រ ដោយយោងតាមមាត្រា៤(ក) នៃច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឡើយ ។ ប្រសិនបើពាក្យសម្គាល់ប្រភពភូមិសាស្ត្រនោះ មិនត្រូវបានប្រើប្រាស់ក្នុងគោលបំណងបញ្ជាក់ពីប្រភពដើមភូមិសាស្ត្រនៃទំនិញ ឬសេវានោះទេ មន្ត្រីកាន់កាប់បញ្ជីត្រូវបដិសេធការចុះបញ្ជីម៉ាកនោះ ទោះបីពាក្យនោះត្រូវបានប្រើប្រាស់ជាម៉ាកវិញ្ញាតកម្ម ឬជាផ្នែកមួយនៃម៉ាកវិញ្ញាតកម្មនោះស្របតាមមាត្រា៤នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ក៏ដោយ។

៣. ក្នុងករណីដែលពាក្យស្នើសុំមិនបំពេញបានតាមលក្ខខណ្ឌតម្រូវ ដូចមានចែងក្នុងប្រការ៨ នៃប្រកាសនេះ អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីអាចកែតម្រូវក្នុងរយៈពេល ៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំចុះបញ្ជីដោយអ្នកដាក់ពាក្យតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកវិញ្ញាតកម្មនោះ។

៤. ក្នុងអំឡុងពេលធ្វើការត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំ មន្ត្រីកាន់កាប់បញ្ជីអាចអញ្ជើញអ្នកដាក់ពាក្យស្នើសុំ ឬបុគ្គលពាក់ព័ន្ធមកធ្វើការពន្យល់ ឬផ្តល់ភស្តុតាងបន្ថែម ឬសុំយោបល់ពីអ្នកជំនាញក្នុងវិស័យ ឬផ្នែកពាក់ព័ន្ធដើម្បីសម្រេច ។

៥. ក្នុងករណីចាំបាច់ មន្ត្រីកាន់កាប់បញ្ជីអាចបង្កើតវិធានណែនាំបន្ថែមសម្រាប់ត្រួតពិនិត្យខ្លឹមសារនៃពាក្យស្នើសុំចុះបញ្ជី និងការគ្រប់គ្រងម៉ាកវិញ្ញាតកម្ម ។

## ប្រការ ១១ .- ការចុះបញ្ជី និងការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ

១. ក្រសួងពាណិជ្ជកម្មត្រូវចុះបញ្ជីម៉ាកវិញ្ញាតកម្ម និងចេញវិញ្ញាបនបត្រជូនអ្នកដាក់ពាក្យស្នើសុំ ក្នុងករណីដែលពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌតម្រូវដូចបានកំណត់ក្នុងប្រការ ៥ និង ១០ នៃប្រកាសនេះ។

២. អនុលោមតាមមាត្រា ១០ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពផ្សាយម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច រួមជាមួយបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់នៃម៉ាកនោះក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម។

៣. រាល់ការកែតម្រូវ ការកែសម្រួល ការផ្ទេរកម្មសិទ្ធិ និងការផ្លាស់ប្តូរផ្សេងៗ ក៏ត្រូវធ្វើការបោះពុម្ពផ្សាយផងដែរ ។

**ប្រការ ១២.-សិទ្ធិទទួលបានពីការចុះបញ្ជី**

សិទ្ធិទទួលបានតាមរយៈការចុះបញ្ជីម៉ាកវិញ្ញាតកម្មមានដូចខាងក្រោម៖

១. កម្មសិទ្ធករនៃម៉ាកវិញ្ញាតកម្ម ត្រូវមានសិទ្ធិផ្តាច់មុខក្នុងការអនុញ្ញាតឲ្យភាគីទីបីប្រើប្រាស់ម៉ាកវិញ្ញាតកម្មបានចុះបញ្ជីរួច ដើម្បីផលិត ឬស្វែងរកទីផ្សារទំនិញ ឬផ្តល់សេវាស្របតាមស្តង់ដារកំណត់ក្នុងបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម។ ការអនុញ្ញាតនេះ នឹងមិនត្រូវបានបដិសេធឡើយ ប្រសិនបើភាគីទីបីអាចបំពេញបាននូវរាល់លក្ខខណ្ឌតម្រូវទាំងឡាយដូចមានកំណត់ក្នុងបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់។

២. ប្រសិនបើអ្នកទទួលបានការអនុញ្ញាតក្នុងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម មិនបានបំពេញតាមស្តង់ដារតម្រូវទាំងអស់ដែលកំណត់ដោយបទប្បញ្ញត្តិនោះ ម្ចាស់ម៉ាកវិញ្ញាតកម្ម អាចដកហូតការអនុញ្ញាតរបស់ខ្លួនក្នុងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម និង/ឬអាចចាត់វិធានការផ្សេងទៀត ដូចបានកំណត់ក្នុងបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់។

៣. ដើម្បីទប់ស្កាត់ ឬរារាំងការរំលោភបំពាន ម្ចាស់ម៉ាកវិញ្ញាតកម្ម អាចចាត់វិធានការចាំបាច់តាមផ្លូវច្បាប់ ដើម្បីប្រឆាំងនឹងភាគីរំលោភបំពាន និងអាចស្វែងរកដំណោះស្រាយពាក់ព័ន្ធទាំងអស់ រួមទាំងសំណងចំពោះការខូចខាត វិធានការបណ្តោះអាសន្ន និងវិធានការតាមមាត់ច្រកព្រំដែន ដូចមានចែងក្នុងមាត្រា ២៤ ដល់មាត្រា ៤៧ និងមាត្រា ៦២ ដល់មាត្រា ៦៩ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

៤. ម្ចាស់ម៉ាកវិញ្ញាតកម្ម មានសិទ្ធិក្នុងការទប់ស្កាត់ការប្រើប្រាស់ម៉ាក ឬម៉ាកវិញ្ញាតកម្មដែលដូច ឬប្រហាក់ប្រហែលទៅនឹងម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួចចំពោះទំនិញ និង/ឬសេវាដែលដូច ឬប្រហាក់ប្រហែលទៅនឹងទំនិញឬសេវាដែលម៉ាកវិញ្ញាតកម្មត្រូវចុះបញ្ជី ។

៥. សិទ្ធិផ្តាច់មុខរបស់ម្ចាស់ម៉ាកវិញ្ញាតកម្ម មិនមែនជាកម្មវត្ថុដើម្បីចាប់បង្ខំភាគីទីបីឲ្យទទួលនូវការធ្វើវិញ្ញាតកម្ម ដោយគ្មានការស្ម័គ្រចិត្តនោះឡើយ។

៦. សិទ្ធិដែលទទួលបានពីការចុះបញ្ជីម៉ាកវិញ្ញាតកម្ម មិនត្រូវបានផ្ទេរទាំងស្រុង ឬដោយផ្នែក លើកលែងតែនីតិបុគ្គលដែលនឹងទទួលបានសិទ្ធិពីម្ចាស់ម៉ាកវិញ្ញាតកម្មនោះអនុវត្តតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ។ ការផ្ទេរសិទ្ធិនេះ ត្រូវមានការយល់ព្រមពីក្រសួងពាណិជ្ជកម្ម ។

## ប្រការ ១៣.- ការចុះបញ្ជីម៉ាកវិញ្ញាតកម្មបរទេស

១. ម៉ាកវិញ្ញាតកម្មបរទេស អាចត្រូវបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនម៉ាកនោះ បានបំពេញតាមលក្ខខណ្ឌតម្រូវទាំងឡាយដែលកំណត់ដោយប្រកាសនេះ និងបានចុះបញ្ជីស្របច្បាប់តាមបទប្បញ្ញត្តិនានាក្នុងប្រទេសដើមរួចហើយ។

២. មិនអនុញ្ញាតឲ្យចុះបញ្ជី ឬត្រូវបានលុបចេញពីបញ្ជី ក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះម៉ាកវិញ្ញាតកម្មបរទេស ដែលមិនត្រូវបានការពារ ឬបានបញ្ឈប់កិច្ចការពារ ឬបានឈប់ប្រើប្រាស់ក្នុងប្រទេសដើម ។

៣. ម៉ាកវិញ្ញាតកម្មបរទេស អាចដាក់ពាក្យស្នើសុំចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែធ្វើឡើងតាមរយៈភ្នាក់ងារតំណាង ដូចមានចែងក្នុងមាត្រា ៥៨ និងមាត្រា ៥៩ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ប្រការ ១៤.- បណ្តឹងជំទាស់

អនុលោមតាមមាត្រា ១០ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ភាគីពាក់ព័ន្ធអាចដាក់ពាក្យប្តឹងជំទាស់នឹងការចុះបញ្ជីម៉ាកវិញ្ញាតកម្មមកក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយការចុះបញ្ជី ដោយឈរលើមូលដ្ឋាននៃលក្ខខណ្ឌតម្រូវមួយ ឬច្រើន ដូចមានចែងក្នុងប្រកាសនេះ ឬច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់មិនត្រូវបានបំពេញ។

## ប្រការ ១៥.- សុពលភាព

១. បទប្បញ្ញត្តិស្តីពី សុពលភាព និងការចុះបញ្ជីម៉ាកសាឡើងវិញ ដូចមានចែងក្នុងមាត្រា១២ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ត្រូវយកមកអនុវត្តផងដែរចំពោះម៉ាកវិញ្ញាតកម្ម។

២. ប្រសិនបើម៉ាកវិញ្ញាតកម្មឈប់ត្រូវបានការពារ ម៉ាកនោះមិនអាចយកមកស្នើសុំចុះបញ្ជីជាម៉ាកក្រោមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឡើយ ។ ម៉ាកវិញ្ញាតកម្មបែបនេះមិនត្រូវបានប្រើប្រាស់ដោយបុគ្គលណាមួយ មុនរយៈពេលផុតសុពលភាព ១០ (ដប់) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទបញ្ចប់កិច្ចការពារនោះឡើយ លើកលែងតែក្រសួងពាណិជ្ជកម្មអនុញ្ញាតឲ្យមានការបន្តប្រព័ន្ធវិញ្ញាតកម្ម ដោយនីតិបុគ្គលផ្សេងដែលបង្ហាញភ័ស្តុតាងថាបានបំពេញតាមលក្ខខណ្ឌតម្រូវនៃប្រការ ៨ នៃប្រកាសនេះ។

**ប្រការ ១៦.- ការត្រួតពិនិត្យអនុលោមភាព**

១. ម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច ត្រូវបង្កើតយន្តការផ្ទៀងផ្ទាត់ ដើម្បីធានាអនុលោមភាពទៅនឹងស្តង់ដារនៃការធ្វើវិញ្ញាតកម្ម ដូចមានចែងក្នុងប្រការ ៨(៣)(ខ) នៃប្រកាសនេះ ហើយត្រូវផ្តល់របាយការណ៍ប្រចាំឆ្នាំជូននាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម រួមទាំងបញ្ជីផលិតផលនិងផលិតករដែលបានធ្វើវិញ្ញាតកម្ម តាមវិធានការនានាសម្រាប់ធ្វើវិញ្ញាតកម្ម ។ របាយការណ៍ និងឯកសារពាក់ព័ន្ធត្រូវធ្វើជាភាសាខ្មែរ ។ ក្នុងករណីដែលឯកសារធ្វើឡើងមិនមែនជាភាសាខ្មែរត្រូវភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសាខ្មែរ ដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ។

២. ក្នុងករណីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនបានផ្តល់របាយការណ៍ប្រចាំឆ្នាំ ឬក្នុងករណីដែលរកឃើញថា មិនមានអនុលោមភាពទៅនឹងស្តង់ដារនៃវិញ្ញាតកម្ម ក្រសួងពាណិជ្ជកម្មនឹងជូនដំណឹងទៅម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ដោយតម្រូវឲ្យដោះស្រាយការខកខានទាំងនោះក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីជូនដំណឹង។

តាមការស្នើសុំដោយមានហេតុផលច្បាស់លាស់ ពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ក្រសួងពាណិជ្ជកម្មអាចពន្យារពេលបន្ថែមទៀតមិនលើសពី ៩០(កៅសិប)ថ្ងៃ។ ប្រសិនបើនៅតែខកខានមិនបានបំពេញតាមការតម្រូវនេះ ម៉ាកវិញ្ញាតកម្មនោះនឹងត្រូវបានលុបចេញពីបញ្ជី។

**ប្រការ ១៧.-ការកែសម្រួល**

១. ក្រោយចុះបញ្ជីរួច និងក្នុងករណីមានការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ម្ចាស់ម៉ាកវិញ្ញាតកម្មអាចកែសម្រួលវិធីសាស្ត្រ និង/ឬនីតិវិធីសម្រាប់៖

ក. ធ្វើវិញ្ញាតកម្មអំពីចរិតលក្ខណៈ ស្តង់ដារ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញនិង/ឬសេវា

ខ. ធ្វើការត្រួតពិនិត្យការប្រើប្រាស់ម៉ាកវិញ្ញាតកម្មក្នុងវិស័យពាណិជ្ជកម្ម។

២. ក្រសួងពាណិជ្ជកម្ម នឹងឯកភាពលើការកែសម្រួល តាមការស្នើសុំពីម្ចាស់ម៉ាកវិញ្ញាតកម្មដែលបានចុះបញ្ជីរួច ប្រសិនបើការកែសម្រួលនោះមិនធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កម្មវត្ថុនិងស្តង់ដារដើមនៃម៉ាកវិញ្ញាតកម្មនោះ។

៣. ការកែសម្រួលខាងលើអាចធ្វើទៅបាន លុះត្រាតែការកែសម្រួលនោះមិនប៉ះពាល់ធ្ងន់ធ្ងរដល់កម្មវត្ថុ និងគម្រោងដើមនៃម៉ាកវិញ្ញាតកម្មនោះ ដែលពាក់ព័ន្ធទៅនឹងសមាសធាតុនៃការអភិវឌ្ឍបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រ ។

**ប្រការ ១៨.- មោឃភាព និងការលុបចេញពីបញ្ជី**

១. ការធ្វើមោឃភាពនៃការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក. ម៉ាកវិញ្ញាតកម្ម មិនបានបំពេញលក្ខខណ្ឌតម្រូវណាមួយ ដូចមានចែងក្នុងប្រកាសនេះ និង

ខ. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនមានសិទ្ធិស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីម៉ាកវិញ្ញាតកម្មដូចមានចែងក្នុងប្រការ៤ និងប្រការ៧ នៃប្រកាសនេះ។

២. ការលុបម៉ាកវិញ្ញាតកម្មចេញពីបញ្ជី ត្រូវផ្អែកលើមូលដ្ឋានដូចខាងក្រោម៖

ក. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចលែងមានសមត្ថភាពធ្វើវិញ្ញាតកម្មលើទំនិញឬសេវា

ខ. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនអនុវត្តតាមកាលកំណត់ដូចមានចែងក្នុងប្រការ ១៥ នៃប្រកាសនេះ

គ. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច បានចាប់ផ្តើមប្រើប្រាស់ម៉ាកវិញ្ញាតកម្មផ្ទាល់ខ្លួនលើទំនិញ និង/ឬសេវា

ឃ. ការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម ធ្វើឲ្យសាធារណជនភ័ន្តច្រឡំ

ង. ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច មិនបានប្រតិបត្តិតាមបទប្បញ្ញត្តិគ្រប់គ្រងការប្រើប្រាស់ម៉ាកវិញ្ញាតកម្ម

ច. ការកែសម្រួលណាមួយដែលបណ្តាលឲ្យបទប្បញ្ញត្តិខាងលើនេះ ផ្ទុយទៅនឹងសណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌សង្គម និង

ឆ. ម៉ាកវិញ្ញាតកម្មបរទេស ដែលបានចុះបញ្ជីស្របតាមប្រការ ១៣ នៃប្រកាសនេះលែងត្រូវបានការពារ ឬមិនត្រូវបានប្រើប្រាស់ក្នុងប្រទេសដើម។

៣. អនុភាពនៃការធ្វើមោឃភាព និងលុបការចុះបញ្ជីម៉ាកវិញ្ញាតកម្ម ត្រូវអនុវត្តទៅតាមមាត្រា ៣០ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ។

**ប្រការ ១៩.- បណ្តឹងតវ៉ា**

១. ជនណាដែលមានការពាក់ព័ន្ធ មានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាបណ្តឹងតវ៉ា ឬតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម ដូចមានចែងក្នុងមាត្រា៦២ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

២. សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា ជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា។

**ប្រការ ២០.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ សីហា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

<u>ចម្លងជូន៖</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។

# ១១. ប្រកាសស្តីពី នីតិវិធីចុះបញ្ជីម៉ាកក្នុង ក្របខណ្ឌអន្តរជាតិ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣១៥ ព.ណ. ភលប.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តន៍ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញលិខិតុបករណ៍ចូលជាសមាជិកនៃពិធីសារទីក្រុងម៉ាឌ្រីដរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ស្តីពី ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥ និងបានចូលជាសមាជិក នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១._ គោលបំណង**

ប្រកាសនេះ មានគោលបំណងអនុវត្តពិធីសារទីក្រុងម៉ាឌ្រីដ និងនីតិវិធីសម្រាប់ការចុះបញ្ជី និងការពារម៉ាកក្នុងក្របខណ្ឌអន្តរជាតិ។

**ប្រការ ២._ វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។

ប្រកាសនេះ ត្រូវអនុវត្តរួមជាមួយបទប្បញ្ញត្តិទាំងឡាយនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួមទាក់ទងនឹងពិធីសារទីក្រុងម៉ាឌ្រីដ ។

**ប្រការ ៣._ វាក្យសព្ទបច្ចេកទេស**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចតទៅ៖

(១) "ពិធីសារទីក្រុងម៉ាឌ្រីដ" សំដៅដល់ពិធីសារពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលត្រូវបានអនុម័តនៅទីក្រុងម៉ាឌ្រីដ នៃប្រទេសអេស្ប៉ាញ នៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៨៩ ដែលប្រទេសកម្ពុជាជាសមាជិកនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៥។

(២) "បទប្បញ្ញត្តិរួម" សំដៅដល់បទប្បញ្ញត្តិទាំងឡាយ ក្រោមកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ និងពិធីសារទីក្រុងម៉ាឌ្រីដ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

(៣) "ភាគីហត្ថលេខី" សំដៅដល់ប្រទេស ឬអង្គការអន្តររដ្ឋាភិបាល ដែលជាសមាជិកនៃពិធីសារទីក្រុងម៉ាឌ្រីដ។

(៤) "នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម" ជាអង្គភាពដែលមានភារកិច្ចក្នុងការចុះបញ្ជី និងការពារម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(៥) "ពាក្យស្នើសុំក្នុងក្របខណ្ឌអន្តរជាតិ" សំដៅដល់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលបានដាក់ពាក្យស្នើសុំនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងនាមជាការិយាល័យដើម ដើម្បីទទួលបានការចុះបញ្ជីម៉ាក និងអត្ថប្រយោជន៍នានាក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(៦) "ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ" សំដៅដល់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលមានអានុភាពក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(៧) "អ្នកស្នើសុំ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ឬបរទេស ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្នុងនាមបុគ្គលនោះ។

(៨) "ម្ចាស់ម៉ាក" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិខ្មែរ ឬបរទេស ដែលបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិត្រូវបានកត់ត្រាទុកក្នុងបញ្ជីក្របខណ្ឌអន្តរជាតិក្នុងនាមបុគ្គលនោះ។

(៩) "ការជ្រើសរើសប្រទេសបន្ទាប់សម្រាប់ការដាក់ពាក្យ" សំដៅដល់ការជ្រើសរើសប្រទេសកម្ពុជា ឬប្រទេសជាភាគីហត្ថលេខីណាមួយបន្ថែមទៀត បន្ទាប់ពីបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ សំដៅពង្រីកកិច្ចការពារម៉ាក។

(១០) "ច្បាប់ស្តីពី ម៉ាក" សំដៅដល់ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២។

(១១) "អនុក្រឹត្យស្តីពី ម៉ាក" សំដៅដល់អនុក្រឹត្យលេខ ៦៤ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

(១២) "ការិយាល័យអន្តរជាតិ"សំដៅដល់ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

(១៣) "បញ្ជីអន្តរជាតិ" សំដៅដល់ទិន្នន័យផ្លូវការពាក់ព័ន្ធនឹងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលគ្រប់គ្រងដោយការិយាល័យអន្តរជាតិ។

(១៤) "ពាក្យស្នើសុំគោល" សំដៅដល់ពាក្យស្នើសុំចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដែលប្រើប្រាស់ពាក្យស្នើសុំនោះធ្វើជាមូលដ្ឋានសម្រាប់ការដាក់ពាក្យចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(១៥) "ការចុះបញ្ជីគោល" សំដៅដល់ការចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ហើយដែលបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ក្រោមពិធីសារទីក្រុងម៉ាឌ្រីដ។

(១៦) "ព្រឹត្តិបត្រផ្លូវការ" សំដៅដល់ព្រឹត្តិបត្រដែលបានបោះពុម្ពផ្សាយម៉ាកដែលបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ។

(១៧) "ការិយាល័យដើម" សំដៅដល់អង្គភាពកម្មសិទ្ធិបញ្ញានៃប្រទេសហត្ថលេខីដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានដាក់ជាលើកដំបូង។

(១៨) "ប្រទេសហត្ថលេខីដែលបានជ្រើសរើស" សំដៅដល់ប្រទេសហត្ថលេខីនៃពិធីសារទីក្រុងម៉ាឌ្រីដ ដែលត្រូវបានជ្រើសរើសសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឬជាប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើសបន្ទាប់។

## ជំពូកទី ២
## សិទ្ធិ និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិក្នុងលក្ខខណ្ឌព្រះរាជាណាចក្រកម្ពុជាជាការិយាល័យដើម

### ប្រការ ៤._ សិទ្ធិក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ឬម៉ាកដែលបានចុះបញ្ជីហើយក្នុងនាមបុគ្គលនោះនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មក្នុងនាមជាការិយាល័យដើម អាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ប្រសិនបើរូបវន្តបុគ្គល ឬនីតិបុគ្គលនោះៈ

(១) ជាជនជាតិខ្មែរ ឬ

(២) មានលំនៅដ្ឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ឬ

(៣) មានគ្រឹះស្ថានឧស្សាហកម្ម ឬពាណិជ្ជកម្ម ស្របច្បាប់និងកំពុងដំណើរការក្នុងព្រះរាជាណាចក្រកម្ពុជា។

ពាក្យស្នើសុំ និងឯកសារយោងសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និងឯកសារទំនាក់ទំនង រវាងការិយាល័យអន្តរជាតិ និងនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើជាភាសាអង់គ្លេស។

## ប្រការ ៥._ ឯកសារ និងលក្ខខណ្ឌតម្រូវសម្រាប់ការដាក់ពាក្យស្នើសុំ

ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិត្រូវបានកំណត់លក្ខខណ្ឌអប្បបរមាដូចខាងក្រោមៈ

(១) ឈ្មោះ អាសយដ្ឋានពិតប្រាកដ និងព័ត៌មានទំនាក់ទំនងលម្អិតរបស់អ្នកស្នើសុំ ព្រមទាំងឈ្មោះ អាសយដ្ឋាន និងព័ត៌មានទំនាក់ទំនងលម្អិតរបស់ភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាក ប្រសិនបើមាន

(២) គំរូម៉ាកស្របតាមលក្ខខណ្ឌតម្រូវ នៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

(៣) យថាប្រភេទទំនិញនិងសេវា ដែលនឹងត្រូវស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ និង

(៤) ប្រទេសហត្ថលេខីដែលត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជី។

អ្នកដាក់ពាក្យស្នើសុំត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ MM2 ដែលអាចទាញយកបានពីគេហទំព័រ www.cambodiaip.gov.kh ។

ពាក្យស្នើសុំអាចយកមកដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម រៀងរាល់ម៉ោងធ្វើការ។

## ប្រការ ៦._ តម្លៃដាក់ពាក្យ

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបង់តម្លៃសេវារដ្ឋបាល និងតម្លៃសេវាពាក់ព័ន្ធផ្សេងទៀត តាមប្រកាសអន្តរក្រសួងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

## ប្រការ ៧._ តម្លៃចុះបញ្ជីម៉ាកអន្តរជាតិ

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបង់តម្លៃតាមការកំណត់របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

# ជំពូកទី ៣
# នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ
# ដែលព្រះរាជាណាចក្រកម្ពុជាជាការិយាល័យដើម

**ប្រការ ៨._ ការត្រួតពិនិត្យពាក្យស្នើសុំ**

ក្នុងនាមជាការិយាល័យដើម នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវផ្ទៀងផ្ទាត់ព័ត៌មានលម្អិតពាក់ព័ន្ធទាំងឡាយនៅក្នុងពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ឲ្យដូចទៅនឹងព័ត៌មានលម្អិតដែលមាននៅក្នុងពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល ។

**ប្រការ ៩._ ការបញ្ជាក់ភាពត្រឹមត្រូវ**

(១) នៅពេលដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ បានបំពេញតាមលក្ខខណ្ឌកំណត់រួចហើយ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវបញ្ជាក់លើពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិនោះ អំពីភាពត្រឹមត្រូវដោយចុះកាលបរិច្ឆេទទទួលពាក្យស្នើសុំ រួចបញ្ជូនទៅការិយាល័យអន្តរជាតិ។

(២) នៅពេលដែលពាក្យស្នើសុំចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ មិនបានបំពេញតាមលក្ខខណ្ឌកំណត់ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម មិនត្រូវបញ្ជូនពាក្យស្នើសុំនោះទៅការិយាល័យអន្តរជាតិឡើយ ប៉ុន្តែត្រូវជូនដំណឹងទៅអ្នកស្នើសុំឲ្យធ្វើការកែតម្រូវក្នុងរយៈពេល ប្រាំពីរ(០៧)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខា។

**ប្រការ ១០._ ការអស់សុពលភាពនៃពាក្យស្នើសុំគោល ឬការចុះបញ្ជីគោល**

អនុលោមតាមមាត្រា ៦ នៃពិធីសារទីក្រុងម៉ាឌ្រីដ នៅពេលដែលពាក្យស្នើសុំគោល ឬការចុះបញ្ជីគោលលែងមានសុពលភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាការិយាល័យដើម នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីបញ្ហានេះ និងត្រូវស្នើសុំលុបការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ចំពោះទំនិញនិងសេវាដែលពាក់ព័ន្ធ។

## ជំពូកទី ៤
## នីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ
## ដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជី

**ប្រការ ១១._ ការត្រួតពិនិត្យម៉ាកលម្អិត**

នៅពេលដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការត្រួតពិនិត្យម៉ាកលម្អិត ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ១២._ ការបដិសេធបណ្តោះអាសន្នចំពោះកិច្ចការពារម៉ាក**

នៅពេលដែលម៉ាកស្នើសុំចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានបដិសេធជាបណ្តោះអាសន្នចំពោះកិច្ចការពារ នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ អំពីការបដិសេធនេះ ដោយអនុលោមតាមលក្ខខណ្ឌតម្រូវនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម ។ ការជូន

ដំណឹងនេះត្រូវអនុលោមតាមមាត្រា ៥(២)(b) នៃពិធីសារទីក្រុងម៉ាឌ្រីដ ។

អ្នកដាក់ពាក្យស្នើសុំដែលត្រូវបានបដិសេធការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ មានសិទ្ធិតវ៉ារកដំណោះស្រាយនានាស្របតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ប្រការ ១៣._ ការបដិសេធបណ្តោះអាសន្នចំពោះកិច្ចការពារម៉ាក ដោយផ្អែកលើបណ្តឹងជំទាស់

នៅពេលដែលមានបណ្តឹងជំទាស់ទៅលើការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីការបដិសេធជាបណ្តោះអាសន្ន ដោយអនុលោមតាមមាត្រា ៥(២)(b) និង ៥(២)(c) នៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

អ្នកដាក់ពាក្យស្នើសុំដែលត្រូវបានបដិសេធការចុះបញ្ជីក្នុងក្របខណ្ឌអន្តរជាតិ មានសិទ្ធិតវ៉ារកដំណោះស្រាយនានាស្របតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ប្រការ ១៤._ ការគ្មានមូលដ្ឋានបដិសេធ និងសេចក្តីអះអាងអំពីការផ្តល់កិច្ចការពារ

នៅពេលនាយកដ្ឋានកម្មសិទ្ធិបញ្ញាបានអនុវត្តនីតិវិធីត្រួតពិនិត្យចប់សព្វគ្រប់ ហើយគ្មានមូលដ្ឋានបដិសេធ នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវផ្ញើសេចក្តីអះអាងអំពីការផ្តល់កិច្ចការពារម៉ាកនោះ ទៅការិយាល័យអន្តរជាតិឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងឲ្យបានមុនថ្ងៃផុតកំណត់នៃរយៈពេលបដិសេធដោយអនុលោមតាមមាត្រា ៥(២)(b) នៃពិធីសារទីក្រុងម៉ាឌ្រីដ។

## ប្រការ ១៥._ សេចក្តីសម្រេចចុងក្រោយ បន្ទាប់ពីបានជូនដំណឹង អំពីការបដិសេធជាបណ្តោះអាសន្នចំពោះកិច្ចការពារ

### (១) សេចក្តីសម្រេចចុងក្រោយអំពីការផ្តល់កិច្ចការពារ

ទោះបីជាការបដិសេធជាបណ្តោះអាសន្នចំពោះកិច្ចការពារ ត្រូវបានបញ្ជូនទៅការិយាល័យអន្តរជាតិ អនុលោមតាមប្រការ ១២ ឬប្រការ ១៣ ខាងលើរួចហើយក៏ដោយ ក៏នាយកដ្ឋានកម្មសិទ្ធិបញ្ញាអាចធ្វើសេចក្តីសម្រេចចុងក្រោយក្នុងការដកចេញការបដិសេធកិច្ចការពារទាំងស្រុង ឬផ្នែកខ្លះ បន្ទាប់ពីបានត្រួតពិនិត្យលើទឡ្ហីករណ៍ និង/ឬភ័ស្តុតាងនានាពីអ្នកដាក់ពាក្យ។

ក្នុងករណីនេះ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវផ្ញើទៅការិយាល័យអន្តរជាតិនូវសេចក្តីសម្រេចណាមួយ ដូចខាងក្រោម៖

(ក) សេចក្តីសម្រេចដែលបញ្ជាក់ថា ការបដិសេធជាបណ្តោះអាសន្ននោះ ត្រូវបានដកចេញ ហើយម៉ាកនោះ ត្រូវបានផ្តល់កិច្ចការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់គ្រប់មុខទំនិញ និងសេវាដែលបានស្នើសុំ ។

(ខ) សេចក្តីសម្រេចដែលបញ្ជាក់ថា ការបដិសេធជាបណ្តោះអាសន្ននោះ ត្រូវបានដកចេញដោយផ្នែកខ្លះ ហើយម៉ាកនោះត្រូវបានផ្តល់កិច្ចការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់

មុខទំនិញនិងសេវាមួយចំនួនដែលបានស្នើសុំ ដោយបញ្ជាក់អំពី យថាប្រភេទ មុខទំនិញ ឬសេវាដែលផ្តល់កិច្ចការពារ។

(២) **សេចក្តីសម្រេចចុងក្រោយអំពីការបដិសេធកិច្ចការពារទាំងស្រុង**

អនុលោមតាមប្រការ ១២ ឬប្រការ ១៣ ខាងលើ និងនៅពេលដែលនីតិវិធីត្រួតពិនិត្យម៉ាកមុនពេលចុះបញ្ជីត្រូវបានបញ្ចប់ នាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ អំពីសេចក្តីសម្រេចក្នុងការបដិសេធកិច្ចការពារទាំងស្រុង ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវបញ្ជូនសេចក្តីសម្រេចចុងក្រោយនេះទៅការិយាល័យអន្តរជាតិ។

## ប្រការ ១៦._ សេចក្តីសម្រេចបន្ថែមនៅលើសេចក្តីសម្រេចចុងក្រោយដែលប៉ះពាល់ដល់កិច្ចការពារម៉ាក

ក្នុងករណីមានបណ្តឹងតវ៉ាលើសេចក្តីសម្រេចចុងក្រោយ ក្នុងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ហើយមានការចេញសេចក្តីសម្រេចបន្ថែមទាក់ទងដល់កិច្ចការពារម៉ាក ក្នុងព្រះរាជាណាចក្រកម្ពុជា នាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីសេចក្តីសម្រេចបន្ថែមនោះ។

## ប្រការ ១៧._ ប្រសិទ្ធភាពនៃការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាត្រូវបានជ្រើសរើស ត្រូវមានអានុភាពដូចគ្នានឹងការដាក់ពាក្យផ្ទាល់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ហើយមានប្រសិទ្ធភាពអនុវត្តគិតចាប់ពីថ្ងៃចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ។

## ប្រការ ១៨._ ម៉ាកសមូហភាព និងម៉ាកវិញ្ញាតកម្ម

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិជាម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ម្ចាស់ម៉ាកត្រូវភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃបទបញ្ជារួមស្តីពីការគ្រប់គ្រងនៃការប្រើប្រាស់ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម ដោយមានការបញ្ជាក់ពីភាពត្រឹមត្រូវ។ ការខកខានមិនបានដាក់ជូនបទបញ្ជារួមស្តីពី ការគ្រប់គ្រងនៃការប្រើប្រាស់ម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្ម នឹងត្រូវបានបដិសេធកិច្ចការពារម៉ាកសមូហភាព ឬម៉ាកវិញ្ញាតកម្មនោះ ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

## ប្រការ ១៩._ ការធ្វើមោឃភាព

នៅពេលការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវបានធ្វើមោឃភាពក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមោឃភាពនោះលែងជាកម្មវត្ថុចំពោះបណ្តឹងតវ៉ា នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ស្របតាមបទប្បញ្ញត្តិនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

**ប្រការ ២០._ ការកត់ត្រាក្នុងបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ**

ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ការកត់ត្រាណាមួយដែលបានធ្វើឡើងក្នុងបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ត្រូវមានអានុភាពដូចការកត់ត្រានៅក្នុងបញ្ជីម៉ាកដែលបានធ្វើឡើងនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មផងដែរ។

**ប្រការ២១._ កិច្ចសន្យាផ្តល់អាជ្ញាប័ណ្ណ**

កិច្ចសន្យាផ្តល់អាជ្ញាបណ្ណ័ទាក់ទងនឹងការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដែលត្រូវបានកត់ត្រាដោយការិយាល័យអន្តរជាតិ មិនមានអានុភាពចំពោះព្រះរាជាណាចក្រកម្ពុជាឡើយ។

**ប្រការ២២._លិខិតបញ្ជាក់ការប្រើប្រាស់ ឬមិនបានប្រើប្រាស់**

(១) ក្នុងករណីដែលព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសសម្រាប់ការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាកអន្តរជាតិរួចហើយ ត្រូវដាក់លិខិតបញ្ជាក់ពីការប្រើប្រាស់ ឬមិនបានប្រើប្រាស់ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មក្នុងអំឡុងពេល ១(មួយ)ឆ្នាំ បន្ទាប់ពីខួបលើកទី ៥ នៃកាលបរិច្ឆេទផ្តល់កិច្ចការពារក្នុងព្រះរាជាណាចក្រកម្ពុជា ឬកាលបរិច្ឆេទផ្តល់កិច្ចការពារសាជាថ្មី ។ ម្ចាស់ម៉ាក ត្រូវបំពេញពាក្យស្នើសុំដែលបានកំណត់ ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យស្តីពី ម៉ាក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

(២) ក្នុងករណីដែលម្ចាស់ម៉ាកខកខានមិនបានដាក់លិខិតបញ្ជាក់ការប្រើប្រាស់ ឬមិនបានប្រើប្រាស់ក្នុងអំឡុងពេលដែលបានកំណត់ដោយច្បាប់ និងអនុក្រឹត្យស្តីពីម៉ាក ម៉ាកដែលបានចុះបញ្ជីនោះនឹងលែងទទួលបានកិច្ចការពារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវជូនដំណឹងទៅការិយាល័យអន្តរជាតិអំពីបញ្ហានេះ ។

**ប្រការ២៣._ការជំនួសការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ ដោយការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ**

ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ អាចស្នើសុំនាយកដ្ឋានកម្មសិទ្ធិបញ្ញាឲ្យជំនួសការកត់ត្រាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ ទៅជាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

**ប្រការ២៤._ ការសុំប្តូរពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅជាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ**

ម្ចាស់ម៉ាកដែលបានចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ អាចស្នើនាយកដ្ឋានកម្មសិទ្ធិបញ្ញាសុំប្តូរពីការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ ទៅជាការចុះបញ្ជីម៉ាកក្នុងក្របខណ្ឌជាតិ ដោយអនុលោមតាមបទប្បញ្ញត្តិនៃពិធីសារទីក្រុងម៉ាឌ្រីដ និងបទប្បញ្ញត្តិរួម។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

### ប្រការ ២៥._ បដិវាទកម្ម

ក្នុងករណីមានទំនាស់រវាងប្រការទាំងឡាយនៃប្រកាសនេះ និងបទប្បញ្ញត្តិអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក ត្រូវអនុវត្តតាមមាត្រា ៦០ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់របស់ព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ២៦._ ប្រសិទ្ធភាពអនុវត្ត

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

<u>ចម្លងជូន៖</u>
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានគាំពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។

# ១២. ប្រកាសស្តីពី នីតិវិធីសម្រាប់កត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
**Nation - Religion - King**

**ក្រសួងពាណិជ្ជកម្ម**
*Ministry of Commerce*

លេខ ១៥៦ ព.ណ.ការប. ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីសម្រាប់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលផលិតផលទំនិញពាក់ម៉ាកផ្តាច់មុខ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពី ការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ/បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពី ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក
- យោងតាមការងារចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

# សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងបង្កើនប្រសិទ្ធភាពអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការការពារកម្មសិទ្ធិបញ្ញា ការប្រកួតប្រជែងដោយសេរី ការការពារផលប្រយោជន៍អ្នកប្រើប្រាស់ និងសំដៅទប់ស្កាត់អំពើគេចពន្ធ ការលក់តម្លើងថ្លៃដែលផ្ទុយនឹងគោលការណ៍ទីផ្សារសេរី និងការនាំចូល និងលក់ទំនិញក្លែងក្លាយ ព្រមទាំងដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម និងវិនិយោគទុននៅកម្ពុជា។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះមានគោលដៅ៖

១- កំណត់នីតិវិធីលម្អិតសម្រាប់ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និង ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

២- កំណត់វិសាលភាពនៃ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និង ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

៣- កំណត់គោលការណ៍ក្នុងការបែងចែកទំនិញពាក់ម៉ាកផ្តាច់មុខនៅក្នុងព្រះរាជាណាចក្រកម្ពុជា

៤- កំណត់នីតិវិធីដោះស្រាយវិវាទស្តីពី សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ

៥- ចូលរួមចំណែកក្នុងការទប់ស្កាត់អំពើគេចពន្ធ ប្រមូលកម្រៃសេវាសាធារណៈ និងចំណូលពន្ធជូនរដ្ឋតាមបទប្បញ្ញត្តិជាធរមាន ។

**ប្រការ ៣.- វិសាលភាព**

១- ប្រកាសនេះ មានវិសាលភាពអនុវត្តលើ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ សម្រាប់ទំនិញដែលបានចុះបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានកំណត់ក្នុងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល ។

២- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក និងការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខគ្របដណ្តប់តែទៅលើទំនិញសុទ្ធនិងថ្មី ដែលមិនទាន់បានដាក់លក់ជាលើកដំបូងក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

១- "ការប្រគល់សិទ្ធិផ្តាច់មុខ" គឺជាការចេញលិខិតប្រគល់សិទ្ធិផ្តាច់មុខដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជូនទៅអ្នកទទួលសិទ្ធិដែលជានីតិបុគ្គលសម្រាប់នាំចូលទំនិញពាក់ម៉ាកផ្តាច់មុខមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- "ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ" គឺជាការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខដោយក្រសួងពាណិជ្ជកម្ម ផ្អែកតាមការស្នើសុំរបស់នីតិបុគ្គលដែលបានទទួលសិទ្ធិផ្តាច់មុខពីម្ចាស់ម៉ាក។

### ប្រការ ៥.- វាក្យសព្ទ

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

១- "**លិខិតប្រគល់សិទ្ធិផ្តាច់មុខ**" សំដៅដល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខចេញដោយម្ចាស់ម៉ាកជូនទៅអ្នកទទួលសិទ្ធិ ដែលមានបញ្ជាក់ច្បាស់លាស់អំពី ម៉ាក ជំពូក និងប្រភេទនៃទំនិញ។

២- "**លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ**" សំដៅដល់លិខិតទទួលស្គាល់ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជាដែលចេញដោយក្រសួងពាណិជ្ជកម្ម។

៣- "**ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក**" សំដៅដល់ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកសម្រាប់នាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ក្រោយពីទទួលបានពីការចុះបញ្ជីម៉ាករួចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំដោយម្ចាស់ម៉ាកខ្លួនឯង ។

### ប្រការ ៦.- ទំនិញដែលមិនអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

ទំនិញដែលមិនអនុញ្ញាតឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខមានដូចខាងក្រោម៖

១- ទំនិញដែលបានប្រើរួចគ្រប់ប្រភេទ
២- ផលិតផលឱសថ
៣- មុខទំនិញហាមឃាត់ដូចមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

### ប្រការ ៧.- ទំនិញជាប់កម្រិតកំណត់

ចំពោះទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន អាចអនុញ្ញាតឲ្យធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលជាមុនសិន ។

### ប្រការ ៨.- ការកម្រិតសិទ្ធិដែលទទួលបានពីការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

១- ម្ចាស់ម៉ាកដែលទទួលបានលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬអ្នកដែលទទួលបានលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា មិនមានសិទ្ធិហាមឃាត់លើការនាំចូលនូវមុខទំនិញដូចខាងក្រោម៖

ក- ទំនិញដែលនាំចូលយកមកប្រើប្រាស់ដោយព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ក្រុមប្រឹក្សានៃអង្គចៅក្រម តុលាការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ។

ខ- ទំនិញនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅមិនធ្វើពាណិជ្ជកម្មនិងសម្រាប់ប្រើប្រាស់ជាប្រយោជន៍ មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ អង្គការជាតិ និងអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្តុំតម្លើង និងកែច្នៃបន្ថែម ការពិសោធន៍និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ អភិវឌ្ឍន៍កសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ និងទំនិញប្រើរួចគ្រប់ប្រភេទ។

២- បុគ្គល អង្គការ អង្គទូត និងក្រសួង ស្ថាប័ន ដែលមានបំណងនាំចូលទំនិញដូចមានចែងក្នុងប្រការ៨(១) ត្រូវស្នើសុំការអនុញ្ញាតពីក្រសួងពាណិជ្ជកម្ម ដោយមានភ្ជាប់មកជាមួយនូវឯកសារយោងដូចខាងក្រោម៖

ក- លិខិតអនុញ្ញាតពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចំពោះអង្គទូត និងអង្គការអន្តរជាតិ ឬលិខិតអនុញ្ញាតពីក្រសួងមហាផ្ទៃចំពោះអង្គការ ឬសហគមន៍ក្នុងស្រុក ឬលិខិតអនុញ្ញាតពីក្រសួងអាណាព្យាបាល ដែលមានបញ្ជាក់ពីបរិមាណ និងម៉ូដែល ព្រមទាំងគោលបំណងយកមកប្រើប្រាស់ ។

ខ- មុននឹងធ្វើការនាំចូលត្រូវមានកិច្ចសន្យាទិញ លក់ និង/ឬ វិក្កយបត្រប្រូហ្វ៊រម៉ា (Pro-forma) ឬឯកសារពាណិជ្ជកម្មដែលមានតម្លៃប្រហាក់ប្រហែល ។

គ- ក្រោយការនាំចូលត្រូវផ្តល់នូវវិក្កយបត្រទិញ លក់ និង/ឬ តារាងបញ្ជាក់អំពីបញ្ជីវេចខ្ចប់ (Packing list) និង/ឬ អញ្ញត្តិប័ណ្ណដឹកជញ្ជូន (Bill of Lading) និងប្រតិវេទន៍គយ (Customs Declaration) ។

៣- បន្ទាប់ពីចេញលិខិតអនុញ្ញាតនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដែលទទួលបានការលើកលែងក្នុងប្រការ៨ដោយលើកលែងចំណុច៤នៃប្រការនេះ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅរដ្ឋបាលគយនិងរដ្ឋាករនិងអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងជូនដំណឹងទៅអ្នកដែលបានទទួលសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ ដើម្បីជួយសម្រួលដល់ការនាំចូល។

៤- មិនតម្រូវឲ្យស្នើសុំលិខិតអនុញ្ញាតនាំចូលឡើយ ចំពោះទំនិញនិងសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដែលគ្មានលក្ខណៈពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ៩.- សិទ្ធិដែលទទួលបានពីការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

១- សិទ្ធិនាំចូលនិងចែកចាយទំនិញពាក់ម៉ាកផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់តាមរយៈការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

២- អ្នកទទួលសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ មានសិទ្ធិប្តឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ចំពោះបុគ្គលណាដែលបាននាំចូលនិងចែកចាយទំនិញស្របគ្នាដោយបំពាននូវសិទ្ធិរបស់ខ្លួន ដើម្បីរកដំណោះស្រាយដូចមានចែងក្នុងប្រការ១៨ នៃប្រកាសនេះ ។

៣- សិទ្ធិនាំចូលនិងចែកចាយទំនិញពាក់ម៉ាកផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផុតរលត់វិញ នៅពេលដែលទំនិញពាក់ម៉ាកផ្តាច់មុខនីមួយៗនោះ ត្រូវបានលក់និងទូទាត់រួចរាល់លើកដំបូងនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ១០.- បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិផ្តាច់មុខលើម៉ាក

១- សិទ្ធិផ្តាច់មុខលើម៉ាក

ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវយកម៉ាករបស់ខ្លួនមកធ្វើការចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមមាត្រា៣ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ សិទ្ធិប្រើប្រាស់ម៉ាករួមមាន ការផលិត ការផ្សព្វផ្សាយ ការលក់ ការនាំចេញ ការនាំចូលជាដើម ដូចមានកំណត់ក្នុងមាត្រា១១ ២៤ និង ៦៦ នៃច្បាប់ខាងលើ។ សិទ្ធិផ្តាច់មុខដែលទទួលបានពីការចុះបញ្ជី អាចផ្ទេរទៅភាគីណាមួយ ដោយមានការយល់ព្រមពីម្ចាស់ម៉ាក និងធ្វើការកត់ត្រានិងតម្កល់នៅក្រសួងពាណិជ្ជកម្ម។

២- គោលការណ៍ផុតរលត់សិទ្ធិ (Exhaustion of Rights)

ក- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មិនត្រូវបានរាប់បញ្ចូលការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ម៉ាក ឬដោយបុគ្គលដែលមានការយល់ព្រមពីម្ចាស់ម៉ាកនោះឡើយ ដូចបានកំណត់ក្នុងមាត្រា១១(គ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលកម្ពុជាបានកំណត់យកគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ (National Exhaustion of Rights)។

ខ- ផ្អែកតាមគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬអ្នកទទួលសិទ្ធិដែលបានកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខមានសិទ្ធិប្តឹងរារាំងការនាំចូលស្របគ្នា (Parallel Importation) នូវទំនិញពាក់ម៉ាកដូចគ្នា ដោយភាគីទីបី។

## ប្រការ ១១.- នីតិវិធីកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ

បុគ្គលដែលស្នើសុំការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមនីតិវិធីដូចខាងក្រោម៖

១- លក្ខខណ្ឌ

ក. បុគ្គលដែលអាចទទួលបាននូវការប្រគល់សិទ្ធិផ្តាច់មុខ ត្រូវមានទ្រង់ទ្រាយជានីតិបុគ្គល (អ្នកទទួលសិទ្ធិ) ។

ខ. ការប្រគល់សិទ្ធិផ្តាច់មុខត្រូវធ្វើឡើងតាមការព្រមព្រៀង រវាងអ្នកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ដែលត្រូវចុះហត្ថលេខាដោយភាគីអ្នកប្រគល់សិទ្ធិ និងត្រូវបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខាក្នុងនាមអ្នកប្រគល់សិទ្ធិដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស ឬក្រសួងយុត្តិធម៌ ។

គ. ក្នុងករណីដែលម្ចាស់ម៉ាកមិនបានប្រគល់សិទ្ធិផ្តាច់មុខដោយផ្ទាល់ទៅអ្នកទទួលសិទ្ធិក្នុងព្រះរាជាណាចក្រកម្ពុជា អ្នកទទួលសិទ្ធិដែលចង់ប្រគល់សិទ្ធិបន្ត ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម ដែលមានចែងអំពីសិទ្ធិប្រគល់សិទ្ធិបន្តទៀត។

ឃ. អ្នកទទួលសិទ្ធិ អាចដាក់ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល៣(បី)ខែយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិ ។

ង. ការដាក់ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវបង់កម្រៃសេវាសាធារណៈទៅតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ ។

ច. ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ អាចធ្វើទៅបានលុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅអ្នកស្នើសុំ ក្នុងករណីដែលមិនអាចធ្វើការកត់ត្រាបាន ឬតម្រូវឲ្យបំពេញឯកសារបន្ថែម ។

ឆ. ទំនិញពាក់ម៉ាកផ្តាច់មុខដែលបានកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ នៅក្រសួងពាណិជ្ជកម្មរួចហើយ មិនអាចអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់ជូនបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែការប្រគល់សិទ្ធិផ្តាច់មុខនោះ ត្រូវបានដកហូត ឬផុតសុពលភាព។

ជ. ការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ លើទំនិញតែមួយនិងពាក់ម៉ាកដូចគ្នាក៏ប៉ុន្តែមានយថាប្រភេទខុសគ្នា អាចអនុញ្ញាតឲ្យធ្វើការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខបាន លុះត្រាតែមានលិខិតប្រគល់សិទ្ធិផ្តាច់មុខពីម្ចាស់ដើម។

ឈ.ការប្រគល់សិទ្ធិផ្តាច់មុខ នឹងគ្មានអានុភាពចំពោះអ្នកទទួលសិទ្ធិ និងភាគីទីបីឡើយ ប្រសិនបើលិខិតប្រគល់សិទ្ធិផ្តាច់មុខមិនបានយកមកធ្វើការកត់ត្រានិងតម្កល់ឲ្យបានត្រឹមត្រូវតាមប្រកាសនេះ ។

២- ឯកសារតម្រូវ

ក. ពាក្យស្នើសុំកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវប្រើប្រាស់លិខិតផ្លូវការរបស់ក្រុមហ៊ុន និងត្រូវចុះហត្ថលេខា និងប្រថាប់ត្រាដោយអ្នកទទួលសិទ្ធិក្នុងស្រុក ឬម្ចាស់ម៉ាក។

ខ. លិខិតប្រគល់សិទ្ធិផ្តាច់មុខ ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពី៖

១. ឈ្មោះអ្នកប្រគល់សិទ្ធិ ឬ/និងអ្នកប្រគល់សិទ្ធិបន្ត និងអាសយដ្ឋានត្រឹមត្រូវតាមវិញ្ញាបនបត្រចុះបញ្ជីម៉ាក

២. ឈ្មោះនីតិបុគ្គលនិងទីស្នាក់ការក្រុមហ៊ុននៃអ្នកទទួលសិទ្ធិ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម

៣. កម្មវត្ថុនៃការប្រគល់សិទ្ធិផ្តាច់មុខត្រូវបញ្ជាក់អំពី ម៉ាក លេខចុះបញ្ជី ជំពូក និងប្រភេទនៃទំនិញ

៤. ប្រទេស ឬដែនដីគ្របដណ្តប់ដោយសិទ្ធិដែលបានប្រគល់

៥. កាលបរិច្ឆេទមានប្រសិទ្ធភាពអនុវត្តនៃលិខិតប្រគល់សិទ្ធិ

៦. សុពលភាពដោយមិនឲ្យលើសពីរយៈពេល១០ឆ្នាំ

៧. ឈ្មោះ និងហត្ថលេខារបស់អ្នកប្រគល់សិទ្ធិ ព្រមទាំងកាលបរិច្ឆេទ ។

គ. ឯកសារភ្ជាប់មកជាមួយនឹងពាក្យស្នើសុំ៖

១. ច្បាប់ដើមនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ចំនួន០១ច្បាប់ ។

២. លិខិតអនុញ្ញាតឲ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាលចំពោះមុខទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន ។

៣. ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកចំនួន ០១ច្បាប់ ។

៤. ច្បាប់ចម្លងនៃលក្ខន្តិកៈក្រុមហ៊ុន គោលការណ៍ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន០១ច្បាប់ ។

៥. ច្បាប់ចម្លងនៃប័ណ្ណប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែមរបស់នីតិបុគ្គលចំនួន០១ច្បាប់ ។

៦. វិក្កយបត្របង់ប្រាក់កម្រៃសេវាសាធារណៈ ។

## ប្រការ ១២.- ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក

១. តាមការស្នើសុំដោយស្ម័គ្រចិត្តពីម្ចាស់ម៉ាក ក្រសួងពាណិជ្ជកម្មអាចធ្វើការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក សម្រាប់សម្រួលដល់ការនាំចូលនិងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ការស្នើសុំលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ម្ចាស់ម៉ាកត្រូវបំពេញតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ៣ ប្រការ៥ចំណុច៣ ប្រការ៦ និង/ឬ ប្រការ៧ ប្រការ៨ និងប្រការ១១ ចំណុច១(ង) ចំណុច២(ក) និងចំណុច២(គ) ដោយលើកលែងចំណុច២(គ)(១) នៃប្រការនេះ។

## ប្រការ ១៣.- សុពលភាព ភារកិច្ច និងសិទ្ធិ

១- សុពលភាព

ក- លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា មានសុពលភាព២(ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

ខ- សុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា អាចមានរយៈពេលខ្លីជាង២(ពីរ)ឆ្នាំ ដោយផ្អែកតាមសុពលភាពអប្បបរមារបស់លិខិតណាមួយនៃ លិខិតប្រគល់សិទ្ធិផ្ដាច់មុខ វិញ្ញាបនបត្រចុះបញ្ជីម៉ាក និងលិខិតអនុញ្ញាតឲ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬរាជរដ្ឋាភិបាល។

២- កាតព្វកិច្ច

ក- ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ ត្រូវបោះពុម្ពផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់ផ្ដាច់មុខ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន៣(បី)លេខជាប់ៗគ្នា ។ ក្នុងករណីចាំបាច់ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ អាចបញ្ជូនច្បាប់ចម្លងនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខទៅអ្នកនាំចូលដោយផ្ទាល់ ដើម្បីអ្នកនាំចូលបានជ្រាបជាព័ត៌មាន ។

ខ- នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខនោះ ក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និង/ឬ ក្នុងគេហទំព័រ www.cambodiaip.gov.kh ។

គ- អ្នកនាំចូលទំនិញតែមួយ ពាក់ម៉ាកដូចគ្នាទៅនឹងទំនិញដែលមានលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខរួចហើយ ត្រូវបញ្ចប់ប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន រួមទាំងទំនិញដែលស្តុកទុកក្នុងឃ្លាំងក្នុងរយៈពេល ៩០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ ដែលចេញដោយក្រសួងពាណិជ្ជកម្ម ។

៣- សិទ្ធិ

ចាប់ពីរយៈពេល៩០(កៅសិប)ថ្ងៃ ដូចបានកំណត់ក្នុងប្រការ១៣ចំណុច២(គ)ខាងលើ ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់ មានសិទ្ធិប្ដឹងទៅរដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីចាត់វិធានការតាមបញ្ញត្តិច្បាប់ជាធរមាន ចំពោះទំនិញតែមួយពាក់ម៉ាកដូចគ្នា ។

**ប្រការ ១៤.- ការបាត់បង់សុពលភាពជាស្វ័យប្រវត្តិ**

សុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្ដាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្ដាច់មុខ ត្រូវបាត់បង់ជាស្វ័យប្រវត្តិ ប្រសិនបើៈ

ក- ការប្រគល់សិទ្ធិផ្ដាច់មុខត្រូវបានដកហូតវិញ ឬ

ខ- សុពលភាពនៃការចុះបញ្ជីម៉ាកត្រូវបាត់បង់ដោយប្រការណាមួយ ឬ

គ- ការចុះបញ្ជីម៉ាកដែលបានចុះបញ្ជីរួចហើយត្រូវបានប្ដូរម្ចាស់កម្មសិទ្ធិ ឬ

ឃ- ការនាំចូលទំនិញជាប់កម្រិតកំណត់ដែលបានអនុញ្ញាត ត្រូវបាននាំចូលគ្រប់ចំនួនរួចហើយ ឬ

ង- ការអនុញ្ញាតឲ្យនាំចូលទំនិញជាប់កម្រិតកំណត់ ត្រូវបានដកហូតវិញ ។

**ប្រការ ១៥.- មោឃភាពនៃការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ**

១- លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ បានចេញដោយក្រសួងពាណិជ្ជកម្មកន្លងមកដែលមិនបានកំណត់សុពលភាព ត្រូវចាត់ទុកជានិរាករណ៍ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីប្រកាសនេះចូលជាធរមាន ។

២- ជនណាដែលមានការពាក់ព័ន្ធអាចស្នើសុំក្រសួងពាណិជ្ជកម្ម ឲ្យផ្តល់មោឃភាពលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខបាន។

៣- ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើមោឃភាពលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ក្នុងករណីបុគ្គលដែលស្នើសុំនោះបង្ហាញថា៖

ក- លិខិតបញ្ជាក់ ឬលិខិតកត់ត្រានិងតម្កល់ មិនបានបំពេញលក្ខខណ្ឌតម្រូវនៃប្រការណាមួយនៃប្រកាសនេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬ

ខ- លិខិតប្រគល់សិទ្ធិផ្តាច់មុខមានភាពមិនប្រក្រតីដោយប្រការណាមួយ។

៤- ក្រសួងពាណិជ្ជកម្ម មានសិទ្ធិលុបការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬការកត់ត្រានិងតម្កល់លិខិតប្រគល់ផ្តាច់មុខប្រសិនបើ៖

ក- បុគ្គលណាដែលអនុវត្តផ្ទុយនឹងសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០៧ សរណន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៥ ស្តីពី ការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ឬ

ខ- មានការស្នើសុំពីម្ចាស់ម៉ាក ឬពីអ្នកទទួលសិទ្ធិដោយភ្ជាប់មកជាមួយនូវឯកសារយោងគ្រប់គ្រាន់ ។

៥. ពាក្យស្នើសុំធ្វើមោឃភាពចំពោះលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវបង់ប្រាក់កម្រៃសេវាសាធារណៈដោយអ្នកដាក់ពាក្យស្នើសុំតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយមិនអាចដកយកវិញ ឬបង្វែរទៅបង់ខ្ទង់ចំណាយផ្សេងទៀតបានឡើយ ។

៦- ការធ្វើមោឃភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវមានអានុភាពអនុវត្តចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច។

**ប្រការ១៦.- ការបន្តសុពលភាព**

១- បុគ្គលដែលមានគោលបំណងបន្តសុពលភាពនៃ លិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ត្រូវដាក់ពាក្យស្នើសុំឲ្យបាន៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាព ហើយត្រូវបំពេញតាមនីតិវិធីនិងលក្ខខណ្ឌ ដូចខាងក្រោម៖

ក- អ្នកដាក់ពាក្យស្នើសុំ ត្រូវបង់ប្រាក់កម្រៃសេវាសាធារណៈដូចបានកំណត់ក្នុងប្រកាសជាធរមាន ។

ខ- ច្បាប់ចម្លងនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ដែលបានតម្កល់នៅក្រសួងពាណិជ្ជកម្ម នៅមានសុពលភាពនៅឡើយ ។ ក្នុងករណីលិខិតប្រគល់សិទ្ធិផ្តាច់មុខបានផុតសុពលភាព អ្នកស្នើសុំត្រូវដាក់លិខិតប្រគល់សិទ្ធិផ្តាច់មុខថ្មី។

គ- ត្រូវបំពេញលក្ខខណ្ឌ នីតិវិធី និងឯកសារតម្រូវដូចមាននៅពេលដាក់ពាក្យស្នើសុំដំបូង ដូចមានចែងក្នុងប្រការ១១ នៃប្រកាសនេះ ។

២- ក្នុងករណី លិខិតប្រគល់សិទ្ធិផ្តាច់មុខ និងវិញ្ញាបនបត្រចុះបញ្ជីម៉ាក ព្រមទាំងលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន នៅមានសុពលភាពចាប់ពី ២(ពីរ)ឆ្នាំ ឡើងទៅ ការបន្តសុពលភាពត្រូវមានរយៈពេល២(ពីរ)ឆ្នាំ ។ ក្នុងករណីលិខិតប្រគល់សិទ្ធិ និងវិញ្ញាបនបត្រចុះបញ្ជីម៉ាក ព្រមទាំងលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន មានសុពលភាពតិចជាង២(ពីរ)ឆ្នាំ ការបន្តសុពលភាពត្រូវមានរយៈពេលស្មើនឹងសុពលភាពអប្បបរមានៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក ឬលិខិតពាក់ព័ន្ធតាមការកំណត់ក្នុងប្បញ្ញត្តិច្បាប់ជាធរមាន ។

៣- លិខិតបន្តសុពលភាពមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃផុតសុពលភាពនៃលិខិតបញ្ជាក់អំពីសិទ្ធិផ្តាច់មុខលើម៉ាក ឬលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខ ហើយត្រូវបោះពុម្ពផ្សាយដូចមានចែងក្នុងប្រការ១៣ ចំណុច២(ក) និង (ខ) នៃប្រកាសនេះ។

**ប្រការ ១៧.-សិទ្ធិនិងរយៈពេលនៃបណ្តឹងតវ៉ា**

១- ជនណាដែលមានការពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅក្រុមប្រឹក្សាបណ្តឹងតវ៉ា ឬតុលាការមានសមត្ថកិច្ច ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេចពាក់ព័ន្ធនឹងការបញ្ជាក់ ឬការកត់ត្រានិងតម្កល់លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រសួងពាណិជ្ជកម្ម ។

២- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ាជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្តីសម្រេច។

**ប្រការ ១៨.- ការបំពានសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ និងនីតិវិធីដោះស្រាយវិវាទ**

ការបំពានសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខត្រូវដោះស្រាយតាមនីតិវិធី ដូចខាងក្រោម៖

១- អ្នកទទួលសិទ្ធិស្របច្បាប់ អាចចេញលិខិតព្រមានដល់អ្នកនាំចូលទំនិញស្របគ្នាឲ្យបញ្ឈប់ការនាំចូលដែលបំពានទៅលើសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខរបស់ខ្លួន ។

២- តាមការស្នើសុំអន្តរាគមន៍ពីអ្នកទទួលសិទ្ធិស្របច្បាប់ ក្រសួងពាណិជ្ជកម្មអាចចេញលិខិតព្រមានដល់អ្នកនាំចូលទំនិញស្របគ្នា ឲ្យបញ្ឈប់ការនាំចូលដែលបំពានទៅលើសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ។

៣- អ្នកទទួលសិទ្ធិស្របច្បាប់ និងអ្នកនាំចូលទំនិញស្របគ្នាអាចធ្វើការសម្រុះសម្រួលអំពីផលប៉ះពាល់ និងការខូចខាតអំពីការនាំចូលទំនិញស្របគ្នាដោយៈ

- អនុញ្ញាតឲ្យអ្នកនាំចូលស្របគ្នាបន្តលក់ទំនិញ ដែលរំលោភសិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខតាមរយៈសងការខូចខាតជូនអ្នកទទួលសិទ្ធិស្របច្បាប់ក្នុងតម្លៃឯកភាពគ្នា ឬ
- អ្នកទទួលសិទ្ធិស្របច្បាប់ទទួលទិញទំនិញដែលនាំចូលស្របគ្នាតាមតម្លៃស្រុះស្រួល។

៤- ក្នុងករណីគ្មានការឯកភាពគ្នាតាមជម្រើសខាងលើ ទំនិញដែលនាំចូលនោះត្រូវបញ្ជូនត្រឡប់ទៅប្រភពដើមវិញ ។

៥- ភាគីវិវាទត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលសម្រុះសម្រួល ដោយចុះហត្ថលេខា ឬផ្តិតមេដៃចំពោះមុខ និងមានការចុះហត្ថលេខាដឹងឮ ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ជូនមួយច្បាប់មកក្រសួងពាណិជ្ជកម្ម។

៦- កំណត់ហេតុស្តីពីលទ្ធផលសម្រុះសម្រួលអាចប្រើប្រាស់ជាឯកសារយោងអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

៧- ក្នុងករណីគ្មានការឯកភាពលើការសម្រុះសម្រួលណាមួយ ភាគីវិវាទអាចប្តឹងទៅតុលាការមានសមត្ថកិច្ច ។

**ប្រការ ១៩.- ភារកិច្ចអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**ចម្លងជូនៈ**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
- ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានគាំពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ ។

# ១៣. ប្រកាសស្ដីពីនីតិវិធីនៃការដាក់ស្នើសុំចុះបញ្ជីម៉ាក តាមប្រព័ន្ធអេឡិចត្រូនិក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៦៥ ព.ណ.កសប.ប្រក

## ប្រកាស
## ស្តីពី
## នីតិវិធីនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៤/០០៦ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញប្រកាសលេខ ២០៦ ពណ.បអ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា
- បានឃើញប្រកាសលេខ ២៩៣ ពណ.កសប.ប្រក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួង ពាណិជ្ជកម្ម ស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកវិញ្ញាតកម្ម
- បានឃើញប្រកាសលេខ ៣៦៨ ពណ.កសប.ប្រក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីចុះបញ្ជីម៉ាកក្នុងក្របខណ្ឌអន្តរជាតិ

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

- បានឃើញប្រកាសលេខ ៤២២ ពណ.កសប.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម ស្តីពីនីតិវិធីចុះបញ្ជី និងកិច្ចការពារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ។

## សម្រេច

### ប្រការ ១.-គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់នីតិវិធីសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក តាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈគេហទំព័រ www.efiling.cambodiaip.gov.kh ។

### ប្រការ ២.-គោលដៅ

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនិងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក
- គាំទ្រដល់ការផ្តល់សេវាចុះបញ្ជីម៉ាកឲ្យបានកាន់តែល្អប្រសើរឡើង
- សម្រួលដល់ការគ្រប់គ្រងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងម៉ាក
- គ្រប់គ្រងការផ្តល់លិខិត និងឯកសារពាក់ព័ន្ធផ្សេងៗ
- គ្រប់គ្រងការប្រមូលកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងកិច្ចការពារម៉ាកឲ្យបានកាន់តែមានប្រសិទ្ធភាពថែមទៀត ។

### ប្រការ ៣.-វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តលើការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ប្រការ ៤.- វាក្យសព្ទ

សម្រាប់គោលដៅនៃប្រកាសនេះ៖

"ម៉ាក" សំដៅដល់ ម៉ាក ម៉ាកសមូហភាព ពាណិជ្ជនាម ម៉ាកវិញ្ញាតកម្ម និងម៉ាកសម្គាល់ភូមិសាស្ត្រ។

"ប្រព័ន្ធអេឡិចត្រូនិក" សំដៅដល់ប្រព័ន្ធដែលរៀបចំឡើងសម្រាប់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមអេឡិចត្រូនិក ។

"អ្នកដាក់ពាក្យស្នើសុំ" សំដៅដល់ អ្នកស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក តាមប្រព័ន្ធអេឡិចត្រូនិក ។

### ប្រការ ៥.-បទប្បញ្ញត្តិដែលអាចអនុវត្តបាន

បទប្បញ្ញត្តិពាក់ព័ន្ធទាំងឡាយ នៃច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ច្បាប់ ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាដែលអាចអនុវត្តបាន ត្រូវយកមកអនុវត្តផងដែរចំពោះការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ។

## ប្រការ ៦.-សមត្ថកិច្ចគ្រប់គ្រង

នាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម មានសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធអេឡិចត្រូនិក ការទទួលពាក្យស្នើសុំសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាក និងការផ្ដល់ឈ្មោះគណនី និងលេខកូដសម្ងាត់សម្រាប់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក ។

## ប្រការ ៧.-អ្នកដាក់ពាក្យស្នើសុំ

អ្នកដាក់ពាក្យស្នើសុំដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម ស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចធ្វើឡើងតាមប្រព័ន្ធអេឡិចត្រូនិក ។

អ្នកដាក់ពាក្យស្នើសុំដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬទីតាំងប្រកបអាជីវកម្ម ស្ថិតនៅក្រៅព្រះរាជាណាចក្រកម្ពុជា ការស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិកត្រូវធ្វើឡើងដោយភ្នាក់ងារតំណាងស្របច្បាប់ដែលមានទីលំនៅ និងកំពុងប្រកបវិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងដែលដាក់ពាក្យស្នើសុំតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវភ្ជាប់មកជាមួយឯកសារតម្រូវ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាទម្រង់អេឡិចត្រូនិក ។

អ្នកដាក់ពាក្យស្នើសុំ ឬភ្នាក់ងារតំណាងត្រូវធានាថា រាល់ឯកសារតម្រូវភ្ជាប់ជាទម្រង់អេឡិចត្រូនិក ដែលផ្ដល់មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ជាឯកសារពិត និងឥតក្លែងបន្លំ ។

ជនណាដែលផ្ដល់ព័ត៌មានមិនពិត ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្ដន្ទាទោសតាមមាត្រា ៦៣ នៃច្បាប់ស្ដីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងច្បាប់ពាក់ព័ន្ធជាធរមាន ។

## ប្រការ ៨.-ការដាក់ពាក្យស្នើសុំ

ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក តម្រូវឲ្យមានឈ្មោះគណនី និងលេខកូដសម្ងាត់ ដែលកំណត់ដោយនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម ។

ក្រោយការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវផ្ដល់ឯកសារតម្រូវជាទម្រង់ច្បាប់ដើម ឬទម្រង់ច្បាប់ចម្លងដោយមានបញ្ជាក់ពីភាពត្រឹមត្រូវ មកនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្ម តាមកាលកំណត់ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

## ប្រការ ៩.-កម្រៃសេវា

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក និងសេវាផ្សេងៗពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក ត្រូវបង់កម្រៃសេវាតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ ដោយអនុលោមតាមប្រកាសរួមលេខ ១៦៤៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតជាធរមាន ឬលិខិតបទដ្ឋានគតិយុត្តដែលនឹងត្រូវបានធ្វើវិសោធនកម្ម ។

**ប្រការ ១០.-ប្រសិទ្ធភាពអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និងប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ទទួលបន្ទុកប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ១០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ។

# ១៤. ប្រកាសស្តីពីនីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករដ្ឋមន្ត្រីពាណិជ្ជកម្ម ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០១១៧ ព.ណ.ក.កម.ប្រក

# ប្រកាស
# ស្តីពី
# នីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ខែ មីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសារាចរណែនាំលេខ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

### ប្រការ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងកំណត់នីតិវិធីគ្រប់គ្រងការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា លុបបំបាត់ការប្រកួតប្រជែងមិនស្មោះត្រង់ ផ្តល់ការការពារ និងផលប្រយោជន៍របស់ម្ចាស់សិទ្ធិ និងសាធារណៈ ដោយទប់ស្កាត់ការនាំចូល និងចែកចាយទំនិញក្លែងក្លាយ ការលក់បង្ខូចថ្លៃ បំពេញតាមស្តង់ដារជាតិ អន្តរជាតិ ដើម្បីលើកកម្ពស់ពាណិជ្ជកម្ម និងវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## ប្រការ២.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តលើការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ចំពោះទំនិញនាំចូលដែលសុទ្ធ និងថ្មី ដែលបានចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបានកំណត់ក្នុងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការទទួលស្គាល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៣.- និយមន័យ

**វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម៖**

១. **ការប្រគល់សិទ្ធិផ្ដាច់មុខ** គឺជាការព្រមព្រៀងដោយស្ម័គ្រចិត្តរវាងអ្នកប្រគល់សិទ្ធិ និងអ្នកទទួលសិទ្ធិ ក្នុងការអនុញ្ញាតឱ្យប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា។

២. **ទំនិញក្រោមសិទ្ធិផ្ដាច់មុខ** សំដៅដល់ទំនិញដែលទទួលបានលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬទទួលបានលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ពីក្រសួងពាណិជ្ជកម្ម ហើយដែលអាចអនុវត្តសិទ្ធិដូចមានចែងក្នុងប្រកាសនេះ។

៣. **លិខិតប្រគល់សិទ្ធិផ្ដាច់មុខ** សំដៅដល់លិខិតជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយអ្នកប្រគល់សិទ្ធិជូនទៅអ្នកទទួលសិទ្ធិ ដែលមានអាសយដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានការបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។

៤. **លិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត** សំដៅដល់លិខិតជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយអ្នកប្រគល់សិទ្ធិ ជូនអ្នកប្រគល់សិទ្ធិបន្ត ដែលមានអាសយដ្ឋានក្នុង ឬក្រៅ ព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យបន្តការផ្ដល់សិទ្ធិផ្ដាច់មុខជូនអ្នកទទួលសិទ្ធិ ដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានការបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។

៥. **លិខិតប្រគល់សិទ្ធិផ្ដាច់មុខបន្ត** សំដៅដល់លិខិតជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយអ្នកប្រគល់សិទ្ធិបន្តដែលជានីតិបុគ្គលដែលមានអាសយដ្ឋាននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្តពីអ្នកប្រគល់សិទ្ធិជាមុនសិន បន្ទាប់មក អ្នកប្រគល់សិទ្ធិបន្តចេញលិខិតប្រគល់សិទ្ធិផ្ដាច់មុខបន្ត ជូនអ្នកទទួលសិទ្ធិដែលមានអាសយដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ក្នុងការប្រើប្រាស់ម៉ាកផ្ដាច់មុខសម្រាប់ការនាំចូល និងចែកចាយទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមានបញ្ជាក់អំពីម៉ាក ជំពូក យថាប្រភេទ និង/ឬ ម៉ូឌែលនៃទំនិញ។

៦. **លិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក** សំដៅដល់លិខិតរបស់ក្រសួងពាណិជ្ជកម្ម ដែលបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក សម្រាប់ការនាំចូល និងចែកចាយទំនិញក្នុងព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំរបស់ម្ចាស់ម៉ាកក្នុងស្រុកដែលបានចុះបញ្ជីម៉ាក និងមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៧. **លិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក** សំដៅដល់លិខិតរបស់ក្រសួងពាណិជ្ជកម្មដែលបានកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកសម្រាប់ការនាំចូល និងចែកចាយទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីអ្នកប្រគល់សិទ្ធិដែលបានចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា ជូនអ្នកទទួលសិទ្ធិជានីតិបុគ្គលដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៨. **អ្នកប្រគល់សិទ្ធិ** សំដៅដល់ម្ចាស់ម៉ាកដែលមានអាសយដ្ឋាននៅក្រៅព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជីម៉ាកនៅព្រះរាជាណាចក្រកម្ពុជា ហើយប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកជូនអ្នកទទួលសិទ្ធិ ដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។

៩. **ម្ចាស់ម៉ាកក្នុងស្រុក** សំដៅដល់នីតិបុគ្គល ដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលបានចុះបញ្ជីម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នើសុំក្រសួងពាណិជ្ជកម្មធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាកក្នុងការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០. **អ្នកទទួលសិទ្ធិ** រួមមាន អ្នកទទួលសិទ្ធិផ្ទាល់ និងអ្នកទទួលសិទ្ធិបន្ត។ អ្នកទទួលសិទ្ធិផ្ទាល់ ដែលមានអាសយដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលសិទ្ធិផ្តាច់មុខពីអ្នកប្រគល់សិទ្ធិ ហើយដែលបានដាក់ពាក្យស្នើសុំកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។ អ្នកទទួលសិទ្ធិបន្ត ដែលមានអាសយដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា បានទទួលសិទ្ធិពីអ្នកប្រគល់សិទ្ធិបន្ត ហើយដែលបានដាក់ពាក្យស្នើសុំកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។

## ប្រការ៤.- ទំនិញដែលលើកលែងសិទ្ធិផ្តាច់មុខ

ទំនិញដែលមិនអនុញ្ញាតឱ្យធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម៖

១. ទំនិញដែលបានប្រើប្រាស់រួចគ្រប់ប្រភេទ។

២. ផលិតផលឱសថសម្រាប់មនុស្ស និងសត្វ។

៣. ជី និងថ្នាំកសិកម្ម។

៤. មុខទំនិញហាមឃាត់ ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ប្រការ៥.- ទំនិញជាប់កម្រិតកំណត់

ទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន លើកលែងទំនិញដែលមានចែងក្នុងចំណុច២ និងចំណុច៣ នៃប្រការ៤ខាងលើ អាចអនុញ្ញាតឱ្យធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខ ក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្មបាន លុះត្រាតែមានលិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរាជរដ្ឋាភិបាលជាមុន។

## ប្រការ៦.- ការកម្រិតសិទ្ធិរបស់ម្ចាស់ម៉ាក និងអ្នកទទួលសិទ្ធិ

១. បន្ទាប់ពីក្រសួងពាណិជ្ជកម្មចេញលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិ មិនអាចហាមឃាត់ក្នុងការនាំចូលទំនិញ តាមលក្ខខណ្ឌដូចខាងក្រោម៖

ក. ទំនិញក្រោមសិទ្ធិផ្តាច់មុខដែលនាំចូលយកមកប្រើប្រាស់ដោយស្ថាប័ន ព្រះបរមរាជវាំង ព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល។

ខ. ទំនិញក្រោមសិទ្ធិផ្តាច់មុខនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅមិនធ្វើពាណិជ្ជកម្ម និងសម្រាប់ប្រើប្រាស់ជាប្រយោជន៍ដល់សង្គម មនុស្សធម៌ ផ្ទាល់ខ្លួន បេសកកម្មការទូត សហគមន៍ សមាគម អង្គការជាតិ និងអង្គការអន្តរជាតិ ភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ការផ្គុំដំឡើងនិងកែច្នៃបន្ថែម ការពិសោធន៍និងស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រ ទំនិញគំរូសម្រាប់តាំងបង្ហាញ ការអភិវឌ្ឍកសិកម្ម កិច្ចសន្យាផលិតកម្មកសិកម្ម គម្រោងវិនិយោគឯកជន វិនិយោគសាធារណៈ និងទំនិញប្រើប្រាស់រួចគ្រប់ប្រភេទ។

គ. ចំពោះទំនិញក្រោមសិទ្ធិផ្ដាច់មុខ ដែលនាំចូលដោយរូបវន្តបុគ្គលក្នុងអីវ៉ាន់ផ្ទាល់ខ្លួនដែលគ្មានលក្ខណៈពាណិជ្ជកម្ម ត្រូវលើកលែងការអនុវត្តសិទ្ធិផ្ដាច់មុខក្នុងប្រកាសនេះ។

ឃ. ទំនិញនាំចូល ដើម្បីនាំចេញគ្រប់ប្រភេទ។

## ប្រការ៧._ សិទ្ធិផ្ដាច់មុខដែលទទួលបាន

១. សិទ្ធិនាំចូល និងចែកចាយទំនិញផ្ដាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលស្គាល់តាមរយៈការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២. ម្ចាស់ម៉ាកក្នុងស្រុកដែលទទួលបានការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬអ្នកទទួលសិទ្ធិពីការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក មានសិទ្ធិប្ដឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ចំពោះបុគ្គលណាដែលបាននាំចូល និងចែកចាយទំនិញក្រោមសិទ្ធិផ្ដាច់មុខស្របគ្នាដោយរំលោភបំពាននូវសិទ្ធិរបស់ខ្លួន ដើម្បីរកដំណោះស្រាយដូចមានចែងក្នុងប្រការ១៦ នៃប្រកាសនេះ។

៣. សិទ្ធិនាំចូល និងចែកចាយទំនិញក្រោមលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវផុតរលត់វិញ នៅពេលដែលទំនិញក្រោមសិទ្ធិផ្ដាច់មុខនីមួយៗ ត្រូវបានលក់លើកដំបូងនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៨._ បទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិផ្ដាច់មុខតាមរយៈការចុះបញ្ជីម៉ាក

**១. ការទទួលបានសិទ្ធិផ្ដាច់មុខតាមរយៈការចុះបញ្ជីម៉ាក**

ដើម្បីទទួលបានសិទ្ធិផ្ដាច់មុខលើម៉ាក អ្នកស្នើសុំត្រូវចុះបញ្ជីម៉ាកនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ដោយអនុលោមតាមមាត្រា៣ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។ សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក រួមមាន ការផលិត ការផ្សព្វផ្សាយ ការលក់ ការនាំចេញ ការនាំចូលជាដើម ដូចមានកំណត់ក្នុងមាត្រា១១ មាត្រា២៤ និងមាត្រា៦៦ នៃច្បាប់ខាងលើ។ សិទ្ធិផ្ដាច់មុខដែលទទួលបានពីការចុះបញ្ជីម៉ាក អាចផ្ទេរម្ចាស់កម្មសិទ្ធិម៉ាកទៅឱ្យភាគីណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ម៉ាក និងបានធ្វើការកត់ត្រា នៅក្រសួងពាណិជ្ជកម្ម។

**២. គោលការណ៍ផុតរលត់សិទ្ធិ**

ក. សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មិនត្រូវបានរាប់បញ្ចូលការដាក់លក់ទំនិញនៅលើទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ម៉ាក ឬដោយបុគ្គលដែលមានការយល់ព្រមពីម្ចាស់ម៉ាកនោះឡើយ ដូចបានកំណត់ក្នុងមាត្រា១១(គ) នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលកម្ពុជាបានកំណត់យកគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ។

ខ. ផ្អែកតាមគោលការណ៍ផុតរលត់សិទ្ធិកម្រិតជាតិ ម្ចាស់ម៉ាក ដែលបានចុះបញ្ជី ឬអ្នកទទួលសិទ្ធិពីលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក មានសិទ្ធិដាក់ពាក្យបណ្ដឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ដើម្បីហាមឃាត់ការនាំចូលស្របគ្នានូវទំនិញរំលោភបំពានសិទ្ធិផ្ដាច់មុខ។

## ប្រការ៩._ លក្ខខណ្ឌ និងឯកសារតម្រូវ

បុគ្គលដែលស្នើសុំបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញតាមលក្ខខណ្ឌ និងផ្ដល់ឯកសារតម្រូវ ដូចខាងក្រោម៖

**១. លក្ខខណ្ឌ**

ក. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិដែលស្នើសុំបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវតែជានីតិបុគ្គល។

ខ. លិខិតប្រគល់សិទ្ធិផ្តាច់មុខត្រូវធ្វើឡើងតាមការព្រមព្រៀងដោយស្ម័គ្រចិត្ត ជាលាយលក្ខណ៍អក្សរ រវាងអ្នកប្រគល់សិទ្ធិជាមួយអ្នកទទួលសិទ្ធិ ហើយត្រូវចុះហត្ថលេខាដោយអ្នកប្រគល់សិទ្ធិ ឬតំណាង និងត្រូវមានបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខា ដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងយុត្តិធម៌។

គ. ក្នុងករណីដែលអ្នកប្រគល់សិទ្ធិអនុញ្ញាតឱ្យអ្នកប្រគល់សិទ្ធិបន្ត ប្រគល់សិទ្ធិជូនអ្នកទទួលសិទ្ធិណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមាន៖

១. លិខិតប្រគល់សិទ្ធិផ្តាច់មុខដែលមានបញ្ជាក់ពីសុពលភាពពីអ្នកប្រគល់សិទ្ធិ ជូនអ្នកប្រគល់សិទ្ធិបន្តដែលមានអាសយដ្ឋាននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ដោយមានបញ្ជាក់ថាអ្នកប្រគល់សិទ្ធិបន្តនេះ អាចប្រគល់សិទ្ធិបន្តជូនអ្នកទទួលសិទ្ធិដែលមានអាសយដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ហើយត្រូវចុះហត្ថលេខាដោយអ្នកប្រគល់សិទ្ធិបន្ត ឬតំណាង និងត្រូវមានការបញ្ជាក់ពីភាពត្រឹមត្រូវនៃសមត្ថកិច្ចរបស់អ្នកចុះហត្ថលេខា ដោយសាការី ឬអង្គភាពដែលមានសមត្ថកិច្ចនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងយុត្តិធម៌។

២. អ្នកប្រគល់សិទ្ធិបន្ត ត្រូវចេញលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ជូនអ្នកទទួលសិទ្ធិដែលមានអាសយដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាហើយលិខិតនេះត្រូវមានបញ្ជាក់សុពលភាព។

ឃ. អ្នកទទួលសិទ្ធិ អាចដាក់ពាក្យស្នើសុំការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ក្នុងរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទនៃការចុះហត្ថលេខានៅលើលិខិតប្រគល់សិទ្ធិផ្តាច់មុខ។ ក្នុងករណីដែលលិខិតប្រគល់សិទ្ធិផ្តាច់មុខមានកំណត់ពីកាលបរិច្ឆេទចូលជាធរមាន ត្រូវជ្រើសរើសកាលបរិច្ឆេទចូលជាធរមាននៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ។

ង. ការដាក់ពាក្យស្នើសុំបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃទៅតាមការកំណត់នៅក្នុងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ហើយកម្រៃដែលបានបង់រួចមិនអាចដកយកមកវិញ ឬផ្ទេរបានឡើយ។

ច. ការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក អាចធ្វើទៅបានលុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវនានានៃប្រកាសនេះ។ ក្រសួងពាណិជ្ជកម្មត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំ ក្នុងករណីដែលមិនអាចធ្វើការកត់ត្រាបាន ឬតម្រូវឱ្យបំពេញឯកសារបន្ថែម។

ឆ. ទំនិញតែមួយ ដែលទទួលបានការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក នៅក្រសួងពាណិជ្ជកម្មរួចហើយ មិនអាចអនុញ្ញាតឱ្យធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកជូនបុគ្គលផ្សេងទៀតបានឡើយ លើកលែងតែការប្រគល់សិទ្ធិផ្តាច់មុខនោះ ត្រូវបានដកហូត ឬធ្វើមោឃភាព ឬផុតសុពលភាព។

ជ. ការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក លើទំនិញក្នុងជំពូកតែមួយ ដែលមានម៉ាកដូចគ្នា ប៉ុន្តែមានយថាប្រភេទ និងម៉ូឌែលនៃទំនិញខុសគ្នា អាចអនុញ្ញាតឱ្យធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកបាន លុះត្រាតែលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកពីអ្នកប្រគល់សិទ្ធិមានបញ្ជាក់អំពីយថាប្រភេទនិងម៉ូឌែលនៃទំនិញនីមួយៗនៃម៉ាក។

ឈ. លិខិតប្រគល់សិទ្ធិផ្តាច់មុខ មិនអាចអនុវត្តសិទ្ធិក្រោមប្រកាសនេះបានទេ ប្រសិនបើលិខិតប្រគល់សិទ្ធិផ្តាច់មុខនេះ មិនបានយកមកធ្វើការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកនៅក្រសួងពាណិជ្ជកម្ម។

២. ឯកសារតម្រូវ

ក. ពាក្យស្នើសុំបញ្ជាក់អំពីសិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាកក្នុងស្រុក ឬតំណាង ដែលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និងមានបោះត្រារបស់នីតិបុគ្គល។ ពាក្យស្នើសុំសម្រាប់ការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវចុះហត្ថលេខា ដោយអ្នកទទួលសិទ្ធិ ឬតំណាង ដែលមានសិទ្ធិចុះហត្ថលេខាក្នុងនាមនីតិបុគ្គល និង/ឬមានបោះត្រារបស់នីតិបុគ្គល។

ខ. លិខិតប្រគល់សិទ្ធិផ្តាច់មុខ និង/ឬលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត និង/ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ត្រូវមានបញ្ជាក់កាលបរិច្ឆេទសុពលភាព និងព័ត៌មាន ដូចខាងក្រោម៖

១. ឈ្មោះរបស់អ្នកប្រគល់សិទ្ធិ ដែលជាម្ចាស់ម៉ាក បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអាសយដ្ឋាន ដូចក្នុងវិញ្ញាបនបត្រចុះបញ្ជីម៉ាក និងឈ្មោះរបស់អ្នកទទួលសិទ្ធិ និងអាសយដ្ឋាន ចំពោះលិខិតប្រគល់សិទ្ធិផ្តាច់មុខ។

២. ឈ្មោះរបស់អ្នកប្រគល់សិទ្ធិ ដែលជាម្ចាស់ម៉ាក បានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងឈ្មោះរបស់អ្នកប្រគល់សិទ្ធិបន្ត ដែលមានអាសយដ្ឋាននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ចំពោះលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត។

៣. ឈ្មោះរបស់អ្នកប្រគល់សិទ្ធិបន្ត ដែលមានអាសយដ្ឋានក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា និងអ្នកទទួលសិទ្ធិដែលជានីតិបុគ្គល ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងមានបញ្ជាក់អាសយដ្ឋាន ចំពោះលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត។

៤. ម៉ាក លេខចុះបញ្ជី ជំពូក និងយថាប្រភេទ ឬម៉ូឌែលនៃទំនិញ។ ចំពោះទោចក្រយានយន្ត ត្រីចក្រយានយន្ត រថយន្ត និងយានយន្តដទៃទៀត ត្រូវមានបញ្ជាក់ពីម៉ាកនៃម៉ូឌែលនីមួយៗ យថាប្រភេទ ឬទំហំស៊ីឡាំងម៉ាស៊ីន និងប្រទេសផលិតឱ្យបានច្បាស់លាស់។

៥. ត្រូវបញ្ជាក់ថាអ្នកទទួលសិទ្ធិ មានសិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងការនាំចូល និងចែកចាយទំនិញ ឬអ្នកប្រគល់សិទ្ធិបន្ត មានសិទ្ធិអនុញ្ញាតបន្តផ្តល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកទៅឱ្យអ្នកទទួលសិទ្ធិក្នុងការនាំចូល និងចែកចាយទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៦. សុពលភាពនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ត្រូវមានរយៈពេលអតិបរមា ១០(ដប់) ឆ្នាំ។

៧. ឈ្មោះ និងហត្ថលេខារបស់អ្នកប្រគល់សិទ្ធិ និង/ឬអ្នកប្រគល់សិទ្ធិបន្ត ឬតំណាងដែលមានសិទ្ធិចុះហត្ថលេខា ព្រមទាំងបញ្ជាក់កាលបរិច្ឆេទនៃការចុះហត្ថលេខា។

**គ.ឯកសារភ្ជាប់**

១. លិខិតប្រគល់សិទ្ធិផ្តាច់មុខ និង/ឬលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត និង/ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ច្បាប់ដើម ឬថតចម្លង ចំនួន ០១(មួយ)ច្បាប់។ ក្នុងករណីការប្រគល់លិខិតខាងលើជាឯកសារថតចម្លង អ្នកដាក់ពាក្យត្រូវប្រគល់លិខិតខាងលើ ច្បាប់ដើមក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យ។

២. លិខិតអនុញ្ញាតឱ្យនាំចូលពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬពីរាជរដ្ឋាភិបាល ចំពោះមុខទំនិញជាប់កម្រិតកំណត់ដែលមានចែងក្នុងបទប្បញ្ញត្តិជាធរមាន។

៣. វិញ្ញាបនបត្រចុះបញ្ជីម៉ាក ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី ថតចម្លងចំនួន ០១(មួយ)ច្បាប់។

៤. លក្ខន្តិកៈក្រុមហ៊ុន សម្រង់ព័ត៌មាន និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ថតចម្លងចំនួន ០១(មួយ) ច្បាប់។

៥. ប័ណ្ណពន្ធប៉ាតង់ និងវិញ្ញាបនបត្រចុះបញ្ជីពន្ធដារ (អាករលើតម្លៃបន្ថែម) របស់នីតិបុគ្គល ថតចម្លង ចំនួន ០១(មួយ) ច្បាប់។

៦. វិក្កយបត្របង់កម្រៃសេវាសាធារណៈ។

## ប្រការ១០_ ការបញ្ជាក់អំពីសិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក

១. ម្ចាស់ម៉ាកក្នុងស្រុកដែលបានចុះបញ្ជីម៉ាកនៅកម្ពុជា អាចស្នើសុំមកក្រសួងពាណិជ្ជកម្ម ក្នុងការធ្វើការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ដើម្បីជួយសម្រួលដល់ការនាំចូល និងចែកចាយទំនិញផ្តាច់មុខក្នុងព្រះរាជាណាចក្រកម្ពុជា។

២. ការស្នើសុំលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ម្ចាស់ម៉ាកក្នុងស្រុកត្រូវបំពេញតាមលក្ខខណ្ឌ និងភ្ជាប់នូវឯកសារដូចមានកំណត់ក្នុងប្រការ៤ ប្រការ៥ និងប្រការ៩(១)(ង) ប្រការ៩(២)(ក) និង(គ) ដោយលើកលែងចំណុច(២)(គ)(១) នៃប្រការ៩។

## ប្រការ១១_ សុពលភាព កាតព្វកិច្ច និងសិទ្ធិ

### ១. រយៈពេលនៃការអនុវត្តសិទ្ធិ

ក. លិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា មានសុពលភាពសម្រាប់ការអនុវត្តសិទ្ធិរយៈពេល ២(ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទសុពលភាព ដែលបានកំណត់ក្នុងលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ក្រសួងពាណិជ្ជកម្ម។

ខ. ក្នុងករណីដែលសុពលភាពរបស់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ឬសុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកមានរយៈពេលតិចជាង ២ (ពីរ) ឆ្នាំ សុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវយកតាមសុពលភាពណា ដែលមានរយៈពេលតិចជាងនៃលិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្ត ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក។

### ២. កាតព្វកិច្ច

ក. បន្ទាប់ពីក្រសួងពាណិជ្ជកម្ម បានចេញលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានាឱ្យបានទូលំទូលាយ។ ក្នុងករណីចាំបាច់ ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អាចបញ្ជូនលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកជាឯកសារថតចម្លងឱ្យអ្នកនាំចូលដោយផ្ទាល់ ដើម្បីជូនជ្រាបជាព័ត៌មាន។

ខ. នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ត្រូវផ្សព្វផ្សាយលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្ម និង/ឬក្នុងគេហទំព័ររបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា និងចម្លងជូនអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គ. អ្នកនាំចូលដទៃទៀតក្រៅពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលនាំចូលទំនិញក្រោមលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកដែលចេញដោយក្រសួងពាណិជ្ជកម្ម ត្រូវបញ្ឈប់ការនាំចូលបន្ទាប់ពី ៩០(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃសុពលភាពដែលបានកំណត់ក្នុងលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិត

កត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកដោយក្រសួងពាណិជ្ជកម្ម។ អ្នកនាំចូលដទៃទៀត ដែលមានបំណងនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ ត្រូវធ្វើការចុះបញ្ជីការប្រតិវេទន៍គយឱ្យបានឆាប់បំផុត ហើយត្រូវជានាថា ការនាំចូលត្រូវបញ្ចប់ក្នុងកំឡុងពេល ៩០(កៅសិប)ថ្ងៃខាងលើ។ ការបញ្ឈប់ការនាំចូលនេះ មិនអនុវត្តចំពោះទំនិញដែលបានដាក់ចូលកណ្តាគារគយមានដែនកំណត់ មុនកាលបរិច្ឆេទនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកឡើយ។

៣. **សិទ្ធិរបស់ម្ចាស់ម៉ាកក្នុងស្រុក និងអ្នកទទួលសិទ្ធិ**

ក. ចំពោះសិទ្ធិនៃការបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក និងការកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាក ៖

យោងប្រការ១១(២)(គ) ក្រោយរយៈពេល ៩០(កៅសិប) ថ្ងៃ បន្ទាប់ពីក្រសួងពាណិជ្ជកម្មចេញលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មានសិទ្ធិប្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីហាមឃាត់អ្នកនាំចូលដទៃទៀតក្រៅពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ និងអាចចាត់វិធានការតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ. ចំពោះការបន្តសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ៖

ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មានសិទ្ធិប្តឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ដើម្បីហាមឃាត់អ្នកនាំចូលដទៃទៀតក្រៅពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលនាំចូលទំនិញក្រោមសិទ្ធិផ្តាច់មុខ និងអាចចាត់វិធានការតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន គិតចាប់ពីកាលបរិច្ឆេទសុពលភាពដែលបានកំណត់នៅក្នុងលិខិតបន្តសុពលភាពនៃការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតបន្តសុពលភាពនៃការកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាករបស់ក្រសួងពាណិជ្ជកម្ម។

## ប្រការ១២.- ការបាត់បង់សុពលភាព

សុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាកឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបាត់បង់ជាស្វ័យប្រវត្តិ ប្រសិនបើ ៖

ក. ការប្រគល់សិទ្ធិផ្តាច់មុខ ឬការប្រគល់សិទ្ធិផ្តាច់មុខបន្ត ត្រូវបានដកហូតវិញពីអ្នកប្រគល់សិទ្ធិ ឬ

ខ. ម៉ាកត្រូវបានលុបចេញពីបញ្ជីម៉ាកនៅក្រសួងពាណិជ្ជកម្ម ឬ

គ. ម៉ាកត្រូវបានប្តូរម្ចាស់កម្មសិទ្ធិ ឬ

ឃ. ការអនុញ្ញាតឱ្យនាំចូលទំនិញជាប់កម្រិតកំណត់ ឬការចុះបញ្ជីផលិតផលជាប់កម្រិតកំណត់ ត្រូវបានដកហូតវិញ ដោយក្រសួង ស្ថាប័ន ឬរាជរដ្ឋាភិបាល។

## ប្រការ១៣.- ការធ្វើមោឃភាព

ការធ្វើមោឃភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

១. បុគ្គលពាក់ព័ន្ធអាចស្នើសុំមកក្រសួងពាណិជ្ជកម្ម ឱ្យធ្វើមោឃភាពលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកបាន។

២. ក្រសួងពាណិជ្ជកម្ម មានសិទ្ធិធ្វើមោឃភាពលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ក្នុងករណីដូចខាងក្រោម ៖

ក. លិខិតបញ្ជាក់ ឬលិខិតកត់ត្រាខាងលើ មិនបានបំពេញលក្ខខណ្ឌតម្រូវនៃប្រការ៩ ប្រការ១០ ប្រការ១១ ប្រការ១២ ឬច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬ

ខ. ការផ្តល់លិខិតប្រគល់សិទ្ធិផ្តាច់មុខ និងឯកសារភ្ជាប់មានលក្ខណៈមិនស្របច្បាប់។

គ. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អនុវត្តផ្ទុយនឹងសារាចរណែនាំលេខ ០៧ សរណន ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥ ស្តីពីការទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់រាជរដ្ឋាភិបាល ឬ

ឃ. មានការស្នើសុំពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកប្រគល់សិទ្ធិ និង/ឬពីអ្នកទទួលសិទ្ធិ ដោយភ្ជាប់មកជាមួយនូវឯកសារគាំទ្រ និងភស្តុតាងគ្រប់គ្រាន់។

៣. ការស្នើសុំធ្វើមោឃភាពលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម ហើយកម្រៃដែលបានបង់រួច មិនអាចដកយកមកវិញ ឬផ្ទេរបានឡើយ។

៤. ការធ្វើមោឃភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកមានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ១៤.- ការបន្តសុពលភាព**

១. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដែលមានបំណងបន្តសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវដាក់ពាក្យស្នើសុំឱ្យបានមុន ៣០(សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់ មុខពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ហើយត្រូវបំពេញតាមនីតិវិធី និងលក្ខខណ្ឌ ដូចខាងក្រោម ៖

ក. អ្នកដាក់ពាក្យស្នើសុំ ត្រូវមានកាតព្វកិច្ចបង់កម្រៃសេវាសាធារណៈជូនរដ្ឋ ដូចមានចែងនៅក្នុងកម្រងសេវាសាធារណៈ ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

ខ. ផ្តល់លិខិតប្រគល់សិទ្ធិផ្តាច់មុខនៅមានសុពលភាពច្បាប់ដើម ឬថតចម្លងដែលមានបញ្ជាក់ភាពត្រឹមត្រូវ ឬលិខិតបញ្ជាក់ការអនុញ្ញាតឱ្យប្រគល់សិទ្ធិបន្ត និងលិខិតប្រគល់សិទ្ធិផ្តាច់មុខបន្តនៅមានសុពលភាពច្បាប់ដើម ឬថតចម្លង ដែលមានបញ្ជាក់ភាពត្រឹមត្រូវ

គ. ផ្តល់វិញ្ញាបនបត្រចុះបញ្ជីម៉ាកថតចម្លងនៅមានសុពលភាព

ឃ. ត្រូវបំពេញលក្ខខណ្ឌ និងឯកសារតម្រូវ ដូចមានចែងក្នុងប្រការ៩ នៃប្រកាសនេះ។

២. ការបន្តសុពលភាពលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក និងការបន្តសុពលភាពលិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក មានរយៈពេល ២(ពីរ) ឆ្នាំ។ ក្នុងករណីដែលសុពលភាពរបស់លិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬសុពលភាពនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកមានរយៈពេលតិចជាង ២(ពីរ) ឆ្នាំ រយៈពេលសម្រាប់ការបន្តសុពលភាពនៃលិខិតបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក និងរយៈពេលសម្រាប់ការបន្តសុពលភាព លិខិតកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវយកតាមសុពលភាពណាដែលមានរយៈពេលតិចជាង ដែលមាននៅក្នុងលិខិតប្រគល់សិទ្ធិផ្តាច់មុខ ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាក។

៣. លិខិតបន្តសុពលភាពការបញ្ជាក់សិទ្ធិផ្តាច់មុខពីការចុះបញ្ជីម៉ាក និងលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក មានប្រសិទ្ធភាពអនុវត្តចាប់ពីកាលបរិច្ឆេទដែលបានកំណត់នៅក្នុងលិខិតបន្តសុពលភាព

ការបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក របស់ក្រសួងពាណិជ្ជកម្ម។

៤. បន្ទាប់ពីក្រសួងពាណិជ្ជកម្ម បានចេញលិខិតបន្តសុពលភាពបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ត្រូវផ្សព្វផ្សាយជាបន្ទាន់ ដូចមានចែងក្នុងប្រការ១១(២)(ក) និង (ខ) នៃប្រកាសនេះ។

៥. ក្នុងករណីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ដាក់ពាក្យស្នើសុំបន្តសុពលភាពលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬលិខិតបន្តសុពលភាពការកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ក្រោយកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ១៤(១) នៃប្រកាសនេះ ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មិនអាចដាក់ពាក្យស្នើសុំបន្តសុពលភាពបានទេ ប៉ុន្តែអាចដាក់ពាក្យស្នើសុំការបញ្ជាក់ថ្មីនៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក និងការកត់ត្រាថ្មីនៃលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាកបាន ហើយលិខិតរបស់ក្រសួងពាណិជ្ជកម្មត្រូវចាត់ទុកថាជាលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាក ហើយមានប្រសិទ្ធភាពអនុវត្តដូចមានចែងក្នុងប្រការ១១(៣)(ក) ដែលម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ មានសិទ្ធិប្ដឹងទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃបន្ទាប់។ រយៈពេលនៃការអនុវត្តសិទ្ធិមានកំណត់ក្នុងលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខថ្មីពីការចុះបញ្ជីម៉ាក ឬលិខិតកត់ត្រាប្រគល់សិទ្ធិផ្ដាច់មុខថ្មីក្នុងការប្រើប្រាស់ម៉ាកផងដែរ។

## ប្រការ១៥.- រយៈពេលនៃការប្ដឹងតវ៉ា

១. បុគ្គលពាក់ព័ន្ធមានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ឬតុលាការ ក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចពាក់ព័ន្ធនឹងលិខិតបញ្ជាក់សិទ្ធិផ្ដាច់មុខពីការចុះបញ្ជីម៉ាក ឬការកត់ត្រាលិខិតប្រគល់សិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ដោយក្រសួងពាណិជ្ជកម្ម។

២. សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ជាកម្មវត្ថុនៃការប្ដឹងតវ៉ាទៅតុលាការក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម។

## ប្រការ១៦.- ការរំលោភបំពានសិទ្ធិ និងនីតិវិធីដោះស្រាយវិវាទ

ការរំលោភបំពានសិទ្ធិនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខត្រូវដោះស្រាយ ដូចខាងក្រោម ៖

១. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ អាចចេញលិខិតព្រមានដល់អ្នកនាំចូលស្របគ្នាដទៃទៀតដែលនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខ ឱ្យបញ្ឈប់ការនាំចូលដែលរំលោភបំពានទៅលើសិទ្ធិស្របច្បាប់របស់ខ្លួន។

២. តាមការស្នើសុំពីម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ក្រសួងពាណិជ្ជកម្មអាចចេញលិខិតព្រមានដល់អ្នកនាំចូលស្របគ្នាដទៃទៀត ដែលនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខ ឱ្យបញ្ឈប់ការនាំចូលទំនិញដែលរំលោភបំពានទៅលើសិទ្ធិស្របច្បាប់របស់ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ។

៣. ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ និងអ្នកនាំចូលដទៃទៀត អាចធ្វើការសម្របសម្រួលគ្នា ដូចខាងក្រោម៖

- អនុញ្ញាតឱ្យអ្នកនាំចូលទំនិញក្រោមសិទ្ធិផ្ដាច់មុខ បន្តលក់ទំនិញ ដែលបាននាំចូលរួចមកហើយ ឱ្យអស់ពីក្នុងស្តុក ប៉ុន្តែត្រូវមានការទូទាត់សំណងនៃការខូចខាតក្នុងតម្លៃសមស្រប ជូនម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ឬ
- ម្ចាស់ម៉ាកក្នុងស្រុក ឬអ្នកទទួលសិទ្ធិ ទទួលទិញទំនិញខាងលើតាមថ្លៃសមស្រប។

៤. ក្នុងករណីដែលភាគីវិវាទគ្មានការឯកភាពគ្នាតាមជម្រើសណាមួយនៃចំណុចខាងលើ ទំនិញដែលនាំចូលនោះត្រូវបញ្ជូនត្រឡប់ទៅប្រទេសដើមវិញ។

៥. ភាគីវិវាទត្រូវធ្វើកំណត់ហេតុអំពីលទ្ធផលនៃការសម្របសម្រួល ដោយចុះហត្ថលេខា ឬផ្តិតមេដៃ ដែលមានការបញ្ជាក់ពីមេធាវី ឬអាជ្ញាធរមានសមត្ថកិច្ច ហើយបញ្ជូនកំណត់ហេតុនេះមួយច្បាប់មកក្រសួងពាណិជ្ជកម្ម។

៦. កំណត់ហេតុស្តីពីលទ្ធផលសម្របសម្រួលអាចប្រើប្រាស់ជាឯកសារគាំទ្រ ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៧. ភាគីទាំងពីរ អាចជ្រើសរើសយកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឬដាក់ពាក្យបណ្តឹងទៅតុលាការ។

## ប្រការ១៧._ និរាករណ៍

ប្រកាសលេខ ១៨៦ ព.ណ.កសប.ប្រក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ ស្តីពីនីតិវិធីសម្រាប់ការកត់ត្រា និងតម្កល់លិខិតប្រគល់សិទ្ធិនាំចូលទំនិញពាក់ម៉ាកផ្តាច់មុខ របស់ក្រសួងពាណិជ្ជកម្ម ត្រូវទុកជានិរាករណ៍។

## ប្រការ១៨._ អវសានប្បញ្ញត្តិ

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន គ្រប់ប្រធាននាយកដ្ឋាន និងគ្រប់ប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៨
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន៖ វីឡាលេខ៦៤ ផ្លូវ ៥៩២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

**Address: #64, St 592, BeungKak II, Khan TuolKork, Phnom Penh, Cambodia**

អ៊ីម៉ែល/Email៖ info@ipac-cambodia.org.kh ׀ វិបសាយ/Website៖ ipac-cambodia.org.kh

Facebook៖ សមាគមកម្មសិទ្ធិបញ្ញាកម្ពុជា ׀ ទូរស័ព្ទ/Tel ៖ ០១២ ៩១០ ៩៩៩